គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល

មហាសន្និបាតវិសាមញ្ញ
តំណាងទូទាំងប្រទេស

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃអាទិត្យ ៥កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១៨

# កម្មវិធីនយោបាយ
# របស់គណបក្សប្រជាជនកម្ពុជាសម្រាប់
# ការកសាង និងការពារមាតុភូមិ ឆ្នាំ២០១៨-២០២៣

## បុព្វកថា

**គណបក្សប្រជាជនកម្ពុជា** មានឈ្មោះដើមថា **បក្សប្រជាជនបដិវត្តន៍ខ្មែរ** ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ១៩៥១ ដោយមានប្រភពចេញពីចលនាតស៊ូស្នេហាជាតិរបស់ប្រជាជនកម្ពុជាប្រឆាំងអាណានិគមនិយមបារាំងដើម្បីឯករាជ្យជាតិ ។ ចាប់ពីពេលបដិសន្ធិមក គណបក្សប្រជាជនកម្ពុជាបានរក្សាខ្ជាប់ឥតប្រែប្រួលនូវសារជាតិរបស់ខ្លួនដែលជាតំណាងដ៏បរិសុទ្ធនៃផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់ប្រជាជនកម្ពុជា ប្តេជ្ញាជម្នះរាល់ឧបសគ្គ ហ៊ានធ្វើពលិកម្មមិនរួញរា សំដៅកសាងប្រទេសកម្ពុជាមួយ ឯករាជ្យ សន្តិភាព សេរីភាព អព្យាក្រឹត ប្រជាធិបតេយ្យ និងវឌ្ឍនភាព។ ដើម្បីសម្រេចគោលបំណង និងឧត្តមគតិដ៏ថ្លៃថ្លានេះ គណបក្សបានតម្កល់ខ្ពស់ឧត្តមគតិស្នេហាជាតិបរិសុទ្ធ គោរពតួនាទីរបស់ប្រជាជនដែលជាអ្នកកសាងប្រវត្តិសាស្ត្រ លើកស្ទួយលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិសេរីភាពរបស់ប្រជាជន និងប្រកាន់យកវិធីត្រិះរិះពិចារណាប្រកបដោយវិទ្យាសាស្ត្រធ្វើជាមូលដ្ឋាននៃមនោគមវិជ្ជារបស់ខ្លួន ដែលបានធានាឲ្យគណបក្សបំពេញបេសកកម្មបម្រើជាតិ និងប្រជាជន ដោយជោគជ័យ។

ប្រវត្តិសាស្ត្របានបង្ហាញច្បាស់ថា រយៈពេល៦៦ឆ្នាំមកនេះ ទោះបីត្រូវប្រឈមនឹងការវិវត្តន៍ប្រែប្រួលយ៉ាងស្មុគស្មាញបំផុតនៃសភាពការណ៍ជាតិ និងសភាពការណ៍អន្តរជាតិយ៉ាងណាក្តី ក៏គណបក្សប្រជាជនកម្ពុជាបានស្ថិតនៅផ្សារភ្ជាប់ខ្លួនជានិច្ចជាមួយប្រជាជន ហើយបានពុះពារឆ្លងកាត់ដំណាក់កាលធំៗនៃប្រវត្តិសាស្ត្ររបស់ជាតិប្រកបដោយវីរភាព គឺ : ការតស៊ូប្រឆាំងរបបអាណានិគមនិយមដើម្បីឯករាជ្យជាតិ, ការការពារឯករាជ្យ សន្តិភាព អព្យាក្រឹតភាព ប្រឆាំងការជ្រៀតជ្រែករបស់បរទេស ពីឆ្នាំ ១៩៥៣-១៩៧០ , សង្គ្រាមដែលបង្កឡើងដោយរបបសាធារណរដ្ឋខ្មែរ និងពួកបរទេសឈ្លានពានពីឆ្នាំ ១៩៧០-១៩៧៥ ជាពិសេសការតស៊ូសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍ ការការពារការរស់ឡើងវិញរបស់ជាតិ និងការស្តារ កសាង និងអភិវឌ្ឍមាតុភូមិ ។

យើងចងចាំមិនអាចបំភ្លេចបានថា មាតុភូមិកម្ពុជាបានឆ្លងកាត់អតីតកាលដ៏ខ្មៅងងឹតបំផុត ដែលក្រាលដោតជាំដោយឈាម និងទឹកភ្នែករបស់ប្រជាជន។ មហន្តរាយ និងសោកនាដកម្មដ៏ធំធេងនេះ គឺផ្តើមឡើងដោយរដ្ឋប្រហារនៅថ្ងៃ ១៨ ខែមីនា ឆ្នាំ១៩៧០ តាមខ្សែញាក់របស់បរទេស ដែលបង្កជាភ្លើងសង្គ្រាមឆាបឆេះយ៉ាងសន្ធោរសន្ធៅ ដុតបំផ្លាញទឹកដីមាតុភូមិយើង និងបានសម្លាប់អាយុជីវិតប្រជាជនកម្ពុជាជាងកន្លះលាននាក់។ ក្រោយជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ នាថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជនកម្ពុជាសង្ឃឹមថានឹងបានរស់ក្នុងសន្តិភាព ប៉ុន្តែផ្ទុយទៅវិញបនក្បត់ប៉ុល ពត បានប្លន់យកទាំងស្រុងនូវសមិទ្ធផលនៃជ័យជម្នះនេះ ហើយបង្កើតឡើងរបបកម្ពុជាប្រជាធិបតេយ្យដែលបានអនុវត្តនយោបាយប្រល័យពូជសាសន៍ដ៏យង់ឃ្នង ធ្វើឲ្យទឹកដីមាតុភូមិយើងទាំងមូលប្រែក្លាយជាវាលពិឃាតយ៉ាងសាហាវឃោរឃៅបំផុត ។ ក្នុងរយៈពេលតែ ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ពួកប៉ុល ពត បានបំផ្លាញរចនាសម្ព័ន្ធសង្គមជាតិឲ្យរលាយខ្ទេចខ្ទីដល់ឫសគល់ សិទ្ធិសេរីភាពដែលជាតម្លៃជាសារវ័ន្តរបស់មនុស្សត្រូវបានលុបបំបាត់ទាំងស្រុង ប្រជាជនកម្ពុជា ៣លាន ៣សែននាក់ ត្រូវបានសម្លាប់យ៉ាងអយុត្តិធម៌។

នៅក្នុងកាលៈទេសៈដ៏ធ្ងន់ធ្ងរបំផុតនេះ បណ្តាកម្លាំងអ្នកស្នេហាជាតិដ៏បរិសុទ្ធនៃគណបក្សប្រជាជនកម្ពុជាដែលនៅសេសសល់ពីការកាប់សម្លាប់ បានផ្តាច់ខ្លួនចេញពីរបបប៉ុល ពត ដើម្បីធ្វើការតស៊ូសង្គ្រោះជាតិពីរបបដ៏យង់ឃ្នងនេះ។ ក្នុងដំណើរឆ្ពោះទៅការសង្គ្រោះជាតិ ប្រវត្តិសាស្ត្របានកត់ត្រាទុកនូវព្រឹត្តិការណ៍សំខាន់ៗដែលមានអត្ថន័យយ៉ាងជ្រាលជ្រៅចំពោះជាតិ គឺ : នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៧៧ សម្តេច **ហ៊ុន សែន** បានចេញដំណើរភៀសខ្លួនទៅប្រទេសវៀតណាម ដើម្បីស្វែងរកការជួយឧបត្ថម្ភក្នុងការតស៊ូរំដោះជាតិ , នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៧៨ កងកម្លាំងប្រដាប់អាវុធសង្គ្រោះជាតិកម្ពុជាដែលជាអង្គភាពទ័ពរៀបរយដំបូងត្រូវបានបង្កើតឡើង , នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៨ កងទ័ព និងប្រជាជនទូទាំងភូមិភាគបូព៌ាបានក្រោកឈរប្រឆាំងនឹងរបបប៉ុល ពត ក្រោមការដឹកនាំរបស់សម្តេច **ហេង សំរិន** និងសម្តេច **ជា ស៊ីម** ព្រមទាំងចលនាតស៊ូដែលមានរួចមកហើយនៅខេត្តកោះកុង និងនៅឦសានទិស ។ ផ្តើមចេញពីចលនាទាំងនេះ បានផ្តល់ឱកាសដល់ការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា **នាថ្ងៃ ២ ធ្នូ ឆ្នាំ១៩៧៨** ដែលជាអង្គការចាត់តាំងនយោបាយតែមួយគត់របស់ប្រជាជនកម្ពុជា ដើម្បីដឹកនាំការតស៊ូផ្តួលរំលំរបបប្រល័យពូជសាសន៍។ រណសិរ្សសាមគ្គីសង្គ្រោះជាតិ និងកងកម្លាំងប្រដាប់អាវុធបដិវត្តន៍កម្ពុជា ដែលមានការគាំទ្រពីប្រជាជននៅទូទាំងប្រទេស ព្រមទាំងទទួលបានការជួយឧបត្ថម្ភដ៏ស្មោះស ទាន់ពេលវេលាពីសំណាក់កងទ័ពស្ម័គ្រចិត្តវៀតណាម និងការគាំទ្រពីកម្លាំងស្នេហាសន្តិភាព និងយុត្តិធម៌នានានៅលើពិភពលោក បានវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ សម្រេចបានមហាជ័យជម្នះជាប្រវត្តិសាស្ត្រនា**ថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩**។ ជ័យជម្នះ ៧ មករា បានសង្គ្រោះអាយុជីវិតប្រជាជនកម្ពុជារាប់លាននាក់ដែលនៅរង់ចាំតែសេចក្តីស្លាប់បានទាន់ពេលវេលា បានធ្វើឲ្យរាល់តម្លៃទាំងខាងស្មារតី និងសម្ភារៈរបស់ប្រជាជាតិដែលបានកសាងក្នុងប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំរបស់ខ្លួនបានរស់ឡើងវិញ បានបិទទំព័រសករាជដ៏ខ្មៅងងឹតបំផុតនៃកម្ពុជា ហើយបើកឡើង**នូវទំព័រសករាជថ្មី គឺឯករាជ្យ សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម។** ប្រជាជនកម្ពុជាដណ្តើមបានមកវិញនូវសិទ្ធិសេរីភាពគ្រប់យ៉ាង ក្លាយជាអ្នកធ្វើម្ចាស់លើជោគវាសនារបស់ខ្លួនពិតប្រាកដ។ ព្រមជាមួយនេះ ជ័យជម្នះ៧មករាបានរួមវិភាគទានដ៏សកម្មដល់សន្តិភាព និងស្ថិរភាពនៅ

ក្នុងតំបន់ ។ នេះជា**សច្ចធម៌ប្រវត្តិសាស្ត្រដែលគ្មានជនណា ឬកម្លាំងណាអាចមកបំភ្លៃ បំផ្លើស និង បំផ្លាញបានឡើយ ។**

បន្ទាប់ពីថ្ងៃជ័យជម្នះ ៧ មករា ប្រទេសជាតិនៅតែត្រូវប្រឈមមុខនឹងឧបសគ្គធំៗយ៉ាងច្រើន ព្រមទាំងផលវិបាករាប់ម៉ឺនជំពូកដែលបន្សល់ទុកដោយសង្គ្រាម ៥ឆ្នាំ ក្រោយថ្ងៃរដ្ឋប្រហារ និងរបបប្រល័យពូជសាសន៍។ ប៉ុន្តែការប្តេជ្ញាចិត្តដ៏មោះមុតរបស់ប្រជាជនកម្ពុជា ដើម្បីដើរចេញឲ្យផុតពីស្រមោលអតីតកាលដ៏ឈឺចាប់ឆ្ពោះទៅរកអនាគតមួយដ៏រុងរឿង គឺគ្មានអ្វីអាចមកបន្ទច់បង្អាក់បានឡើយ ។ លើមូលដ្ឋានជ័យជម្នះ ៧ មករា សាធារណរដ្ឋប្រជាមានិតកម្ពុជា (បានប្តូរឈ្មោះជារដ្ឋកម្ពុជានៅឆ្នាំ ១៩៨៩) ដែលជារដ្ឋរបស់ប្រជាជន និងដើម្បីប្រជាជន ត្រូវបានបង្កើតឡើង និងដឹកនាំដោយក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ដែលបានគ្រប់គ្រងប្រទេសក្នុងស្ថានភាពដែលខ្ទេចខ្ទីសេដ្ឋកិច្ច សង្គមត្រូវបំផ្លាញខ្ទេចខ្ទី និងក្នុងកាលៈទេសៈមានសន្តិភាពផង និងសង្គ្រាមផង ព្រមទាំងត្រូវមជ្ឈដ្ឋានខាងក្រៅមួយចំនួនហ៊ុមព័ទ្ធខាងនយោបាយ និងសេដ្ឋកិច្ចយ៉ាងអយុត្តិធម៌ និងអមនុស្សធម៌ថែមទៀត។ ភារកិច្ចចម្បងៗរបស់យើងនៅពេលនោះគឺ ទប់ស្កាត់មិនឲ្យរបបប្រល័យពូជសាសន៍វិលត្រឡប់មកវិញបានដើម្បីការពារការរស់ឡើងវិញរបស់ជាតិ ខិតខំស្តារ និងកសាងសេដ្ឋកិច្ច សង្គមឡើងវិញពីលេខសូន្យ ពីបាតដៃទទេ ដើម្បីធ្វើឲ្យជីវភាពប្រជាជនមានស្ថិរភាពជាជំហានៗ ។ អាស្រ័យដោយកម្លាំងមហាសាមគ្គីជាតិ យើងបាននាំប្រទេសជាតិឲ្យឆ្លងផុតដំណាក់កាលដែលលំបាកបំផុតឈានមកដល់ដំណាក់កាលពង្រឹងពង្រីកខ្លួនតែក្នុងរយៈពេល ១០ឆ្នាំប៉ុណ្ណោះ ដែលបានបង្កបុព្វបទ និងលក្ខណសម្បត្តិចាំបាច់ជាមូលដ្ឋានឲ្យប្រជាជាតិយើងអាចបន្តបោះជំហានទៅមុខឥតឈប់ឈរប្រកបដោយជោគជ័យរហូតមកដល់បច្ចុប្បន្ន ។

សរុបមក រយៈពេល ៣៩ឆ្នាំកន្លងមកនេះ គណបក្សប្រជាជនកម្ពុជាបានដឹកនាំប្រទេសសម្រេចបានសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រជូនជាតិ និងប្រជាជន គឺ ៖

### ដំណាក់កាលឆ្នាំ ១៩៧៩ - ១៩៩៣

១- បានសម្រេចមហាជ័យជម្នះជាប្រវត្តិសាស្ត្រ ថ្ងៃ ៧មករា ឆ្នាំ១៩៧៩ ដែលបានសង្គ្រោះជាតិឲ្យរស់ឡើងវិញរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយបានទប់ស្កាត់របបដ៏យង់ឃ្នងនេះមិនឲ្យវិលត្រឡប់មកកម្ពុជាវិញជាលើកទី២ ។

២- បាននាំមកជូនប្រជាជនវិញនូវសិទ្ធិ សេរីភាពគ្រប់យ៉ាង លទ្ធិប្រជាធិបតេយ្យ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលរបបប្រល័យពូជសាសន៍បានកម្ទេចទាំងស្រុងទៅហើយនោះ ។

៣- បានស្តារ និងកសាងសេដ្ឋកិច្ច សង្គមឡើងវិញចាប់ពីសូន្យឲ្យមានស្ថិរភាពជាជំហានៗ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការកសាង និងអភិវឌ្ឍប្រទេសឲ្យរីកចម្រើនជាបន្តបន្ទាប់មកដល់បច្ចុប្បន្ន ។

៤- បានធ្វើជាកម្លាំងស្នូលនៃការបង្រួបបង្រួមជាតិ រហូតសម្រេចបានកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា នាទីក្រុងប៉ារីស ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ និងជាកម្លាំងមិនអាចខ្វះបានក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ ពីឆ្នាំ ១៩៩១-១៩៩៣ ។

### ដំណាក់កាល ឆ្នាំ ១៩៩៣-២០១៧

១- បន្តទប់ស្កាត់យ៉ាងមានប្រសិទ្ធភាពនូវការប៉ុនប៉ងវិលត្រឡប់មកវិញនៃរបបប្រល័យពូជ-

សាសន៍ ការពាររាល់សមិទ្ធផលនៃសង្គមជាតិ ការពាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលជាសមិទ្ធផលដ៏ថ្លៃថ្លាបំផុតនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ការពារនិរន្តរភាពនៃរដ្ឋសភា និងរាជរដ្ឋាភិបាល រក្សាស្ថិរភាពនយោបាយ ស្ថិរភាពសង្គមបានរឹងមាំ ធ្វើឲ្យប្រជាជនបានរស់នៅដោយសុខសាន្ត ។

២- ការពារកម្មសិទ្ធិស្របច្បាប់របស់ប្រជាជន ការពារអាជីពរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ និងការពាររាល់កិច្ចសន្យាវិនិយោគទុនពីសម័យរដ្ឋកម្ពុជា ។

៣- ក្នុងនាមជាគណបក្សដែលបានកាន់អំណាចជាបន្តបន្ទាប់ គណបក្សបានការពារ និងពង្រីកឥតឈប់ឈរនូវប្រព័ន្ធប្រជាធិបតេយ្យសេរី ពហុបក្ស លើកកម្ពស់ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស សម្រេចការបោះឆ្នោតទាំងសកល និងអសកល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាបន្តបន្ទាប់ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌។ គណបក្សបានដោះស្រាយរាល់បញ្ហាដែលកើតមានក្រោយការបោះឆ្នោតម្តងៗ តាមរយៈការចរចា ដោយឈរលើមូលដ្ឋានតម្កល់ខ្ពស់បំផុតនូវផលប្រយោជន៍ជាតិ និងប្រជាជន គណបក្សបានរក្សាស្ថិរភាពនៃរាជបល្ល័ង្ក និងសម្រេចការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដែលធានាឲ្យប្រទេសជាតិមានស្ថិរភាព និងបន្តឈានទៅមុខយ៉ាងត្រឹមត្រូវតាមគន្លងនៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ។

៤- ជោគជ័យនៃ**នយោបាយឈ្នះ ឈ្នះ** របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានធ្វើឲ្យពួកប្រល័យពូជសាសន៍ ប៉ុល ពត ត្រូវរលំរលាយទាំងស្រុងទាំងអង្គការចាត់តាំងនយោបាយ ទាំងអង្គការចាត់តាំងយោធា ប្រទេសជាតិទាំងមូលទទួលបានសន្តិភាពពេញលេញ មានឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុងចាប់ពីចុងឆ្នាំ១៩៩៨មក ។ ចាប់ពីពេលនោះ កម្ពុជាបានបោះជំហានទៅមុខយ៉ាងរឹងមាំលើមាគ៌ាសន្តិភាព បង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ សហប្រតិបត្តិការ និងអភិវឌ្ឍន៍ ។ ប្រជាជនកម្ពុជាបានរស់នៅយ៉ាងសុខដុមរមនាក្នុងសង្គមជាតិ ដោយគ្មានការរើសអើងអំពីអតីតកាល ឬនិន្នាការនយោបាយឡើយ ។ សន្តិភាព និងស្ថិរភាពនយោបាយបានផ្តល់ឱកាសដ៏មានតម្លៃបំផុតដែលពុំធ្លាប់មានដល់ប្រជាជនកម្ពុជាក្នុងការអភិវឌ្ឍសង្គមជាតិ ។

អាស្រ័យដោយនយោបាយ ឈ្នះ ឈ្នះ មានគុណតម្លៃប្រវត្តិសាស្ត្រដ៏ធំធេង យើងបាន និងកំពុងកសាងឡើងនូវវិមាន ឈ្នះ ឈ្នះ ព្រមទាំងកំណត់យកថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៩៨ ជា "ទិវានយោបាយ ឈ្នះ ឈ្នះ" ដើម្បីចារិក និងតម្កល់និមិត្តរូប វត្ថុតាង និងសមិទ្ធផលទាំងអស់ដែលពាក់ព័ន្ធ ទុកជាការចងចាំ និងជាមេរៀនសម្រាប់មនុស្សជំនាន់ក្រោយតរៀងទៅ។

៥- អនុវត្តកំណែទម្រង់រដ្ឋដ៏ទូលំទូលាយ និងស៊ីជម្រៅប្រកបដោយផ្លែផ្កា រួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ ការប្រឆាំងអំពើពុករលួយ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងធនធានធម្មជាតិ ដីធ្លី ព្រៃឈើ ជលផល និងបរិស្ថាន ដែលបានធានាដល់ការលើកកម្ពស់អភិបាលកិច្ចល្អ ការពង្រឹងយុត្តិធម៌ សមធម៌សង្គម និងការអភិវឌ្ឍប្រទេសជាតិ ។ នៅក្នុងដំណើរការកែទម្រង់នេះដែរ គណបក្សបានដាក់ចេញនូវគោលនយោបាយថ្មីៗ និងបានកែសម្រួលគោលនយោបាយជាបន្តបន្ទាប់ដែលបានផ្តល់ផលប្រយោជន៍ផ្ទាល់ដល់មន្ត្រីរាជការ

កងកម្លាំងប្រដាប់អាវុធ កសិករ កម្មករ និយោជិត អាជីវករ និងប្រជាជនទូទៅ។

៦- អភិវឌ្ឍសេដ្ឋកិច្ច សង្គម ឱ្យមានការរីកចម្រើនឥតឈប់ឈរ ប្រកបដោយចីរភាព និងសមធម៌ ព្រមទាំងធន់នឹងវិបត្តិ ដែលបានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅនូវជីវភាពរបស់ប្រជាជន ទាំងខាងសម្ភារៈ ទាំងខាងស្មារតី ក្នុងនោះ ផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់ៗបានកើនពី ២២៣ ដុល្លារអាមេរិក នៅឆ្នាំ ១៩៩៣ ដល់ ១៣០៧ ដុល្លារ នៅឆ្នាំ ២០១៦ និងដល់១៤៣៥ដុល្លារ នៅឆ្នាំ២០១៧ ជាមួយនោះ កម្ពុជាកំពុងតែផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម និងសេវាកម្ម។ កម្ពុជាបានប្រែក្លាយពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងកំពុងបន្តដំណើរយ៉ាងស្វាហាប់ឈានឆ្ពោះទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ ។ កម្ពុជាត្រូវបានចាត់ទុកថាជាប្រទេសឯតទគ្គករកំណើន និងជាខ្លាសេដ្ឋកិច្ចថ្មីមួយនៅអាស៊ី ដោយរក្សាកំណើនខ្ពស់ជាមធ្យម ៧,៧% ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ដែលឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើនយ៉ាងរហ័សនូវវិស័យឧស្សាហកម្ម, កម្មន្តសាល, សំណង់, កសិកម្ម, សេវាកម្ម, ទេសចរណ៍ និង អចលនទ្រព្យ ជាដើម ។

៧- រក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមបានរឹងមាំ រាំងស្កាត់ឧបាយកលរបស់ពួកប្រឆាំង និងមជ្ឈដ្ឋានអគតិនានា ដែលបានប្រើប្រាស់ចលនាបដិវត្តន៍ពណ៌ប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ការពារសង្គមជាតិមិនឲ្យធ្លាក់ទៅក្នុងកលិយុគ អស្ថិរភាព ការបែកបាក់ និងសង្គ្រាមសាជាថ្មីទៀត ។ កសាងខឿនការពារជាតិរបស់ប្រជាជនយ៉ាងរឹងមាំ ដែលធានាការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាមិនឲ្យបាត់បង់សូម្បីបន្តិចណាឡើយ ។ ដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងតាមរយៈការចរចាដោយសន្តិវិធី ដោយផ្អែកលើរដ្ឋធម្មនុញ្ញ ច្បាប់ជាតិ ច្បាប់អន្តរជាតិ និងឯកសារពាក់ព័ន្ធនានាដែលបានបន្សល់ទុកពីអាណានិគមនិយមបារាំង កសាងខ្សែបន្ទាត់ព្រំដែនប្រកបដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍។

៨- លើកស្ទួយកិត្តិយស កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជាឡើងវិញនៅលើឆាកអន្តរជាតិ មានចំណងមិត្តភាព និងសហប្រតិបត្តិការល្អជាមួយគ្រប់ប្រទេសដោយមិនប្រកាន់របបនយោបាយ ហើយបានធ្វើឲ្យមានទំនាក់ទំនងជាប្រក្រតីជាមួយអង្គការអន្តរជាតិនានា ទាំងក្នុងក្របខណ្ឌតំបន់ ក៏ដូចពិភពលោក ដែលបាននាំមកនូវការគាំទ្រ និងជំនួយឧបត្ថម្ភយ៉ាងច្រើនសម្រាប់ការអភិវឌ្ឍ។ កម្ពុជាបានក្លាយជាប្រទេសដែលស្មើភាព និងស្មើសិទ្ធិជាមួយបណ្តាប្រទេសក្នុងការចូលរួមរាល់កិច្ចការអន្តរជាតិ។ កម្ពុជាដែលធ្លាប់ជាប្រទេសទទួលកងទ័ពរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ បច្ចុប្បន្នបានក្លាយជាប្រទេសដែលបានបញ្ជូនកងកម្លាំងរក្សាសន្តិភាពរបស់ខ្លួន ទៅជួយថែរក្សាសន្តិភាពនៅប្រទេសមួយចំនួនវិញ ក្នុងក្របខណ្ឌប្រតិបត្តិការនៃអង្គការសហប្រជាជាតិ។ កម្ពុជាបានសម្រេចការចុះបញ្ជីប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក និងបេតិកភណ្ឌអរូបិយមួយចំនួនទៀតទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។

ឆ្លងតាមបណ្តាសមិទ្ធផលដ៏វិសេសវិសាលខាងលើនេះ បានបង្ហាញច្បាស់ថា រយៈពេល ៣៩ ឆ្នាំកន្លងទៅនេះ ផ្តើមពីជ័យជម្នះ៧មករា ប្រជាជនកម្ពុជាបានសម្រេចនូវការផ្លាស់ប្តូរសង្គមយ៉ាងធំធេង ដែលពុំអាចនឹកស្មានដល់ ។ កម្ពុជាបានប្រែក្លាយពីវាលពិឃាតនៃរបបប្រល័យពូជសាសន៍ ពីសមរភូមិនៃសង្គ្រាមដ៏រ៉ាំរ៉ៃ ពីការបែកបាក់ជាតិ និងការបែងចែកទឹកដី ពីគំនរផេះផង់ ទៅជាទឹកដីដែលមានសន្តិភាព

ឯកភាព ស្ថិរភាព សេរីភាព ប្រជាធិបតេយ្យ នីតិរដ្ឋ និងអភិវឌ្ឍន៍លើគ្រប់វិស័យដែលធ្វើឲ្យប្រជាជនគ្រប់រូបបានរស់នៅប្រកបដោយក្តីសង្ឃឹមយ៉ាងសុខដុមរមនាក្រោមដំបូលនៃរដ្ឋធម្មនុញ្ញតែមួយ និងម្លប់ដ៏ត្រជាក់នៃអង្គព្រះមហាក្សត្រជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។ **គឺគណបក្សប្រជាជនកម្ពុជាដែលបានដឹកនាំធ្វើឲ្យសម្រេចនូវការផ្លាស់ប្តូរដ៏ធំធេងនេះ** ។

សន្តិភាព ស្ថិរភាព និងរាល់សមិទ្ធផលដែលយើងសម្រេចបានមកដល់ពេលនេះ គឺបានមកពីការយកអាយុជីវិតធ្វើជាដើមទុន ពីពលិកម្មដ៏ធំធេង និងមិនអាចកាត់ថ្លៃបានរបស់យុទ្ធជន យុទ្ធនារី មន្ត្រី សមាជិក សមាជិកាគណបក្ស និងជនរួមជាតិយើងរាប់លាននាក់ដើម្បីជាតិ មាតុភូមិ ព្រមទាំងការជួយឧបត្ថម្ភគាំទ្រដ៏ស្មោះសពីបណ្តាប្រទេសជាមិត្ត និងសហគមន៍អន្តរជាតិ ។ អាស្រ័យហេតុនេះ យើងប្តេជ្ញាថែរក្សាសមិទ្ធផលដ៏ថ្លៃថ្លានេះឲ្យគង់វង្សជារៀងរហូត ដោយមិនអនុញ្ញាតឲ្យមជ្ឈដ្ឋានណាមួយមកបំផ្លាញទៅវិញបានឡើយ ទោះបីជាត្រូវបង់ដោយតម្លៃណាក្តី ។ យើងប្តេជ្ញាថែរក្សា និងបន្តកសាងប្រទេសជាតិយើងឲ្យកាន់តែរីកចម្រើនក្លាយជាប្រទេសជឿនលឿនមួយក្នុងតំបន់ ជាសង្គមប្រកបដោយអរិយធម៌ និងសេចក្តីស្រឡាញ់ ដោយគ្មានការកើតឡើងជាថ្មីនូវសង្គ្រាម អំពើប្រល័យពូជសាសន៍ និងការបែកបាក់ផ្ទៃក្នុងជាតិដូចពេលមុនទៀត ។

នៅលើមាគ៌ានៃជ័យជម្នះ និងដំណើរឆ្ពោះទៅមុខទៀត គណបក្សចងចាំ និងចារិកទុកជារៀងរហូតនូវស្មារតីលះបង់ និងការចូលរួមយ៉ាងធំធេងរបស់សមាជិក សមាជិកាគណបក្ស និងជនរួមជាតិនៅគ្រប់ទិសទីនៅក្នុងបុព្វហេតុដ៏ឧត្តុង្គឧត្តមរបស់ប្រជាជាតិ និងគណបក្ស ហើយគាំទ្រពេញទំហឹងចំពោះបេក្ខភាពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់នីតិកាលទី ៦ នៃរដ្ឋសភា ព្រមទាំងនីតិកាលបន្តបន្ទាប់ទៀត។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** គឺជា**ស្នូលរបស់គណបក្សប្រជាជនកម្ពុជា និងជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមនៃប្រជាជនកម្ពុជា** ដែលបានដឹកនាំប្រទេសប្រកបដោយគតិបណ្ឌិត ភាពឈ្លាសវៃ និងភាពអង់អាច សម្រេចបានជោគជ័យដ៏ត្រចះត្រចង់បំផុតជូនជាតិ មាតុភូមិ និងប្រជាជន ។

ដើម្បីបន្តបេសកកម្មបម្រើជាតិ និងប្រជាជនឲ្យសម្រេចបានសមិទ្ធផលកាន់តែធំធេងឡើងថែមទៀត **គណបក្សប្រជាជនកម្ពុជា** សូមប្រកាសកម្មវិធីនយោបាយសម្រាប់ការកសាង និងការពារមាតុភូមិពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២៣ ដូចតទៅ ៖

## ក- គោលដៅជាយុទ្ធសាស្ត្ររបស់គណបក្ស

ក្នុងស្មារតីប្រកាន់ខ្ជាប់គតប្រែប្រួលនូវគោលបំណង និងឧត្តមគតិដ៏ថ្លៃថ្លារបស់ខ្លួន និងផ្តើមចេញពីសំណូមពរនៃសភាពការណ៍ទូទៅបច្ចុប្បន្ន គណបក្សប្រជាជនកម្ពុជាពុះពារសម្រេចគោលដៅធំៗជាយុទ្ធសាស្ត្រ ដូចខាងក្រោម ៖

**១**- គោរព ប្រតិបត្តិ ការពាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ការពាររបបរាជានិយម និងរាល់សមិទ្ធផលរបស់ជាតិឲ្យបានស្ថិតស្ថេរជានិរន្តរ៍ លើកកម្ពស់លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ធានាសិទ្ធិមនុស្ស ការគោរពច្បាប់ និងយុត្តិធម៌ក្នុងសង្គម ពង្រឹងឆ្លងសាមគ្គីជាតិ ដើម្បីកសាងប្រទេសប្រកបដោយភាពសុខដុមរមនា រុងរឿងថ្កើងថ្កាន ជាអារ្យប្រទេសដ៏ឧត្តុង្គឧត្តម។

២- រក្សា ការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីឲ្យបានគង់វង្ស ការពារសន្តិភាព ស្ថិរភាព និងសន្តិសុខជាតិយ៉ាងរឹងមាំ ដើម្បីធានាដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមដោយចីរភាព និងការរស់នៅដ៏សុខសាន្តរបស់ប្រជាជន។

៣- កសាងព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដ៏រឹងមាំ និងជឿនលឿនដោយផ្អែកលើច្បាប់ ធានាការអនុវត្តច្បាប់ដោយស្មើភាពសម្រាប់ពលរដ្ឋគ្រប់រូប ពលរដ្ឋម្នាក់ៗមានសិទ្ធិពេញលេញ និងមានកាតព្វកិច្ចចូលរួមយ៉ាងសកម្មក្នុងការកសាង និងការពារមាតុភូមិ រាល់ស្ថាប័នរដ្ឋគ្រប់ថ្នាក់ ទាំងស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការ បំពេញតួនាទី និងភារកិច្ចរបស់ខ្លួនតាមការកំណត់នៃច្បាប់ ប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុតចំពោះប្រជាជនដែលជាម្ចាស់នៃអំណាច ។

៤- បន្តខិតខំអភិវឌ្ឍប្រទេសឲ្យរីកចម្រើនឥតឈប់ឈរលើគ្រប់វិស័យ និងកាន់តែមានមូលដ្ឋានរឹងមាំ សំដៅក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ ដោយប្រកាន់ខ្ជាប់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យមានកំណើនខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន លើកកម្ពស់ការបែងចែកផ្លែផ្កានៃកំណើនដោយសមធម៌ ធានាចីរភាពនៃធនធានធម្មជាតិ និងបរិស្ថាន ប្រជាជនមានចំណេះដឹង និងជំនាញខ្ពស់ មានវប្បធម៌ជ្រៅជ្រះ មានការងារធ្វើកាន់តែប្រសើរ មានសុខភាពមាំមួន មានសេចក្តីស្រឡាញ់ និងសាមគ្គីភាព និងមានជីវភាពរស់នៅយ៉ាងសមរម្យ ថ្លៃថ្នូរ ដោយចាកផុតពីភាពក្រីក្រ ពីគ្រោះអវិជ្ជា ពីជំងឺតម្កាត់នានា ពីការកេងប្រវ័ញ្ច និងពីអំពើហិង្សាគ្រប់រូបភាព ។

៥- អភិវឌ្ឍប្រព័ន្ធគាំពារសង្គមមួយប្រកបដោយបរិយាប័ន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ ដែលធានានូវការផ្តល់ការគាំពារ និងការពង្រីកសមត្ថភាពនៃសមាជិកគ្រប់រូបក្នុងសង្គម ក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច និងភាពងាយរងគ្រោះផ្សេងៗ ដែលកើតឡើងពីការប្រែប្រួលលក្ខខណ្ឌនៃការងារ និងការរស់នៅ ដោយមិនទុកឲ្យប្រជាជនណាម្នាក់មិនទទួលបានការគាំពារសង្គមឡើយ។

៦- កសាងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើររវាងព្រះរាជាណាចក្រកម្ពុជា ជាមួយគ្រប់ប្រទេស និងអង្គការអន្តរជាតិនានាឲ្យកាន់តែរឹងមាំ ដើម្បីជំរុញការអភិវឌ្ឍប្រទេស ជំរុញសមាហរណកម្មកម្ពុជាក្នុងសហគមន៍អន្តរជាតិ ដោះស្រាយរាល់បញ្ហារវាងរដ្ឋ និងរដ្ឋដោយសន្តិវិធី ពង្រឹងកិច្ចការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី ព្រមទាំងផលប្រយោជន៍របស់ប្រជាជនកម្ពុជាទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ហើយចូលរួមយ៉ាងសកម្មចំពោះបុព្វហេតុសន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់ និងពិភពលោក ។

## ខ- គោលនយោបាយធំៗជាអាទិភាព

ដើម្បីសម្រេចគោលដៅជាយុទ្ធសាស្ត្រខាងលើនេះ គណបក្សកំណត់គោលនយោបាយធំៗជាអាទិភាពគឺ :

### ខ.១- ការពារយ៉ាងរឹងមាំឯករាជ្យ សេរីភាព អធិបតេយ្យ បូរណភាពទឹកដី និងសន្តិភាព ដើម្បីធានាការអភិវឌ្ឍប្រទេសជាតិ និងភាពសុខដុមរមនារបស់ប្រជាជន

គណបក្សតម្កល់ខ្ពស់នូវឯករាជ្យ និងអធិបតេយ្យជាតិជាគុណតម្លៃដ៏ឧត្តុង្គឧត្តមបំផុត ដើម្បី

ធានាអត្ថិភាពនៃជាតិ និងជាសសរស្តម្ភដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់សន្តិភាព និងវឌ្ឍនភាពប្រកបដោយកិត្តិយសរបស់ប្រជាជាតិខ្មែរ ។ ប្រវត្តិសាស្ត្របានបង្ហាញយ៉ាងច្បាស់ថា អាស្រ័យដោយការបែក-បាក់ផ្ទៃក្នុងជាតិ បានបើកឱកាសឲ្យពួកបរទេសចូលមកជ្រៀតជ្រែកឈ្លានពានកម្ពុជាបាន ធ្វើឲ្យកម្ពុជាត្រូវបាត់បង់ឯករាជ្យ និងអធិបតេយ្យរបស់ខ្លួន ហើយប្រជាជាតិយើងមានតែការទទួលរងនូវសង្គ្រាម បង្ហូរឈាម ការវិនាសអន្តរាយ និងទុក្ខវេទនារកទីបំផុតគ្មានឡើយ ។ ដើម្បីដណ្តើមយកមកវិញនូវឯករាជ្យ អធិបតេយ្យជាតិ និងសន្តិភាព ប្រជាជនកម្ពុជាបានធ្វើពលិកម្មធំធេងណាស់ នៅក្នុងដំណើរតស៊ូដ៏វែងឆ្ងាយទើបអាចសម្រេចបាន ។ ដូច្នេះ យើងត្រូវថែរក្សាសមិទ្ធផលដ៏វិសេសវិសាលនេះឲ្យស្ថិតស្ថេររឹងមាំជានិច្ច។

ក្នុងស្មារតីនេះគណបក្សប្រជាជនកម្ពុជា បន្តជ្រោងខ្ពស់ទង់មហាសាមគ្គីជាតិនៅក្រោមដំបូលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ សំដៅប្រមូលកម្លាំងប្រជាជាតិទាំងមូល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀត ដើម្បីរួមគ្នាបន្តកសាង និងការពារមាតុភូមិឲ្យសម្រេចបានសមិទ្ធផលកាន់តែធំធេងឡើងថែមទៀត ។ យើងប្រឆាំងដាច់ខាតចំពោះឧបាយកល និងសកម្មភាពឧទ្ទាមរបស់មជ្ឈដ្ឋានណាក៏ដោយ ទោះជាបុគ្គល ជាក្រុម ឬ ជាអង្គការនយោបាយដែលព្យាយាមបំផ្លាញឯកភាពជាតិ បង្កអស្ថិរភាពក្នុងសង្គម បំផ្លាញលទ្ធិប្រជាធិបតេយ្យ ប៉ុនប៉ងធ្វើឲ្យមានការផ្លាស់ប្តូរណាមួយដែលផ្ទុយពីរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ព្រមជាមួយនេះ យើងប្រឆាំងដាច់ខាត និងមិនអនុញ្ញាតឲ្យបរទេសណាមកជ្រៀតជ្រែក រំលោភបំពានលើឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជាឡើយ ដើម្បីការពារសន្តិភាព និងស្ថិរភាពនយោបាយ ការពាររាល់សមិទ្ធផលនៃសង្គមជាតិ ធានាដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមដោយចីរភាព និង ការពារមិនឲ្យកម្ពុជាវិលត្រឡប់ទៅរកគ្រោះមហន្តរាយជាថ្មីម្តងទៀត ។

## ខ.២- លើកកម្ពស់ជីវភាពរបស់ប្រជាជនគ្រប់រូបទាំងខាងសម្ភារៈ និង ស្មារតីឲ្យបានសមរម្យ ប្រកបដោយភាពថ្លៃថ្នូរ

ការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រចាំឆ្នាំជាបន្តបន្ទាប់ក្នុងរយៈពេលពីរទសវត្សកន្លងមកនេះ បានធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាននូវគុណភាពនៃការរស់នៅរបស់ប្រជាជន។ ភាពក្រីក្រត្រូវបានកាត់បន្ថយពី ៥៣,៥% នៅឆ្នាំ ២០០៤ មកនៅប្រមាណ ១៣,៥% នៅឆ្នាំ ២០១៤ ហើយបានបន្តធ្លាក់ចុះថែមទៀតនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ កម្ពុជាបានទទួលចំណាត់ថ្នាក់ជាប្រទេសជោគជ័យបំផុតទី ៤ លើពិភពលោក ក្នុងការកាត់បន្ថយអត្រាភាពក្រីក្រ និងជាប្រទេសឈានមុខគេទាំង៧លើពិភពលោក ក្នុងការកែលម្អសន្ទស្សន៍នៃការអភិវឌ្ឍក្នុងចន្លោះពីឆ្នាំ ១៩៩០ ដល់ ២០១៥។ ប្រការនេះបានបង្ហាញច្បាស់ថា កម្ពុជាមិនគ្រាន់តែមានសេដ្ឋកិច្ចកាន់តែរឹងមាំទេ តែកំណើនក៏កាន់តែមានបរិយា-ប័ន្ន ហើយការបែងចែកផលនៃកំណើន ក៏កាន់តែមានសមធម៌ផងដែរ ។

ក្នុងគោលដៅបន្តលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនឲ្យបានប្រសើរឡើងឥតឈប់ឈរ គណបក្សបន្តចាត់ទុកការកាត់បន្ថយភាពក្រីក្រជាគោលនយោបាយអាទិភាពមួយ ដោយបន្តខិតខំកាត់

បន្ថយភាពក្រីក្រឲ្យបានជាង ១% ក្នុង១ឆ្នាំ ជាមួយនឹងការរាំងស្កាត់មិនឲ្យប្រជាជនដែលបានឆ្លងផុតបន្ទាត់នៃភាពក្រីក្រហើយវិលត្រឡប់ទៅរកភាពក្រីក្រវិញ តែកាន់តែទទួលបានលក្ខខណ្ឌអំណោយផលសម្រាប់ការកែលម្អជីវភាពរបស់ខ្លួន លើមូលដ្ឋានបន្តជំរុញការអភិវឌ្ឍសេដ្ឋកិច្ចទីផ្សារដែលបម្រើឲ្យផលប្រយោជន៍សង្គមទាំងមូល ព្រមទាំងដាក់ចេញ និងពង្រឹងការអនុវត្តគោលនយោបាយសង្គមនានាប្រកបដោយប្រសិទ្ធភាព ដែលឆ្លើយតបពិតប្រាកដទៅនឹងសំណូមពរនៃជីវភាពផ្ទាល់របស់ប្រជាជន។

ក្នុងស្មារតីនេះ គណបក្សនឹងបន្តជំរុញការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៨-២០២៣ ប្រកបដោយភាពប្រាកដនិយម ប្រទាក់ក្រឡាគ្នា និងឈរលើគោលការណ៍ "មិនទុកឲ្យប្រជា-ជនកម្ពុជាណាម្នាក់ស្ថិតនៅក្រៅការអភិវឌ្ឍឡើយ" ដោយដាក់បញ្ចូលក្របខណ្ឌសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពគ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅ ។

បន្តផ្តល់អាទិភាពខ្ពស់ដល់ការអភិវឌ្ឍធនធានមនុស្ស ទឹក ភ្លើង និងផ្លូវ ដែលជាកត្តាដ៏សំខាន់ចាំបាច់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចដោយចីរភាព និងបរិយាប័ន្ន និងការបែងចែកផ្លែផ្កានៃកំណើនដោយសមធម៌ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាជន ។ បន្តពង្រីកបណ្តាលក្ខខណ្ឌចាំបាច់សម្រាប់ធានាឲ្យប្រជាពលរដ្ឋគ្រប់រូបមានការងារធ្វើ ដែលទទួលបានប្រាក់ចំណូលសមរម្យធ្វើឲ្យការរស់នៅមានស្ថិរភាព និងភាពថ្លៃថ្នូរ ។

បន្តអភិវឌ្ឍ និងពង្រឹងប្រព័ន្ធគាំពារសង្គមមួយដែលមានប្រសិទ្ធភាព ចីរភាពហិរញ្ញវត្ថុ និងមានវិសាលភាពគ្របដណ្តប់ ដើម្បីផ្តល់ការគាំពារ និងពង្រឹងសមត្ថភាពរបស់សមាជិកគ្រប់រូបក្នុងសង្គម ក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច ទប់ស្កាត់ កាត់បន្ថយភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសម-ភាព ហើយរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សឲ្យកាន់តែរឹងមាំ ទូលំទូលាយ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ច ។

## ខ.៣- ការពាររបបរាជានិយម លើកស្ទួយលទ្ធិប្រជាធិបតេយ្យ សិទ្ធិ សេរីភាពរបស់ប្រជាជន និងការគោរពច្បាប់

គណបក្សប្រជាជនកម្ពុជា ការពារ និងប្រកាន់ខ្ជាប់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ តាមប្រព័ន្ធនយោបាយប្រជាធិបតេយ្យសេរីពហុបក្សឲ្យស្ថិតស្ថេរជានិច្ចនិរន្តរ៍ ស្របតាមបេសកកម្មជាប្រវត្តិសាស្ត្ររបស់គណបក្ស និងស្របតាមឆន្ទៈរបស់ប្រជាជនកម្ពុជាដែលគោរពស្រឡាញ់ និងលើកតម្កើងអង្គព្រះមហាក្សត្រ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីព្រះអង្គទ្រង់គង់ជាម្លប់ដ៏ត្រជាក់ត្រជុំនៃប្រជាជាតិខ្មែរទាំងមូល និងដើម្បីធានាឯករាជ្យជាតិ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាធានានូវសុខសន្តិភាព ការបង្រួបបង្រួមជាតិ ឯកភាពជាតិ ព្រមទាំងធានានូវសិទ្ធិសេរីភាពរបស់ប្រជាជនរួមគ្នាដង្ហែជុំវិញអង្គព្រះមហាក្សត្រ បន្តកសាងព្រះរាជាណាចក្រកម្ពុជា ជាអារ្យប្រទេសមួយ។ គណបក្សប្រជាជនកម្ពុជាថ្កោលទោស និងប្រឆាំងដាច់ខាតនូវរាល់ទង្វើ និងសកម្មភាពគ្រប់បែបយ៉ាងដែលប៉ះពាល់ ឬរំលោភបំពានលើអង្គព្រះមហាក្សត្រជាទីសក្ការៈ។

បន្តពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ឲ្យចាក់គ្រឹះកាន់តែរឹងមាំពីថ្នាក់ជាតិរហូតដល់មូលដ្ឋាន ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាជនក្នុងការកសាង និងការពារមាតុភូមិ ប្រកបដោយភាពជាម្ចាស់លើជោគវាសនាអនាគតប្រទេសជាតិ ។ ធានាការការពារ និងលើកស្ទួយសិទ្ធិសេរីភាពរបស់ប្រជាជនក្នុងការបង្កើត ការជ្រើសរើស និងការចូលរួមសកម្មភាពនយោបាយក្នុងគណ-បក្សនយោបាយនានា ស្របតាមគោលការណ៍នៃប្រជាធិបតេយ្យ និងនីតិរដ្ឋ។ ការពារ និងគាំទ្រយ៉ាងម៉ឺងម៉ាត់ចំពោះដំណើរការរៀបចំការបោះឆ្នោតតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងសកល និងអសកល ឲ្យបានទៀងទាត់តាមអាណត្តិដែលកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានសុវត្ថិភាព ។

ធានាការការពារ និងលើកស្ទួយសិទ្ធិសេរីភាពគ្រប់បែបយ៉ាងរបស់ប្រជាជន ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិ កតិកាសញ្ញា សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស។ បន្តលើកកម្ពស់ការទទួលខុសត្រូវខាងផ្លូវច្បាប់ក្នុងការគោរព និងផ្តល់តម្លៃដល់ជីវិតមនុស្ស និងសិទ្ធិសេរីភាពរបស់បុគ្គល ដោយប្តេជ្ញាការពារនូវសិទ្ធិមានជីវិតរស់នៅ សិទ្ធិមានលំនៅឋាន សិទ្ធិប្រកបមុខរបរចិញ្ចឹមជីវិត សិទ្ធិទទួលបានការងារសមរម្យ សិទ្ធិធ្វើដំណើរ សិទ្ធិទទួលបានព័ត៌មាន សិទ្ធិទទួលបានការអប់រំ សិទ្ធិទទួលបានការថែទាំសុខភាព និងការព្យាបាលជំងឺ សិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌របស់ប្រទេសជាតិ សេរីភាពក្នុងជំនឿសាសនា ការសម្តែងមតិ ការបង្កើតសហជីព សមាគម អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងអង្គការវិជ្ជាជីវៈផ្សេងៗ ។ ទន្ទឹមនឹងការធានាការពារសិទ្ធិសេរីភាព បន្តពង្រឹង និងជំរុញការបំពេញករណីយកិច្ច កាតព្វកិច្ចនានារបស់ប្រជាជនគ្រប់រូបក្នុងសង្គម ជំរុញឲ្យមានការគោរពច្បាប់ សីលធម៌ សេចក្តីថ្លៃថ្នូរក្នុងសង្គម ព្រមទាំងការធានាការពារមិនឲ្យមានការរំលោភបំពានសិទ្ធិសេរីភាព និងការប្រើប្រាស់សិទ្ធិសេរីភាពប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃ ដើម្បីប្រជាជនបានរស់នៅប្រកបដោយភាពសុខដុមរមនាជាមួយគ្នា ។

ពង្រឹងប្រព័ន្ធយុត្តិធម៌តាមរយៈការបន្តពង្រឹង និងលើកកម្ពស់នីតិរដ្ឋ ដោយធ្វើការពិនិត្យកែលម្អក្របខ័ណ្ឌច្បាប់ និងតាក់តែងច្បាប់ថ្មីៗបន្ថែមទៀត សំដៅឲ្យប្រទេសយើងមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ និងល្អ ស្របតាមការវិវត្តន៍រីកចម្រើនរបស់សង្គម ដើម្បីការពារផលប្រយោជន៍ប្រជាជន និងផលប្រយោជន៍សាធារណៈ។ មន្ត្រីអនុវត្តច្បាប់គ្រប់ៗរូប ត្រូវតែទទួលបានការបណ្តុះបណ្តាល អប់រំ ដើម្បីលើកកម្ពស់សមត្ថភាពក្នុងការបំពេញការងារបម្រើប្រជាជន និងសង្គម ប្រកបដោយមនសិការវិជ្ជាជីវៈ សីលធម៌ ស្អាតស្អំ និងវិន័យក្នុងការងារ។ ពង្រឹងឯករាជ្យភាពរបស់ចៅក្រម និងស្ថាប័នតុលាការគ្រប់ថ្នាក់ ដើម្បីផ្តល់យុត្តិធម៌ដល់ប្រជាជនគ្រប់ៗរូប ។ ជំរុញ និងលើកកម្ពស់ការអប់រំ ផ្សព្វផ្សាយច្បាប់ឲ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយ ដើម្បីឲ្យមានការយល់ដឹងអំពីច្បាប់ និងមានការគោរព អនុវត្តច្បាប់បានត្រឹមត្រូវ និងស្មើភាពគ្នាចំពោះមុខច្បាប់សម្រាប់មនុស្សគ្រប់ៗរូប រួមទាំងរាំងស្កាត់រាល់ទម្រង់នៃការប្រើប្រាស់សិទ្ធិអំណាចបំពានច្បាប់ និទ្ទណ្ឌភាព និងអំពើហិង្សាតាមគ្រប់រូបភាពក្នុងសង្គម ។

## ខ.៤- ពង្រឹងរដ្ឋបាលសាធារណៈនៅគ្រប់ថ្នាក់ ជារដ្ឋបាលរបស់ប្រជាជន និងបម្រើផលប្រយោជន៍របស់ប្រជាជន

បន្តពង្រឹងរដ្ឋបាលសាធារណៈ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជារដ្ឋបាលទំនើប ស្អាតស្អំ និងមានគុណភាព ដើម្បីបម្រើប្រជាជន និងផលប្រយោជន៍សាធារណៈប្រកបដោយប្រសិទ្ធភាពខ្ពស់។ ពង្រឹង និងលើកកម្ពស់សមត្ថភាពស្ថាប័នសាធារណៈគ្រប់ថ្នាក់ ដោយធ្វើការពិនិត្យ កែលម្អរចនាសម្ព័ន្ធ តួនាទី ភារកិច្ច ចំនួនក្របខណ្ឌនៅតាមស្ថាប័ននីមួយៗឲ្យបានសមស្រប ដើរទន្ទឹមនឹងការពង្រឹង និងការលើកកម្ពស់គុណភាព សមត្ថភាពមន្ត្រីរាជការនៅតាមស្ថាប័ននីមួយៗ ប្រកបដោយជំនាញវិជ្ជាជីវៈខ្ពស់ ពង្រឹងប្រព័ន្ធត្រួតពិនិត្យលើលទ្ធផលការងារ ក្រមសីលធម៌វិជ្ជាជីវៈ និងឥរិយាបថរបស់មន្ត្រីរាជការគ្រប់ៗរូបក្នុងការបម្រើផលប្រយោជន៍ប្រជាជន និងផលប្រយោជន៍សាធារណៈ ។ លើកកម្ពស់សមត្ថភាពស្ថាប័នសាធារណៈគ្រប់ថ្នាក់ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាជនគ្រប់មជ្ឈដ្ឋានឲ្យកាន់តែប្រសើរឡើង ទាំងគុណភាព ប្រសិទ្ធភាព និងវិសាលភាព ដោយបង្កិតការផ្តល់សេវាសាធារណៈឲ្យនៅជាប់ជាមួយតម្រូវការនៃការលើកកម្ពស់គុណភាពនៃជីវិតរស់នៅរបស់ប្រជាជន។ បង្កើតយន្តការទទួលដោះស្រាយ និងទទួលព័ត៌មានត្រឡប់ពីប្រជាជនអំពីការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ ដើម្បីធានាឲ្យមានការចូលរួម ការជឿទុកចិត្តពីប្រជាជន និងឆ្លើយតបបានតាមសំណូមពររបស់ប្រជាជនគ្រប់មជ្ឈដ្ឋានក្នុងសង្គម។ ពង្រឹងការទទួលខុសត្រូវ ការដាក់ពិន័យ និងការលើកទឹកចិត្ត ទាំងចំពោះមន្ត្រីទាំងចំពោះស្ថាប័នសាធារណៈក្នុងការបម្រើប្រជាជន។

បង្កើនប្រាក់បៀវត្សជារៀងរាល់ឆ្នាំជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងបង្កើនប្រាក់សោធននិវត្តសម្រាប់និវត្តជន និងអតីតយុទ្ធជនឲ្យមានចីរភាព ដើម្បីធានាការលើកស្ទួយជីវភាពរស់នៅ ព្រមទាំងជំរុញលើកទឹកចិត្តមន្ត្រីរាជការក្នុងការបំពេញតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន។

## ខ.៥- បន្តជំរុញការកែទម្រង់ ដើម្បីអភិបាលកិច្ចល្អ

សន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ដែលបានកែប្រែស្ថានភាពកម្ពុជាពីប្រទេសមួយក្នុងចំណោមប្រទេសក្រីក្របំផុតក្នុងពិភពលោក មកជាប្រទេសមានចំណូលមធ្យមកម្រិតទាប គឺជាសមិទ្ធផលដែលបានមកពីការអនុវត្តប្រកបដោយជោគជ័យនូវគោលនយោបាយកែទម្រង់រដ្ឋដ៏ស៊ីជម្រៅ និងទូលំទូលាយលើមូលដ្ឋាននៃការពង្រឹងអភិបាលកិច្ចល្អនៅគ្រប់ថ្នាក់ និងគ្រប់ផ្នែក។

ដើម្បីឈានឆ្ពោះសម្រេចបាននូវការប្តេជ្ញាចិត្តខាងនយោបាយក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ របៀបវារៈគោលនយោបាយជាអាទិភាពមួយរបស់គណបក្សប្រជាជនកម្ពុជា គឺការបន្តជំរុញដំណើរការកែទម្រង់រដ្ឋដ៏ស៊ីជម្រៅ និងទូលំទូលាយ រួមមាន ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, ការកែទម្រង់ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន, ការកែទម្រង់ការគ្រប់គ្រងដីធ្លី លំនៅឋាន សំណង់ និងការគ្រប់គ្រងទីក្រុង ទីប្រជុំជន ព្រមទាំងវិស័យដទៃៗទៀតឲ្យមានភាពប្រទាក់ក្រឡាគ្នា និងមានប្រសិទ្ធភាពខ្ពស់ ដោយឈរលើគោលការណ៍

អភិបាលកិច្ចល្អ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព និងដើម្បីធានាឲ្យប្រជាជនកម្ពុជាគ្រប់ៗរូប ទទួលបានអត្ថប្រយោជន៍ប្រកបដោយសមធម៌ពីការអភិវឌ្ឍលើគ្រប់វិស័យក្នុងសង្គម។

គណបក្សប្រកាន់ជំហរម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមរយៈការពង្រឹង និងការបង្កើនវិធានការស្នូលទាំង៣ គឺការអប់រំ ការបង្ការ និងទប់ស្កាត់ និងការបង្ក្រាបបទល្មើសបញ្ជូនទៅតុលាការ ដើម្បីធានាការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈគ្រប់យ៉ាង ការពង្រឹងអភិបាលកិច្ចល្អ និងនីតិរដ្ឋ ព្រមទាំងរក្សាបានភាពស្អាតស្អំ យុត្តិធម៌ និងកិត្តិយសរបស់មន្ត្រីសាធារណៈ។

## ខ.៦-ជំរុញការអភិវឌ្ឍសង្គម សេដ្ឋកិច្ចឲ្យមានការរីកចម្រើនប្រកបដោយចីរភាព សមធម៌ និងបរិយាប័ន្ន

### ខ.៦.១- ការគ្រប់គ្រងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ

#### ១- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចខ្ពស់

សេដ្ឋកិច្ចកម្ពុជាកំពុងតែស្ថិតនៅក្នុងដំណាក់កាលមួយដ៏សំខាន់ ដែលទាមទារឲ្យមានការធានានូវស្ថិរភាពនៅក្នុងបរិបទចលនការនៃការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងការប្រែប្រួលយ៉ាងខ្លាំងនូវនិម្មាបនកម្មសេដ្ឋកិច្ច ពាណិជ្ជកម្ម និងភូមិសាស្ត្រនយោបាយទាំងក្នុងកម្រិតតំបន់ និងពិភពលោក ។ ទន្ទឹមនេះ ត្រូវខិតខំសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ដើម្បីឈានទៅសម្រេចចក្ខុវិស័យជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។ ក្នុងបរិការណ៍នេះគោលនយោបាយជាអាទិភាពរួមមាន ៖

- ពង្រឹងយន្តការគ្រប់គ្រងហានិភ័យ និងវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងកិច្ចអន្តរាគមន៍ក្នុងសេដ្ឋកិច្ច និងពង្រឹងគោលនយោបាយរូបិយវត្ថុ ដើម្បីរក្សាអត្រាអតិផរណាឲ្យស្ថិតក្នុងកម្រិតទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព និងអាចគ្រប់គ្រងបាន។
- បន្តធ្វើពិពិធកម្មមូលដ្ឋាននៃកំណើនរយៈពេលវែងដែលមានភាពប្រទាក់ក្រឡាគ្នា ដូចជា កសិកម្ម ទេសចរណ៍ ឧស្សាហកម្ម សំណង់ និងអចលនទ្រព្យជាដើម ដែលជាយុទ្ធសាស្ត្រកំណើនរបស់ជាតិឲ្យមានសន្ទុះកាន់តែខ្លាំងឡើង និងឆាប់រហ័ស។
- ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងក្នុងស្រុក ដើម្បីបង្កើនការផលិត និងលើកកម្ពស់ផលិតភាពបន្ថែមទៀត និងខិតខំស្វែងរកប្រភពទុនថ្មីៗសម្រាប់វិស័យឯកជន ពិសេសការអភិវឌ្ឍទីផ្សារមូលបត្រ។
- ជំរុញការវិនិយោគលើវិស័យអាទិភាព ដូចជា កសិកម្ម ប្រព័ន្ធធារាសាស្ត្រ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដឹកជញ្ជូន និងថាមពលជាដើម។
- អនុវត្ត និងធ្វើបច្ចុប្បន្នកម្មគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។
- បន្តអភិវឌ្ឍ និងពង្រឹងក្របខ័ណ្ឌគ្រប់គ្រងស្ថិរភាពហិរញ្ញវត្ថុ ដើម្បីធានាបាននូវការអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយចីរភាព និងភាពធន់ខ្ពស់។

## ២- រក្សាឲ្យបាននូវចីរភាពថវិកា

ថវិកាជាតិត្រូវមានចីរភាព ដើម្បីគាំទ្រស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច រក្សាកំណើន និងការអភិវឌ្ឍ ពិសេសកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរបស់ប្រជាជន ។ ក្នុងន័យនេះ ត្រូវប្រកាន់ខ្ជាប់នូវគោលនយោបាយអាទិភាពគឺ ៖

- កែលម្អ និងពង្រឹងការអនុវត្តគោលនយោបាយថវិកា ដោយផ្ដោតលើរចនាសម្ព័ន្ធពន្ធ ការពង្រឹងរដ្ឋបាលប្រមូលចំណូល ការពង្រឹងសមត្ថភាពស្ថាប័នត្រៀមសម្រាប់សេដ្ឋកិច្ចឌីជីថល និងពាណិជ្ជកម្មលើប្រព័ន្ធអ៊ីនធើណេត ។

- បន្តពង្រឹងការអនុវត្តកម្មវិធីគ្រប់គ្រងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញការប្រមូលចំណូលជាតិ បន្តវិចារណកម្មចំណាយឲ្យចំទិសដៅតាមរយៈការវិភាជ និងពង្រឹងប្រសិទ្ធភាពចំណាយក្នុងវិស័យសំខាន់ៗដូចជា អប់រំ សុខាភិបាល កសិកម្ម ដឹកជញ្ជូន និងបច្ចេកវិទ្យាជាដើម ។

- បន្តគ្រប់គ្រងបំណុលសាធារណៈឲ្យមានប្រសិទ្ធភាព ស្ថិតក្នុងកម្រិតទាប និងអាចគ្រប់គ្រងបាន ដែលធានាបាននូវលទ្ធភាពបង់សេវាបំណុល រួមចំណែកទ្រទ្រង់ចីរភាពកំណើនរយៈពេលវែង និងបង្កើនផលិតភាពសេដ្ឋកិច្ច ។

## ៣- បង្កើនបរិយាប័ន្ននៃកំណើនសេដ្ឋកិច្ច

ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ កម្ពុជាត្រូវបង្កើនលំហបរិយាប័ន្នដែលគួរអង្គក្នុងសង្គម ពិសេសប្រជាជនដែលក្រីក្រ ជួបការលំបាក និងមិនអាចជួយខ្លួនឯងបាន ត្រូវទទួលបានឱកាស និងមានលទ្ធភាពចូលរួម និងទទួលផលពីកំណើន ដើម្បីទទួលបាននូវការគាំពារ និងការការពារខ្លួន ។ ក្នុងន័យនេះ គោលនយោបាយជាអាទិភាពរួមមាន ៖

- អនុវត្តគោលនយោបាយជាតិគាំពារសង្គម គោលនយោបាយជាតិស្ដីពីមនុស្សវ័យចាស់ ២០១៧-២០៣០ ការផ្ដល់ឥណទាន និងធានារ៉ាប់រងសម្រាប់គាំទ្រវិស័យកសិកម្ម ព្រមទាំងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់ដែលរួមចំណែកដល់ការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន។

- បន្តអភិវឌ្ឍសំណាញ់សុវត្ថិភាពសង្គម និងសេវាសុខុមាលភាព ការតភ្ជាប់បណ្ដាញអគ្គិសនី និងការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ព្រមទាំងពង្រីកឱកាសក្នុងការទទួលបានសេវាសុខភាព អាហារូបត្ថម្ភ និងការអប់រំសម្រាប់គ្រួសារក្រីក្រ។

## ៤- ពង្រឹងសមត្ថភាពប្រកួតប្រជែង

សមត្ថភាពប្រកួតប្រជែងខ្ពស់ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ គឺជាកត្តាចាំបាច់សម្រាប់កម្ពុជា ក្នុងការបន្តរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ។ ក្នុងន័យនេះ ត្រូវអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់សម្រាប់គាំទ្រការអភិវឌ្ឍ ពង្រឹងការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទ វិនិយោគលើប្រព័ន្ធឡូជីស្ទីក និងផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដទៃទៀត ពិសេសកាត់បន្ថយថ្លៃអគ្គិសនី និងថ្លៃដឹកជញ្ជូន ។ ជាមួយនេះ ត្រូវអភិវឌ្ឍធនធានមនុស្ស ជំនាញ មូលដ្ឋានចំណេះដឹង បច្ចេកទេស និងវិទ្យាសាស្ត្រ ជំរុញការផ្ទេរបច្ចេកវិទ្យាទំនើប ឆ្លាតវៃ និងនវានុវត្តន៍ ជំរុញលើកទឹកចិត្តដល់ការវិនិយោគ និងធ្វើទំនើបកម្មកសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម រួមទាំង

លើកទឹកចិត្ត និងអភិវឌ្ឍឧស្សាហកម្មថ្មីៗ ដែលបង្កើនផលិតភាព គុណភាព ផ្តល់តម្លៃបន្ថែមខ្ពស់ និងមានភាពច្នៃប្រឌិត ។

## ខ.៦.២- ការពង្រឹងភាពជាដៃគូក្នុងការអភិវឌ្ឍ

បន្តពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ និងការចូលរួមរបស់តួអង្គអភិវឌ្ឍន៍ទាំងអស់ ដោយស្មើភាព និងស្មើសិទ្ធិ និងឈរលើគោលការណ៍នៃការគោរពភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ បន្តពង្រឹងយន្តការពិគ្រោះយោបល់ស្តីពីភាពជាដៃគូដែលមានស្រាប់ ដែលជាវេទិកាសម្រាប់ពិភាក្សាលើប្រធានបទនានាពាក់ព័ន្ធនឹងការអភិវឌ្ឍប្រទេសជាតិ។

ក្នុងបរិការណ៍ថ្មីរបស់កម្ពុជា ពិសេសមុនពេលកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ហិរញ្ញប្បទានសហប្រតិបត្តិការនៅតែមានតួនាទីសំខាន់ក្នុងរយៈពេលខ្លី និងមធ្យមក្នុងការចូលរួមចំណែកគាំទ្រការអភិវឌ្ឍប្រទេស ពិសេសបំពេញតម្រូវការចំណាយអាទិភាពរបស់រាជរដ្ឋាភិបាល សំដៅឈានទៅសម្រេចកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្នុងស្មារតីនេះ ត្រូវខិតខំបន្តកៀរគរ និងលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ដោយត្រូវរក្សាហានិភ័យ និងបន្ទុកសេវាបំណុលឲ្យនៅកម្រិតអប្បបរមាដោយប្រុងប្រយ័ត្នខ្ពស់បំផុត និងអាចគ្រប់គ្រងបាន ស្របតាមគោលនយោបាយថវិកា គោលនយោបាយរូបិយវត្ថុ ស្ថានភាពហិរញ្ញប្បទាន និងតម្រូវការចាំបាច់ជាអាទិភាព។ ជាមួយនេះ ត្រូវបន្តពង្រឹងភាពប្រុងប្រយ័ត្នខ្ពស់ក្នុងការគ្រប់គ្រងបំណុលសាធារណៈឲ្យមានប្រសិទ្ធភាព តាមរយៈការអនុវត្តដោយហ្មត់ចត់ និងខ្ជាប់ខ្ជួននូវគោលការណ៍គន្លឹះទាំង៤ រួមមាន (១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន (២) ត្រូវខ្ចីឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់ (៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច និង (៤) ត្រូវប្រើប្រាស់ឥណទានទាំងនោះប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិខ្ពស់បំផុត។

បន្តពង្រឹងភាពជាដៃគូជាមួយសង្គមស៊ីវិល សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងក្របខណ្ឌច្បាប់ដើម្បីលើកកម្ពស់នីតិរដ្ឋ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការចូលរួមផ្តល់ផលប្រយោជន៍ពិតប្រាកដដល់កិច្ចអភិវឌ្ឍន៍កម្ពុជា ។

## ខ.៦.៣- ការអភិវឌ្ឍវិស័យឯកជន

### ១- ការពង្រឹងវិស័យឯកជន ជំរុញវិនិយោគ និងធុរកិច្ច

គណបក្សប្រជាជនកម្ពុជាចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ពិសេសការអភិវឌ្ឍវិស័យឧស្សាហកម្ម សំដៅធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មប្រើពលកម្មច្រើន ទៅជាឧស្សាហកម្មផ្អែកលើសមត្ថភាពជំនាញ។ ក្នុងន័យនេះ គោលនយោបាយជាអាទិភាព រួមមាន ៖

- ទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស និងវិនិយោគក្នុងស្រុក រួមទាំងសហគ្រាសធុនតូច និងមធ្យមលើគ្រប់វិស័យ ពិសេសឧស្សាហកម្មថ្មីៗ ដូចជា គ្រឿងអេឡិកត្រូនិក គ្រឿងបង្គុំ និងការកែច្នៃម្ហូបអាហារ ជាដើម ដើម្បីធ្វើពិពិធកម្មឧស្សាហកម្ម ផ្ទេរបច្ចេកវិទ្យា និងបង្កើតតម្លៃបន្ថែម ការងារ មុខរបរ

និងប្រាក់ចំណូល។

- បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអនុវត្តវិធានការនានាសំដៅកាត់បន្ថយថ្លៃដឹកជញ្ជូន និងថ្លៃអគ្គិសនី ព្រមទាំងការជំរុញការរៀបចំកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលឆ្លើយតបនឹងតម្រូវការទីផ្សារ។

- ពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគ និងធុរកិច្ច តាមរយៈការបន្តកែលម្អក្របខណ្ឌគតិយុត្ត ក្របខណ្ឌអភិបាលកិច្ច និងប្រសិទ្ធភាពនៃស្ថាប័នសាធារណៈពាក់ព័ន្ធ ព្រមទាំងកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តយន្តការច្រកចេញចូលតែមួយ និងការលុបបំបាត់ចំណាយក្រៅផ្លូវការ ដើម្បីឲ្យក្លាយជាយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទាក់ទាញវិនិយោគ។

- ពង្រឹងអភិក្រមបើកចំហសម្រាប់ការអភិវឌ្ឍវិស័យឯកជន និងទាក់ទាញវិនិយោគសំដៅពង្រីកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិ។

- កសាងអភិបាលកិច្ចសាជីវកម្មល្អ រួមជាមួយនឹងច្បាប់វិនិយោគ ព្រមទាំងវិធានការច្បាប់ពាក់ព័ន្ធដទៃទៀត សំដៅលើកទឹកចិត្តសមស្របនឹងចំគោលដៅដែលឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍរយៈពេលវែង ។

- ជំរុញការចូលរួមទទួលខុសត្រូវផ្នែកសង្គម និងបរិស្ថានរបស់វិស័យឯកជនក្នុងសកម្មភាពសង្គមផ្សេងៗ ដូចជា ការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល ការការពារបរិស្ថាន និងសកម្មភាពមនុស្សធម៌ផ្សេងៗ ដើម្បីធានាចីរភាពនៃការអភិវឌ្ឍ។

## ២- ការអភិវឌ្ឍឧស្សាហកម្ម សិប្បកម្ម និងសហគ្រាសធុនតូច និងមធ្យម

-វិស័យឧស្សាហកម្ម សិប្បកម្ម និងសហគ្រាសធុនតូច និងមធ្យម ជាអាទិភាពសំខាន់នៃយុទ្ធសាស្ត្រកំណើន ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ការជំរុញពិពិធកម្មសេដ្ឋកិច្ច និងការកែសម្រួលរចនាសម្ព័ន្ធស៊ីជម្រៅ។ ក្នុងស្មារតីនេះ ទន្ទឹមនឹងការត្រៀមចូលរួមជាបណ្តើរៗក្នុងចរន្តសកលនៃបដិវត្តន៍ឧស្សាហកម្មទី ៤ គណបក្សនឹងជំរុញការបង្កើតកម្រងឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗសំដៅអភិវឌ្ឍតំបន់ទាំងនោះឲ្យឈានដល់កម្រិតស្តង់ដារអន្តរជាតិលើគ្រប់ទិដ្ឋភាព រួមមាន ប្រព័ន្ធគ្រប់គ្រង មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្ត និងវិធានការគាំទ្រឡូជីស្ទិកជាក់ស្តែងផ្សេងទៀត ។ ជាមួយនេះ ត្រូវជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗ ឱ្យមានបទដ្ឋានខ្ពស់ ដោយប្រើយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន។

- ជំរុញការអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស ដោយរៀបចំផែនការសម្រាប់ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងនិយ័តកម្ម ព្រមទាំងយន្តការគ្រប់គ្រងចាំបាច់នានា ដែលនឹងផ្តល់សិទ្ធិអំណាច និងយុត្តាធិការពេញលេញសម្រាប់ការកៀរគរ ទាក់ទាញ និងប្រមូលផ្តុំនូវប្រភពធនធានបញ្ញាញាណសកម្មភាពធុរកិច្ច និងវិនិយោគ ដើម្បីអភិវឌ្ឍខេត្តនេះឱ្យទៅជាប៉ូលសេដ្ឋកិច្ចសំខាន់មួយ និងជាមជ្ឈ-មណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ស្របតាមទស្សនទាននៃការអភិវឌ្ឍប្រកបដោយ

ចីរភាព និងមានតុល្យភាពបរិស្ថាន ព្រមទាំងប្រែក្លាយជា "ទីក្រុងឧស្សាហកម្មបៃតងអាស៊ាន" នាពេលអនាគត ។

- បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញ និងលើកកម្ពស់ភាពប្រកួតប្រជែងសហគ្រាស ព្រមទាំងរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ដោយកំណត់យកមុខសញ្ញាសហគ្រាសដែលមានសក្តានុពលក្នុងការនាំចេញ ការអភិវឌ្ឍផលិតផលថ្មី ការតភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ ការតភ្ជាប់ខ្សែចង្វាក់តម្លៃ និងការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ។ បន្ថែមលើនេះ អភិវឌ្ឍតំបន់ជុំវិញរាជធានីភ្នំពេញឱ្យក្លាយជាតំបន់ឧស្សាហកម្មប្រមូលផ្តុំ ដោយមានផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ និងបែងចែករវាងតំបន់ឧស្សាហកម្ម និងតំបន់និវេសនដ្ឋាន ឬទីប្រជុំជន រួមទាំងដាក់ចេញនូវផែនការរយៈពេលវែងសម្រាប់ប្រែក្លាយរាជធានីភ្នំពេញទៅជាមជ្ឈមណ្ឌលរដ្ឋបាល ឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍ ។

- លើកកម្ពស់គុណភាពនៃការផលិតដល់សហគ្រាសធុនតូច និងមធ្យម និងហាងសិប្បកម្ម ដោយផ្អែកលើគោលការណ៍ **ស៥** "សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ស្តង់ដារ ស្ថិតស្ថេរ" ព្រមទាំងលើកកម្ពស់ការបង្កើតតក្កកម្ម និងបណ្តុះបណ្តាលកម្មសិទ្ធិឧស្សាហកម្ម។ ពង្រឹងសមត្ថភាពសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក និងបង្កើនគុណភាព សោភ័ណភាព និងផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ ដើម្បីផ្សារភ្ជាប់ និងទាញយកផលប្រយោជន៍ពីសក្តានុពលសហគ្រាស និងវិនិយោគបរទេសធំៗ។ ជាមួយនេះ បន្តលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យឧស្សាហកម្ម សិប្បកម្ម និងសហគ្រាសធុនតូច និងមធ្យម កែលម្អខ្សែចង្វាក់ផលិតកម្ម ពង្រឹងគុណភាព ធ្វើពិពិធកម្មផលិតកម្ម និងទីផ្សារ ការពារបរិស្ថាន និងសុវត្ថិភាពអ្នកប្រើប្រាស់ ។

- ពង្រឹងយន្តការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងហាងសិប្បកម្ម ដើម្បីរៀបចំការចុះបញ្ជី ការគ្រប់គ្រង និងការតាមដានវឌ្ឍនភាពនៃវិស័យនេះ ពិសេសរៀបចំគោលនយោបាយ និងផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ។ បន្តពង្រឹងច្រកចេញចូលតែមួយ និងបញ្ជរសេវាចុះបញ្ជីក្រោមដំបូលតែមួយ ដើម្បីបង្កភាពងាយស្រួលដល់ការរៀបចំបែបបទក្នុងការសុំបង្កើតមូលដ្ឋានផលិតកម្ម សំដៅកែសម្រួលបរិស្ថានធុរកិច្ច វិនិយោគឱ្យកាន់តែល្អប្រសើរ ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗដើម្បីចែករំលែកចំណេះដឹង ធ្វើការតស៊ូមតិ ការពារសិទ្ធិ និងផលប្រយោជន៍ និងពង្រឹងទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងឯកជន សំដៅទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ។

- កសាងធនធានមនុស្សដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មឱ្យមានភាពរឹងមាំ និងជីវភាព ដោយផ្តល់ការហ្វឹកហ្វឺនលើជំនាញឯកទេសសម្រាប់ដោះស្រាយកង្វះខាតជំនាញក្នុងវិស័យអាទិភាព តាមរយៈបង្កើនអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាលវិស្វករ និងអ្នកបច្ចេកទេស ។ ជាមួយនេះ ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម និងហាងសិប្បកម្ម សម្រាប់ការបណ្តុះបណ្តាល និងការវិនិយោគលើគ្រឿងម៉ាស៊ីន ឬ បរិក្ខារផលិតកម្ម ព្រមទាំងការលើកទឹកចិត្តផ្សេងៗទៀត

ដោយផ្សារភ្ជាប់លក្ខខណ្ឌនៃការផលិតវត្ថុធាតុដើមក្នុងស្រុក ការលើកកម្ពស់គុណភាពផលិតផល និង ទំនើបកម្មនៃខ្សែចង្វាក់ផលិតកម្ម សំដៅផ្សារភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ។

## ៣- ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ

ទិសដៅជាអាទិភាពនៃវិស័យហិរញ្ញវត្ថុ និងធនាគារ គឺសម្រេចឲ្យបាននូវប្រព័ន្ធហិរញ្ញវត្ថុមួយ ប្រកបដោយប្រសិទ្ធភាព ដោយផ្អែកលើគោលការណ៍ទីផ្សារ ហើយមានលក្ខណៈពិពិធភាព រឹងមាំ និង បរិយាប័ន្នដែលផ្តល់លទ្ធភាពទូលំទូលាយក្នុងការបំពេញតម្រូវការសេវាហិរញ្ញវត្ថុ ក្នុងគោលបំណងទ្រ ទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងប្រសិទ្ធភាព កាត់បន្ថយភាពក្រីក្រ និងបង្កើនចំណូល ប្រជាជន ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុង តំបន់។ ដើម្បីសម្រេចបាននូវទិសដៅនេះ គោលនយោបាយជាអាទិភាព រួមមាន ៖

- បន្តអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពទន់ភ្លន់និងប្រុងប្រយ័ត្ន និងបន្តសិក្សា ពីឧបករណ៍គោលនយោបាយរូបិយវត្ថុដែលផ្អែកលើទីផ្សារបន្ថែមទៀត ដើម្បីរក្សាស្ថិរភាពថ្លៃ តាមរយៈ ការពង្រឹងស្ថិរភាពអត្រាអតិផរណាឱ្យស្ថិតក្នុងកម្រិតទាបអាចគ្រប់គ្រងបាន រក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងតម្លៃប្រាក់រៀល និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងសេដ្ឋកិច្ចដោយសន្សឹមៗ។
- បន្តពង្រីកតួនាទីនៃវិស័យធនាគារ ដើម្បីកៀរគរធនធានហិរញ្ញវត្ថុក្នុងស្រុកសម្រាប់បំពេញ តម្រូវការសេដ្ឋកិច្ចឱ្យកាន់តែរីកចម្រើនឆាប់រហ័ស។ ស្វែងរកប្រភពទុនដែលមានតម្លៃទាប និងសិក្សា ពីកត្តារួមផ្សំទាំងឡាយដែលធ្វើឱ្យថ្លៃដើមនៃទុនមានកម្រិតខ្ពស់ និងរិះរកមធ្យោបាយដើម្បីបញ្ចុះអត្រា ការប្រាក់ដោយគោរពតាមយន្តការទីផ្សារ។
- បន្តអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ដើម្បីធានាថា ប្រជាជនកាន់តែច្រើន មានលទ្ធភាពទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុក្នុងការវិនិយោគ ពង្រីកអាជីវកម្ម បង្កើតមុខរបរ លើកកម្ពស់ជីវភាព និងកាត់បន្ថយភាពក្រីក្រ។
- ពង្រឹងក្របខណ្ឌច្បាប់ បទបញ្ញត្តិ និងការត្រួតពិនិត្យលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋានបង្ការហានិភ័យ និងការប្រមើលមើលទៅមុខ តាមរយៈការដាក់ឱ្យអនុវត្ត ធ្វើ បច្ចុប្បន្នកម្ម និងពិនិត្យឡើងវិញនូវបទបញ្ញត្តិជាធរមានទាំងឡាយឱ្យស្របតាមការអនុវត្តល្អប្រសើរជា អន្តរជាតិ (ឧត្តមានុវត្តន៍អន្តរជាតិ) ដើម្បីពង្រឹងប្រព័ន្ធធនាគារកម្ពុជាឱ្យកាន់តែរឹងមាំ ប្រសិទ្ធភាព និង អាចវិវត្តន៍តាមទាន់ស្ថានភាពទីផ្សារ ព្រមទាំងធានាបានស្ថិរភាពហិរញ្ញវត្ថុ។
- បន្តអភិវឌ្ឍប្រព័ន្ធទូទាត់ និងបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យកាន់តែសម្បូរបែប និងជឿនលឿនស្រប តាមបច្ចេកវិទ្យាថ្មីៗ ដើម្បីលើកកម្ពស់ប្រតិបត្តិការធនាគារឱ្យកាន់តែទំនើប មានប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃសមរម្យ ឆ្លើយតបទៅនឹងតម្រូវការនៃការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងការធ្វើសមាហរណកម្មនៅ ក្នុងអាស៊ាន និងក្នុងតំបន់ ។
- ពង្រឹងយន្តការបង្ការនិងគ្រប់គ្រងវិបត្តិដែលអាចកើតឡើងជាយថាហេតុ តាមរយៈការលើក កម្ពស់យន្តការពង្រឹង តាមដាន វិភាគ និងវាយតម្លៃហានិភ័យចំពោះស្ថិរភាពហិរញ្ញវត្ថុ។

- រួមចំណែកក្នុងការជំរុញសមាហរណកម្មវិស័យហិរញ្ញវត្ថុនៅក្នុងតំបន់ ដើម្បីទាញយកផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈគំនិតផ្តួចផ្តើម និងការគាំទ្រនានាថ្នាក់តំបន់ ដូចជាការពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុ ការកៀរគរធនធានហិរញ្ញវត្ថុ និងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ក្នុងក្របខ័ណ្ឌអាស៊ាន និងអាស៊ាន+៣ ជាដើម។

- ពង្រីកការផ្តល់សេវាហិរញ្ញវត្ថុខ្នាតតូច ជាពិសេស សេវាឥណទានទៅដល់តំបន់ជនបទ ប្រជាពលរដ្ឋដែលមានចំណូលទាប និងសហគ្រាសធុនតូចក្នុងអត្រាការប្រាក់មួយទាបសមរម្យ។ ក្នុងស្មារតីនេះ បន្តយកចិត្តទុកដាក់ការត្រួតពិនិត្យ និងដាក់ចេញបទបញ្ញត្តិសមស្រប ដើម្បីប្រមូលប្រតិបត្តិករឥណទានក្រៅប្រព័ន្ធឱ្យចូលមកក្នុងប្រព័ន្ធ តម្រូវឱ្យគ្រឹះស្ថាន និងប្រតិបត្តិករឥណទានធ្វើប្រតិបត្តិការប្រកបដោយភាពត្រឹមត្រូវ សុចរិត មានតម្លាភាព និងភាពប្រកួតប្រជែង ព្រមទាំងផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ និងក្នុងគោលដៅលើកកម្ពស់កម្រិតជីវភាព ។

- បន្តពង្រីកគោលការណ៍គាំពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ដោយកំណត់ច្បាស់ពីលក្ខខណ្ឌនានាចំពោះការផ្តល់ និងទទួលឥណទាន ការផ្សព្វផ្សាយពាណិជ្ជកម្ម នីតិវិធីប្តឹងនិងតវ៉ា ក៏ដូចជាការផ្តល់ព័ត៌មានពេញលេញនិងត្រឹមត្រូវដល់អ្នកខ្ចី ជាពិសេសការគណនាអត្រាការប្រាក់ កម្រៃសេវា និងនីតិវិធីប្រមូលបំណុល។

- លើកកម្ពស់កិច្ចការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការពង្រឹងក្របខណ្ឌច្បាប់និងបទបញ្ញត្តិទាក់ទងនានា ការបង្កើនសមត្ថភាពវិភាគ តាមដាន និងត្រួតពិនិត្យ ព្រមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធ និងដៃគូអន្តរជាតិក្នុងការផ្លាស់ប្តូរព័ត៌មាន និងការចាត់វិធានការចាំបាច់នានា សំដៅធានាឱ្យប្រទេសកម្ពុជាមានសុវត្ថិភាព មិនមែនជាគោលដៅនៃបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

## ខ.៦.៤- ការអភិវឌ្ឍវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ ពាណិជ្ជកម្ម ការគ្រប់គ្រងដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

### ១- ការអភិវឌ្ឍវិស័យកសិកម្ម

- ជំរុញកំណើនកសិកម្មដោយបន្តធ្វើទំនើបកម្មវិស័យកសិកម្មដោយចីរភាព កាន់តែមានភាពវៃឆ្លាត ធន់ជាមួយការប្រែប្រួលអាកាសធាតុ មានប្រសិទ្ធភាពខ្ពស់ និងមានឧត្តមភាពប្រកួតប្រជែងខ្លាំង ដើម្បីធានាសន្តិសុខស្បៀងប្រកបដោយសុវត្ថិភាព និងអាហារូបត្ថម្ភគ្រប់គ្រាន់ កាត់បន្ថយជាអតិបរមានូវការលំបាករបស់ប្រជាកសិករក្នុងការប្រកបរបរកសិកម្ម ព្រមទាំងធ្វើឱ្យវិស័យកសិកម្មក្លាយជាសសរទ្រូងដ៏រឹងមាំមួយក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ជាមូលដ្ឋានគន្លឹះដ៏សំខាន់នៃការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព ហើយរួមចំណែកដល់ការលើកកម្ពស់គុណភាពបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដី ព្រៃឈើ ទឹក និងជលផលផងដែរ។

- បន្តអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពនានា ដើម្បីបញ្ចប់ភាពអត់ឃ្លាន លើកកម្ពស់សន្តិសុខស្បៀង ធ្វើឲ្យប្រសើរឡើងអាហារូបត្ថម្ភ និងការអភិវឌ្ឍកសិកម្មដោយចីរភាព និង

រៀបចំទិវាជាតិអាហារូបត្ថម្ភជារៀងរាល់ឆ្នាំ ដើម្បីបង្កើនការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃអាហារូបត្ថម្ភ ។

- លើកកម្ពស់ការអនុវត្តកសិកម្មចម្រុះ ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកទេសសមស្រប បច្ចេកវិទ្យាវៃឆ្លាត និងនវានុវត្តន៍ថ្មៗប្រឌិត សំដៅបង្កើនផលិតភាព គុណភាព សុវត្ថិភាព និងធ្វើពិពិធកម្មកសិកម្ម ដែលផ្តោតទៅលើដំណាំស្រូវ និងដំណាំមានតម្លៃខ្ពស់ ការចិញ្ចឹមសត្វយកសាច់ ទឹកដោះ ស៊ុត និងការធ្វើវារីវប្បកម្ម កាត់បន្ថយថ្លៃចំណាយ និងជំរុញការចូលលក់លើទីផ្សារទាំងក្នុងស្រុក និងក្រៅស្រុក សម្រាប់ផលិតផលកសិកម្មកម្ពុជាគ្រប់ប្រភេទ ។

- ជំរុញការអភិវឌ្ឍសហគ្រាសកសិកម្មខ្នាតតូច និងមធ្យមនៅតាមតំបន់សេដ្ឋកិច្ចពិសេស និងមូលដ្ឋានឃុំ ភូមិ ទន្ទឹមនឹងការជំរុញលើកទឹកចិត្តប្រជាកសិករ រួមសាមគ្គីគ្នាបង្កើតជាសហគមន៍កសិកម្ម រួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្មដើម្បីប្រមូលផ្តុំការផលិតឱ្យមានទំហំសេដ្ឋកិច្ចសម្រាប់ធ្វើពាណិជ្ជកម្ម និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចរចាអំពីថ្លៃកសិផលឲ្យបានសមស្រប ព្រមទាំងទទួលបានការគាំទ្រកាន់តែប្រសើរអំពីសេវាបច្ចេកទេស និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព (មានចំណូលកាន់តែច្រើន តម្លៃចំណាយកាន់តែទាប និងផលចំណេញកាន់តែខ្ពស់) ។

- បន្តអនុវត្តគោលនយោបាយពាណិជ្ជកម្មបើកចំហពង្រីកទីផ្សារកសិផល ជាមួយនឹងការបង្កើតឱ្យមានកម្មវិធី "ភាពជាដៃគូពហុភាគីក្នុងកសិធុរកិច្ច" កាន់តែទូលំទូលាយរវាងប្រជាកសិករជាក្រុមអ្នកផលិតជាមួយក្រុមហ៊ុនឯកជន តាមរយៈការបន្តពង្រឹងពង្រីកការអនុវត្ត "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" ដោយមានការចូលរួមជួយសម្របសម្រួល និងគាំទ្រពីក្រសួងស្ថាប័នជំនាញពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលជំនាញ សំដៅផ្សារភ្ជាប់ប្រជាកសិករជាមួយទីផ្សារ និងធានាទីផ្សារសម្រាប់ផលិតផលកសិកម្ម ដោយផ្លាស់ប្តូរពីការផលិតតាមគ្នា ឬតាមឮគេថា មកជាការផលិតតាមតម្រូវការទីផ្សារជាក់ស្តែង ។ ក្រុមហ៊ុនឯកជនជាទីផ្សារទទួលទិញផលិតផលកសិកម្មពីប្រជាកសិករ និងក៏ជាទីផ្សារផ្គត់ផ្គង់ដើមទុន ការធានារ៉ាប់រង និងធាតុចូលកសិកម្មដែលមានគុណភាពពិតប្រាកដ និងមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ដូចជា ៖ គ្រឿងយន្តកសិកម្ម ម៉ាស៊ីនកសិកម្ម ឧបករណ៍កសិកម្ម ពូជសុទ្ធល្អ ជីកសិកម្ម ថ្នាំកសិកម្ម និងបសុឱសថ ។ល។

- បន្តអនុវត្តគោលនយោបាយមិនយកពន្ធ លើការនាំចូលគ្រឿងយន្តកសិកម្ម ឧបករណ៍កសិកម្ម គ្រឿងបន្លាស់ ឧបករណ៍បរិក្ខារផ្តល់ថាមពលកកើតឡើងវិញ គ្រាប់ពូជដំណាំ ពូជសត្វ ជីកសិកម្ម ថ្នាំកសិកម្ម និងបសុឱសថ ។ល។

- សិក្សា និងឈានទៅបង្កើតកម្មវិធីធានារ៉ាប់រងក្នុងវិស័យកសិកម្ម ដើម្បីធ្វើឱ្យការប្រកបរបរកសិកម្មរបស់ប្រជាកសិករមានស្ថិរភាព កាត់បន្ថយបានជាអតិបរមានូវហានិភ័យ និងការខូចខាតបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិនានា។ ជាមួយនេះ បន្តជំរុញការកាត់បន្ថយថែមទៀតអត្រាការប្រាក់សម្រាប់ឥណទានកសិកម្មឲ្យកាន់តែផ្តល់ភាពអនុគ្រោះដល់ប្រជាកសិករ។

- បង្កើនចំណាយថវិកាជាតិ និងកៀរគរធនធានហិរញ្ញវត្ថុបន្ថែមពីគ្រប់ប្រភព រួមទាំងជំនួយពីដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគពីវិស័យឯកជនក្នុងប្រទេស និងក្រៅប្រទេស ដើម្បីបន្តអភិវឌ្ឍ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធកសិកម្មឱ្យកាន់តែប្រសើរឡើង ដូចជា ឡសម្ងួត ឃ្លាំងស្តុក រោងចក្រកែច្នៃវេចខ្ចប់ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងបណ្តាញផ្លូវតភ្ជាប់ពីតំបន់ផលិតមកកាន់ទីផ្សារ ។

- ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្មឱ្យឆ្លើយតបតាមតម្រូវការអភិវឌ្ឍន៍ជាក់ស្តែង ជាពិសេសការពង្រឹងសមត្ថភាពប្រជាកសិករឱ្យក្លាយជាដៃគូដ៏សកម្មក្នុងភាពជាដៃគូកសិធុរកិច្ច តាមរយៈការអប់រំ ស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្មស្តីពីចំណេះដឹង បច្ចេកទេសថ្មីៗ បទពិសោធន៍ និងព័ត៌មានអំពីអាកាសធាតុ និងទីផ្សារដែលមានយន្តការជាប្រព័ន្ធទូទាំងប្រទេសពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋានឃុំ សង្កាត់ និងភូមិ ។ យកចិត្តទុកដាក់ការបង្កាត់ និងអភិវឌ្ឍពូជដំណាំ និងពូជសត្វថ្មីៗ ដែលមានលក្ខណៈទំនើបធន់ជាមួយការប្រែប្រួលអាកាសធាតុ(ការឡើងកម្តៅ រាំងស្ងួត ទឹកជំនន់ ទឹកសមុទ្រ) និងសមាសភាពចង្រៃ (ជំងឺ សត្វចង្រៃ សត្វល្អិតចង្រៃ និងស្មៅចង្រៃ) ផ្តល់ទិន្នផលខ្ពស់ និងមានគុណភាពល្អ ឆ្លើយតបតាមតម្រូវការទីផ្សារ ។ រៀបចំបង្កើតឱ្យមានបណ្ឌិត្យសភាវិទ្យាសាស្ត្រកសិកម្មកម្ពុជាដែលមានមធ្យោបាយ ធនធាន និងសមត្ថភាពស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើបៗបម្រើដល់វិស័យកសិកម្ម ដោយមានមូលដ្ឋានចេញពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ។

- បង្កើនការយកចិត្តទុកដាក់ និងលើកទឹកចិត្តដល់ការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងប្រព័ន្ធព័ត៌មានវិទ្យាប្រកបដោយភាពច្នៃប្រឌិតខ្ពស់នៅក្នុងគ្រប់ដំណាក់នៃខ្សែចង្វាក់ផលិតកម្មកសិកម្ម ដែលធានាគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ ។ ទន្ទឹមនេះ យកចិត្តទុកដាក់ផ្តល់រង្វាន់លើកទឹកចិត្តដល់ការស្រាវជ្រាវ អភិវឌ្ឍ ផ្សព្វផ្សាយ និងប្រើប្រាស់របកគំហើញថ្មីៗ ដូចជាបច្ចេកទេសផលិត កែច្នៃ បច្ចេកវិទ្យាកសិកម្ម ពូជ គ្រឿងយន្តកសិកម្ម ឧបករណ៍កសិកម្ម ។ល។ សំដៅជំរុញគំនិតច្នៃប្រឌិតថ្មីសម្រាប់បង្កើនសន្ទុះទំនើបកម្មកសិកម្មឲ្យកាន់តែមានឧត្តមភាពប្រកួតប្រជែង។

- ពង្រឹងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យលើមុខទំនិញកសិកម្មគ្រប់ប្រភេទរួមទាំងកសិផលជាដំណាំ សត្វ សាច់ ត្រី និងផលិតផលជលផល ដើម្បីធានាការសម្រួលពាណិជ្ជកម្ម ការទប់ស្កាត់ និងលុបបំបាត់ការឆ្លងសមាសភាពចង្រៃ និងការបំពុលដោយសារសំណល់សារធាតុគីមី-ជីវសាស្ត្របង្កគ្រោះថ្នាក់ដល់សុខភាពលើសកម្រិតកំណត់ ដែលអាចមាននៅជាមួយទំនិញកសិកម្មទាំងនោះ ក៏ដូចជាជួយគាំទ្រដល់ផលិផលកសិកម្មក្នុងស្រុកឱ្យមានគុណភាពល្អ ឆ្លើយតបតាមស្តង់ដារសុវត្ថិភាពស្បៀងអាហារនៃតម្រូវការទីផ្សារទាំងក្នុងស្រុក និងទីផ្សារនាំចេញ ។ ជំរុញខ្លាំងការធ្វើផលិតកម្មកសិកម្មសរីរាង្គ ការអនុវត្តកសិកម្មល្អ ការចិញ្ចឹមសត្វល្អ និងវារីវប្បកម្មល្អ ។

- បន្តពង្រឹងការអនុវត្តយ៉ាងម៉ឺងម៉ាត់ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ជំនាញពាក់ព័ន្ធនានា ជំរុញការចូលរួមសហការ និងតាមដានកាន់តែប្រសើរឡើងពីប្រជាជន និងសង្គមស៊ីវិល ជាពិសេសពីប្រជាសហគមន៍មូលដ្ឋាន ព្រមទាំងបន្តផ្តល់សិទ្ធិឱ្យប្រជាសហគមន៍គ្រប់គ្រង ប្រើប្រាស់ និងអភិវឌ្ឍដោយចីរភាពនូវធនធានព្រៃឈើ និងជលផលរួមទាំងអតីតឡូត៍នេសាទ តាមរយៈការបង្កើតជាសហគមន៍នេសាទ និងសហគមន៍ព្រៃឈើឱ្យបានកាន់តែច្រើនប្រកបដោយសមត្ថភាព និងប្រសិទ្ធ-ភាព ហើយរាល់សមាជិកនៃសហគមន៍នឹងទទួលបានផលប្រយោជន៍ពីការចូលរួមនេះ។ ពុំមានការផ្តល់ដីសម្បទានសេដ្ឋកិច្ច ឬ ការជួលឡូត៍នេសាទទៀតទេ ហើយតំបន់សម្បទានសេដ្ឋកិច្ចដែលនៅសេសសល់ពីមុនមកនឹងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងរ៉ឹង ដើម្បីធានាថា ដំណើរការដីសម្បទានសេដ្ឋកិច្ចទាំងនោះប្រព្រឹត្តទៅប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់។

## ២- ការអភិវឌ្ឍជនបទ

- ជំរុញចលនាអភិវឌ្ឍន៍មូលដ្ឋានឃុំភូមិប្រកបដោយចីរភាព មានសុវត្ថិភាព សាមគ្គីភាព សុខដុមរមនា និងមានជីវភាពរស់នៅកាន់តែល្អប្រសើរ តាមរយៈការបណ្ដុះគំនិតភាពជាម្ចាស់ មានការច្នៃប្រឌិត ខិតខំធ្វើការងារ ប្រែក្លាយរាល់ការផលិតគ្រប់ប្រភេទ ជាពិសេសការធ្វើកសិកម្មទៅជាមុខជំនួញ និងមានស្មារតីសហការជួយគ្នាទៅវិញទៅមក ។ បង្កើនការអនុវត្តកម្មវិធីផ្សព្វផ្សាយ បណ្ដុះជំនាញវិជ្ជាជីវៈ ច្នៃប្រឌិត និងបង្កើតមុខរបរ ជាពិសេសសម្រាប់យុវជននៅក្នុងមូលដ្ឋានផ្ទាល់ កាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។

- បង្កើនសន្ទុះអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ដោយផ្ដល់អាទិភាពខ្ពស់ដល់ការស្ថាបនា ការស្ដារ និងកែលម្អផ្លូវក្នុងភូមិ ផ្លូវតភ្ជាប់ពីភូមិទៅឃុំ ពីតំបន់កសិដ្ឋាន ស្រែចំការទៅកាន់ផ្លូវជាតិ ទីក្រុង ទីប្រជុំជនដែលជាទីផ្សារសម្រាប់ផលិតផលកសិកម្ម ដោយបន្តស្ថាបនាផ្លូវដី ផ្លូវក្រួសក្រហម និងប្រែក្លាយជាជំហានៗពីផ្លូវដី ឬក្រួសក្រហមឱ្យទៅជាផ្លូវក្រាលកៅស៊ូ ឬចាក់បេតុង។ ទន្ទឹមនេះពង្រឹងការថែទាំជួសជុលផ្លូវជនបទជាប្រចាំ សំដៅធានាការប្រើប្រាស់បានគ្រប់រដូវកាល ជំរុញសកម្មភាពសេដ្ឋកិច្ច និងកែលម្អបរិស្ថានរស់នៅនៅជនបទ រៀបចំឲ្យមានដំណើរការនៃប្រព័ន្ធគ្រប់គ្រង និងថែទាំផ្លូវជនបទដោយចីរភាព ដោយមានការចូលរួមរបស់សហគមន៍មូលដ្ឋានជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ។

- ជំរុញការអនុវត្តរបៀបរស់នៅស្អាត និងមានអនាម័យល្អប្រកបដោយសុវត្ថិភាព តាមរយៈការពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតនៅជនបទ ការបន្តជីកអណ្ដូង និងស្រះទឹក ការជំរុញចលនាធ្វើបង្គន់អនាម័យនៅគ្រប់ខ្នងផ្ទះរបស់ប្រជាជន និងក្នុងទីធ្លាកំសាន្តសាធារណៈនានា និងការផ្សព្វផ្សាយអប់រំប្រជាជនអំពីសុខភាព ការបង្ការរោគ និងអនាម័យ។

- បន្តអភិវឌ្ឍតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅឲ្យរីកចម្រើនទាំងខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ធានាសិទ្ធិទទួលបានការការពារដោយច្បាប់ និងវិធានការសង្គមនានា ដែលឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការរស់នៅប្រកបដោយភាពថ្លៃថ្នូរ ព្រមទាំងការគោរពចំពោះទំនៀមទម្លាប់ប្រពៃណី ភាសា ជំនឿ របស់ជនជាតិដើមភាគតិច។

## ៣- ការជំរុញពាណិជ្ជកម្ម

- ពង្រឹងការសម្រួលពាណិជ្ជកម្ម តាមរយៈការកែលម្អនីតិវិធី ការពង្រឹងយន្តការ ដឹកជញ្ជូនឆ្លងដែន ការកាត់បន្ថយថ្លៃចម្លងការពាណិជ្ជកម្ម និងការពង្រឹងការសម្របសម្រួលស្ថាប័ន។ ជាមួយនេះបន្តកែលម្អការធ្វើបែបបទបញ្ជាញទំនិញ សម្រាប់ទំនិញដែលលើកលែងពន្ធ កាត់បន្ថយតម្រូវការឯកសារមិនចាំបាច់ សម្រួលនីតិវិធីឲ្យបានឆាប់រហ័ស និងលុបបំបាត់ចំណាយក្រៅផ្លូវការ ព្រមទាំងកាត់បន្ថយនីតិវិធីត្រួតពិនិត្យដែលជាន់គ្នា និងគ្មានតម្លាភាព និងបង្កើត និងដាក់ឲ្យដំណើរការមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មដែលប្រមូលផ្ដុំនូវព័ត៌មានអំពីវិធានពាណិជ្ជកម្ម តារាងពន្ធ និងកម្រៃផ្លូវការដែលត្រូវបង់ដោយពាណិជ្ជករ ហើយដាក់ព័ត៌មានទាំងនេះលើបណ្ដាញអ៊ីនធឺណិត ។

- បន្តជំរុញការធ្វើពិពិធកម្មទីផ្សារនាំចេញ និងបង្កើនល្បឿនសមាហរណកម្មនៅក្នុងក្របខណ្ឌពាណិជ្ជកម្មសេរីសំខាន់ៗក្នុងតំបន់ និងពិភពលោក ពិសេសបណ្តាប្រទេសក្នុងសមាគមអាស៊ាន ស្របតាមទិសដៅសម្រេចផែនការមេស្តីពីការតភ្ជាប់អាស៊ាន ២០២៥ និងបណ្តាប្រទេសសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ ការពារ និងលើកតម្កើងកម្មសិទ្ធិបញ្ញា និងជំរុញការប្រកួតប្រជែងពាណិជ្ជកម្មប្រកបដោយភាពយុត្តិធម៌ និងសមធម៌។

- ជំរុញការចរចាយ៉ាងសកម្មលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងក្របខណ្ឌអាស៊ាន-សហគមន៍អឺរ៉ុប ដើម្បីធានាបានចំណែកទីផ្សារអឺរ៉ុប និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសំខាន់ៗផ្សេងៗទៀត និងជំរុញពាណិជ្ជកម្មក្នុងស្រុក តាមរយៈការរៀបចំវេទិកា ឬ សន្និសីទថ្នាក់ជាតិលើគោលនយោបាយអភិវឌ្ឍន៍កសិ-ពាណិជ្ជកម្ម ដើម្បីជំរុញអ្នកផលិត កសិករ និងសមាគមអាជីវកម្មឱ្យកាន់តែខិតខំផលិតទំនិញ និងសេវាកម្ម ដោយអនុលោមតាមស្តង់ដារផលិតកម្ម។

- ពង្រឹងយន្តការតាមដានថ្លៃទីផ្សារដើម្បីរក្សាស្ថិរភាពថ្លៃទំនិញ បន្តធ្វើកិច្ចអន្តរាគមន៍លើទីផ្សារពិសេសបណ្តាមុខទំនិញជាយុទ្ធសាស្ត្រ ដូចជា ស្រូវ អង្ករ កៅស៊ូ ពោត ប្រេងឥន្ធនៈ អគ្គិសនី ទឹក និងមុខទំនិញផ្សេងទៀត តាមរយៈការផ្សព្វផ្សាយ ជំរុញលើកទឹកចិត្ត និងទប់ស្កាត់សកម្មភាពលក់បំប៉ោងថ្លៃ ឬ ការស្តុកទំនិញលក់ដំឡើងថ្លៃ សំដៅលើកកម្ពស់សកម្មភាពធុរកិច្ច ការនាំចេញនាំចូល និងជីវភាពរបស់ប្រជាជន។ ជាមួយនេះ បង្កលក្ខណៈងាយស្រួលក្នុងការធ្វើចរាចរផលិតផល និងទំនិញបានដោយសេរីនៅគ្រប់ទីកន្លែងតាមគោលការណ៍ទីផ្សារ ពិសេសបន្តខិតខំការពារថ្លៃកសិផលរបស់ប្រជាកសិករ ។

- ជំរុញការផលិត និងការប្រើប្រាស់ផលិតផលក្នុងស្រុក ពិសេសផលិតផលខ្មែរ ផលិតផលមានលក្ខណៈប្រពៃណី ដូចជា កន្ទេល ក្រមា រូបចម្លាក់ គ្រឿងសង្ហារឹម នំ បង្អែម ជាដើម និងផលិតផលសម្គាល់ភូមិសាស្ត្រដើម្បីលើកកម្ពស់ផលិតផលខ្មែរ និងការបង្កើតការងារធ្វើក្នុងស្រុក ។ បន្តលើកកម្ពស់ការយល់ដឹង ការប្រើប្រាស់ផលិតផលមានគុណភាព មានអនាម័យ មានច្បាប់អនុញ្ញាត ទន្ទឹមនេះទប់ស្កាត់ការផលិត ការនាំចូល និងការចែកចាយផលិតផលក្លែងក្លាយ និងផលិតផលខូចគុណភាព និងហួសកាលបរិច្ឆេទប្រើប្រាស់ ដើម្បីការពារផលប្រយោជន៍ប្រជាជន ។

- រៀបចំបណ្តាញធុរកិច្ចដែលជាមូលដ្ឋានក្នុងការផ្តល់ការពិគ្រោះយោបល់ផ្នែកពាណិជ្ជកម្ម ផ្តល់ព័ត៌មានអំពីទីផ្សារក្រៅប្រទេស និងជួយសម្របសម្រួលសកម្មភាពជំរុញការនាំចេញ រួមទាំងការរៀបចំការផ្សព្វផ្សាយទីផ្សារ ឬ ការតាំងពិព័រណ៍។ បន្តតាមដានពិនិត្យស្ថានភាព និងពង្រឹងការងារបច្ចេកទេសដល់សភាពាណិជ្ជកម្មរាជធានី ខេត្ត សម្របសម្រួលជំរុញកិច្ចសហប្រតិបត្តិការរវាងសភា-ពាណិជ្ជកម្មថ្នាក់ជាតិ និងអន្តរជាតិ តាមដានថ្លៃទំនិញ និងស្ថិរភាពទីផ្សារ តាមរយៈការឃ្លាំមើលសកម្មភាពអាជីវកម្ម និងការផ្តល់ពត៌មានទាន់ពេលវេលាសម្រាប់វិស័យឯកជន ទប់ស្កាត់ការប្រមូលទិញផ្តាច់មុខពីឈ្មួញកណ្តាល និងរក្សាបាននូវកម្លាំងចរចាថ្លៃ តាមរយៈការចងក្រង និងបង្កើតសហគមន៍អាជីវកម្មតាមបណ្តាមូលដ្ឋានផលិតធំៗ ។

- អភិវឌ្ឍវិស័យពាណិជ្ជកម្មនៅថ្នាក់ក្រោមជាតិ ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគនៅតាមរាជធានី ខេត្ត ដោយបន្តអនុវត្តចលនាភូមិ១ ផលិតផល១ ឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព តាមរយៈការជំរុញវិស័យឯកជន និងផលិតករខ្នាតតូចតាមបណ្ដាខេត្តឱ្យចូលរួមសម្រិតសម្រាំងគុណភាពផលិតផល និងចូលរួមដាក់តាំងផលិតផលក្នុងវេទិកាពាណិជ្ជកម្មនានា និងរៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរជារៀងរាល់ឆ្នាំ។

**៤- ការគ្រប់គ្រងដីធ្លី និងសំណង់**

- ជំរុញការគ្រប់គ្រង ប្រើប្រាស់ និងអភិវឌ្ឍដីធ្លីឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ដើម្បីបង្កើនផលិតភាពដី ជាមូលដ្ឋានគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព និងសមធម៌ ស្របតាមសក្ដានុពល និងគុណភាពរបស់ដីនៅក្នុងតំបន់ភូមិសាស្ត្រមូលដ្ឋានជាក់ស្ដែង ដោយសិក្សារៀបចំបង្កើតឱ្យមានផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីឱ្យបានគ្រប់រាជធានី ខេត្ត និងក្រុង ខណ្ឌ ស្រុកនៅទូទាំងប្រទេស ។ ជាមួយនេះ បន្តជំរុញការរៀបចំផែនការប្រើប្រាស់ដីឃុំ សង្កាត់ ។

- ជំរុញការវាស់វែង ចុះបញ្ជី និងផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លីលើកដំបូងតាមលក្ខណៈជាប្រព័ន្ធដោយឥតគិតថ្លៃជូនប្រជាជនដែលបាន និងកំពុងគ្រប់គ្រង និងប្រើប្រាស់ស្របច្បាប់ឱ្យបានចប់នៅត្រឹមឆ្នាំ ២០២៣ និងបន្តចុះបញ្ជីចំពោះក្បាលដីដែលត្រូវបានផ្ទេរ ឬប្រែប្រួលតាមតម្រូវការជាក់ស្ដែងរបស់កម្ម-សិទ្ធិករ ដើម្បីពង្រឹងការធានាសន្តិសុខដីធ្លីគ្រប់ប្រភេទ រួមទាំងដីធ្លីឯកជនរបស់ប្រជាជន ដីធ្លីសមូហភាពរបស់សហគមន៍មូលដ្ឋាន និងដីធ្លីរបស់រដ្ឋ សំដៅកាត់បន្ថយជាអតិបរមានូវទំនាស់ដីធ្លី និងលុបបំបាត់សកម្មភាពល្មើសច្បាប់ក្នុងការរំលោភដណ្ដើមកាន់កាប់ដីធ្លីគ្រប់ប្រភេទ ។ បន្តចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។

- បន្តអនុវត្តគោលនយោបាយដ៏ថ្លៃថ្លារបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក្នុងការអនុគ្រោះពន្ធលើការផ្ទេរសិទ្ធិកម្មសិទ្ធិរវាងឪពុកម្ដាយបង្កើត និងកូនបង្កើត និងរវាងជីដូនជីតាបង្កើត និងចៅបង្កើត ក៏ដូចការបន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីកសិកម្មរបស់ប្រជាកសិករដែលបង្កបង្កើនផលជាលក្ខណៈគ្រួសារ។

- បែងចែកដីធ្លីដែលមាននៅក្នុងសន្និធិជាក់ស្ដែងរបស់រដ្ឋ ជូនដល់គ្រួសារប្រជាជនក្រីក្រ យុទ្ធ-ជនពិការ គ្រួសារយុទ្ធជនពលី អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលគ្មានដី ខ្វះដី ហើយត្រូវការដីពិតប្រាកដ តាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចប្រកបដោយតម្លាភាព សមធម៌ និងយុត្តិធម៌ដែលធានាប្រសិទ្ធភាពក្នុងការលើកស្ទួយជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

- ជំរុញការអភិវឌ្ឍវិស័យសំណង់ និងការរៀបចំទីក្រុង ទីប្រជុំជនដោយចីរភាព តាមរយៈការជំរុញអភិវឌ្ឍ និងពង្រឹងការអនុវត្តបទដ្ឋានគតិយុត្តិ ច្បាប់ បច្ចេកទេស និងស្ដង់ដារសំណង់វៃឆ្លាតដែលធានាគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ មានតម្រូវការប្រើប្រាស់ទឹក និងថាមពលតិចសម្រាប់ការរស់នៅប្រកបដោយផាសុកភាពរបស់ប្រជាជន ។ បង្កើតកម្មវិធីជាតិមួយក្នុងការអភិវឌ្ឍលំនៅឋានដែលមានតម្លៃថោកសមរម្យ ដើម្បីជួយសម្រួលដោះស្រាយលំនៅឋានសម្រាប់ក្រុមគ្រួសារមានចំណូលទាប ឬចំណូលមធ្យមកម្រិតទាបមានលទ្ធភាពទិញ ឬជួលបាន ជាពិសេសយុវជនដែលទើបរៀបការបង្កើតគ្រួសារថ្មី។

- ពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងបច្ចេកទេសពាក់ព័ន្ធ ព្រមជាមួយការគ្រប់គ្រងដីធ្លី និងសំណង់គ្រប់ប្រភេទឱ្យកាន់តែមានប្រសិទ្ធភាព ដោយយកចិត្តទុកដាក់ខ្ពស់ដល់ការអភិវឌ្ឍសមត្ថភាពមន្ត្រីសមត្ថកិច្ចជំនាញដើម្បីផ្តល់សេវាសាធារណៈក្នុងវិស័យដីធ្លី និងសំណង់ឱ្យបានកាន់តែប្រសើរឡើងតាមតម្រូវការចាំបាច់របស់ប្រជាជន។ បង្កើនការអប់រំផ្សព្វផ្សាយឱ្យមានការយល់ដឹងជាសាធារណៈ និងការចូលរួមអនុវត្តរបស់ប្រជាជន ក៏ដូចក្រុមហ៊ុននានាក្នុងការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី និងសំណង់ស្របតាមច្បាប់ និងបទបញ្ញត្តិនានាប្រកបដោយចីរភាព និងប្រសិទ្ធភាព ។

## ៥- ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

- ពង្រឹងការអនុវត្តគោលនយោបាយ "បរិស្ថានស្អាត និងបៃតង" សំដៅរួមចំណែកធានាគោលដៅអភិវឌ្ឍន៍ដោយចីរភាព។ ដើម្បីសម្រេចគោលដៅនេះ គណបក្សបន្តជំរុញកិច្ចគាំពារបរិស្ថាន ឲ្យឆ្លើយតបទៅនឹងកំណើនប្រជាជន និងសំណូមពរនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមរយៈការតាមដាន និងត្រួតពិនិត្យជាប្រចាំនូវគុណភាពបរិស្ថាន (ទឹក, ដី, ខ្យល់) ការបង្កើនប្រសិទ្ធភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពីគម្រោងអភិវឌ្ឍន៍នានាទាំងរដ្ឋ និងឯកជន ដើម្បីធ្វើឱ្យប្រាកដថា រាល់គម្រោងអភិវឌ្ឍន៍ទាំងអស់នឹងមានផលប៉ះពាល់តិចបំផុតចំពោះសុខុមាលភាពរបស់ប្រជាជន និងបរិស្ថានធម្មជាតិ។ ពង្រឹងការត្រួតពិនិត្យ និងគ្រប់គ្រងយ៉ាងម៉ត់ចត់ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសទាន់សម័យ និងមានសុវត្ថិភាពខ្ពស់ ចំពោះសំណល់រឹង រាវ និងសារធាតុគ្រោះថ្នាក់ទាំងអស់ ដើម្បីធានាដល់ជីវិតរស់នៅរបស់ប្រជាជនក្នុងបរិស្ថានស្អាតប្រកបដោយសុវត្ថិភាព និងផាសុកភាព គ្មានការបំពុលគ្រប់យ៉ាង ។

- បង្កើនការយល់ដឹង និងការយកចិត្តទុកដាក់ជាសាធារណៈលើកិច្ចការការពារបរិស្ថាន តាមរយៈកម្មវិធីអប់រំផ្សព្វផ្សាយគ្រប់រូបភាព និងការសម្របសម្រួលគោលនយោបាយអភិវឌ្ឍន៍ជាតិ ដោយបញ្ជ្រាបយ៉ាងវៃឆ្លាតនូវគោលដៅអភិវឌ្ឍន៍ដោយចីរភាព រួមទាំងការប្រែប្រួលអាកាសធាតុ ទៅក្នុងគ្រប់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមនៅគ្រប់ថ្នាក់ ។

- បង្កើនការអភិរក្សធនធានធម្មជាតិ ដោយបន្តសិក្សារៀបចំតំបន់ព្រៃឈើធម្មជាតិសំខាន់ៗទាំងអស់ជាតំបន់ការពារធម្មជាតិ ដែលបច្ចុប្បន្ននេះមានរហូតទៅដល់៤៦កន្លែង គ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ៧,៥លានហិកតា ។ កំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិទាំងអស់ឱ្យបានច្បាស់លាស់ និងមានផែនការគ្រប់គ្រង និងអភិរក្សប្រកបដោយចីរភាពសម្រាប់ជាឧត្តមប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងបច្ចុប្បន្ន និងអនាគតយូរអង្វែង។ ជាមួយនឹងការពង្រឹងការអនុវត្តច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ជំនាញពាក់ព័ន្ធនានានោះ ត្រូវបន្តជំរុញលើកទឹកចិត្តឱ្យមានការចូលរួមសហការ និងតាមដានកាន់តែល្អប្រសើរពីប្រជាជន និងសង្គមស៊ីវិល ជាពិសេសពីប្រជាសហគមន៍មូលដ្ឋានផ្ទាល់។ លើសពីនេះទៀត ប្រជាសហគមន៍មូលដ្ឋានដែលរស់នៅក្នុង និងក្បែរតំបន់ការពារធម្មជាតិនឹងត្រូវបានផ្តល់សិទ្ធិគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងប្រសិទ្ធភាព ព្រមទាំងទទួលបានការគាំទ្រ និងឧបត្ថម្ភបំណិនជីវិត តាមរយៈការដាំដុះ ការចិញ្ចឹមសត្វ វារីវប្បកម្ម ការកែច្នៃផលិតផលជាវត្ថុអនុស្សាវរីយ៍ ឬ ចំណីអាហារ និងការផ្តល់សេវាកម្មផ្សេងៗនៅតាមតំបន់

គុណភាព និងភាពរហ័សទាន់ពេលវេលាក្នុងចលនាដឹកជញ្ជូនទំនិញ និងអ្នកដំណើរ ដើម្បីជំរុញការធ្វើធុរកិច្ចប្រកបដោយតម្លាភាព និងសមភាព ព្រមទាំងមានតម្លៃសេវាកម្មដឹកជញ្ជូនមួយដែលមានភាពប្រកួតប្រជែងនៅគ្រប់កម្រិត ក្នុងប្រទេស តំបន់ និងពិភពលោក ។

- បន្តជំរុញការធ្វើសមាហរណកម្មវិស័យដឹកជញ្ជូនកម្ពុជាឲ្យកាន់តែស៊ីជម្រៅជាមួយប្រទេសជិតខាងក្នុងតំបន់ និងពិភពលោក តាមរយៈការចូលរួមអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដឹកជញ្ជូននានា មានជាអាទិ៍ គំនិតផ្តួចផ្តើម "ខ្សែក្រវ៉ាត់មួយ ផ្លូវមួយ" ផែនការយុទ្ធសាស្ត្រដឹកជញ្ជូនអាស៊ាន ២០១៦-២០២៥ ផែនការមេស្តីពីការតភ្ជាប់អាស៊ាន ២០២៥ និងផែនការដទៃៗទៀត ។

- បន្តស្តារ ជួសជុល ថែទាំ ពង្រីក អភិវឌ្ឍថ្មីនូវផ្លូវជាតិ និងផ្លូវខេត្ត ជាមួយនឹងការពង្រឹងការអនុវត្តកម្មវិធីថែទាំផ្លូវ លើកកម្ពស់ការប្រើប្រាស់ និងពង្រឹងសមត្ថភាពស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំផែនការប្រតិបត្តិការ និងការគ្រប់គ្រងបណ្តាញដឹកជញ្ជូន។ ជំរុញការជួសជុល ថែទាំ និងសាងសង់ប្រព័ន្ធបង្ហូរ និងចម្រោះទឹកកខ្វក់ឱ្យមានប្រសិទ្ធភាពខ្ពស់ នៅតាមទីក្រុង និងទីរួមខេត្តដើម្បីបញ្ចៀសការលិចលង់តំបន់ប្រជាជនរស់នៅ ធានាបរិស្ថានល្អ និងសុខុមាលភាពប្រជាជន ព្រមទាំងជំរុញការកសាង និងការការពារច្រាំងទន្លេ ។ ជំរុញការស្តារ សាងសង់ និងអភិវឌ្ឍផ្លូវដែក ដើម្បីផ្ទេរការដឹកជញ្ជូនពីផ្លូវថ្នល់មកការដឹកជញ្ជូនតាមផ្លូវដែក បន្ថយបន្ទុកការប្រើប្រាស់ផ្លូវថ្នល់។ ព្រមជាមួយនេះ បន្តអភិវឌ្ឍការដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ជាពិសេសការសាងសង់ និងពង្រីកកំពង់ផែទឹកជ្រៅឲ្យឆ្លើយតបទៅនឹងកំណើននៃពាណិជ្ជកម្មជាតិ និងអន្តរជាតិ។

- ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក បង្កើនការត្រួតពិនិត្យបច្ចេកទេសយានយន្ត លុបបំបាត់ការដឹកជញ្ជូនហួសទម្ងន់កំណត់ និងការកែច្នៃយានយន្តខុសលក្ខណៈបច្ចេកទេស យកចិត្តទុកដាក់រក្សាសុវត្ថិភាពចរាចរណ៍ និងផ្តល់សេវារហ័សតម្លៃថោក រួមទាំងវិធានការចាំបាច់នានាដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងការកកស្ទះចរាចរណ៍ ។

### ២- អាកាសចរស៊ីវិល

ការដឹកជញ្ជូនតាមផ្លូវអាកាសត្រូវមានលក្ខណៈទន់ភ្លន់ បត់បែន និងវិចារណកម្មត្រឹមត្រូវបំផុតជាមួយបណ្តាប្រទេសក្នុងតំបន់ និងក្រៅតំបន់ ប្រកបដោយបរិមាណ គុណភាព និងប្រសិទ្ធភាព។ វិស័យអាកាសចរស៊ីវិលកម្ពុជាបាន និងកំពុងរីកចម្រើនគួរឲ្យកត់សម្គាល់ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍។ ក្នុងន័យនេះ គោលនយោបាយអាទិភាពក្នុងការអភិវឌ្ឍវិស័យនេះ រួមមាន៖

- បន្តចូលរួមអនុវត្តគោលនយោបាយបើកចំហជើងមេឃក្នុងក្របខណ្ឌអាស៊ាន មហាអនុតំបន់ទន្លេមេគង្គ ក្រុមប្រទេសកម្ពុជា ឡាវ ភូមា វៀតណាម ( CLMV) និងកិច្ចសហប្រតិបត្តិការអន្តរជាតិផ្សេងៗទៀត ព្រមទាំងការពង្រឹងសន្តិសុខ សុវត្ថិភាពហោះហើរ សេវាកម្មអាកាសយានដ្ឋាន និងចីរភាពបរិស្ថាន។

- បន្តកែលម្អ និងធ្វើទំនើបកម្មអាកាសយានដ្ឋានជាតិ-អន្តរជាតិ ក្នុងនោះមានដូចជាការអភិវឌ្ឍព័ត៌មានវិទ្យា ព័ត៌មានឧតុនិយម ប្រព័ន្ធទិន្នន័យស្ថិតិ ការសិក្សាអង្កេត និងផ្លាស់ប្តូរប្រព័ន្ធផ្តល់

ព័ត៌មានអាកាសចរណ៍ជាដើម ព្រមទាំងអភិវឌ្ឍអាកាសវិថីស្រប ( Parallel Routes) បែងចែកការគ្រប់គ្រងចរាចរណ៍ដែនអាកាស ដើម្បីពង្រឹងសុវត្ថិភាពនៃការហោះហើរ។ ស្តារ និងធ្វើទំនើបកម្មអាកាសយានដ្ឋានក្នុងស្រុកដែលមានអាទិភាពខ្ពស់។

- ពង្រឹងសុវត្ថិភាព និងសន្តិសុខអាកាសចរស៊ីវិលតាមរយៈការពង្រឹង និងកែលម្អលក្ខខណ្ឌបច្ចេកទេស សុវត្ថិភាពហោះហើរ និងលទ្ធភាពហោះហើររបស់បណ្តាក្រុមហ៊ុន កែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់សុវត្ថិភាពនាំផ្លូវអាកាស និងអាកាសយានដ្ឋាន ព្រមទាំងពង្រឹងការតាមដាន និងត្រួតពិនិត្យលើប្រតិបត្តិករសន្តិសុខអាកាសយានដ្ឋាន និងក្រុមហ៊ុនសន្តិសុខឯកជន សំដៅធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងផ្តល់សេវាកម្មអាកាសចរស៊ីវិល និងកាត់បន្ថយនូវហានិភ័យពីគ្រោះថ្នាក់អាកាសចរណ៍។

- បង្កើនការគ្រប់គ្រង និងចាត់ចែងការផ្តល់សេវាកម្មពាក់ព័ន្ធនានា រួមមាន ការនាំផ្លូវអាកាស (ចេញ-ចូល) ការឆ្លងកាត់ដែនអាកាស ការចុះចតជាលក្ខណៈឯកជន ការរុករកសង្គ្រោះបន្ទាន់ ការពន្លត់អគ្គិភ័យសម្រាប់យន្តហោះស្ថិតក្នុងភាពគ្រោះថ្នាក់ និងការផ្តល់ព័ត៌មានហោះហើរ ដើម្បីពង្រឹងគុណភាពនៃការផ្តល់សេវាកម្មអាកាសចរស៊ីវិលប្រកបដោយភាពជឿទុកចិត្ត និងទាន់ពេលវេលា។

### ៣- ការគ្រប់គ្រងធនធានទឹក និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ

- ទឹកជាប្រភពនៃជីវិត ការគ្រប់គ្រង ប្រើប្រាស់ និងអភិវឌ្ឍទឹកដោយចីរភាព និងសមធម៌ឱ្យកាន់តែមានប្រសិទ្ធភាពស្របទៅតាមពេលវេលា និងទីតាំងនៃតម្រូវការជាក់ស្តែងទាំងបរិមាណ និងគុណភាពសម្រាប់ជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចសម្រាប់វិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងសកម្មភាពសេដ្ឋកិច្ចសង្គមផ្សេងៗទៀត គឺជាអាទិភាពដ៏សំខាន់មួយសម្រាប់ធានាដល់គោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅកម្ពុជា។ ដើម្បីសម្រេចគោលដៅនេះ គណបក្សនឹងបន្តជំរុញការអភិវឌ្ឍ និងអនុវត្តផែនការគ្រប់គ្រងទឹកចម្រុះនៅតាមបណ្តាតំបន់អាងទឹកសំខាន់ៗ (តំបន់មេគង្គលើ តំបន់ទន្លេសេកុង-សេសាន-ស្រែពក តំបន់អាងទឹកបឹងទន្លេសាប តំបន់មេគង្គក្រោម-បាសាក់ និងតំបន់ឈូងសមុទ្រ) សំដៅពង្រីកការផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់តាមតម្រូវការប្រើប្រាស់ចាំបាច់ទូទាំងប្រទេស ធានាចីរភាពនៃប្រព័ន្ធបរិស្ថានធម្មជាតិ រួមទាំងបរិស្ថានទឹកដែលគ្មានការបំពុល ទប់ស្កាត់ និងកាត់បន្ថយឲ្យបានជាអតិបរមានូវហានិភ័យ និងផលប៉ះពាល់ដែលបណ្តាលមកពីទឹក ជាពិសេសគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតខ្វះទឹក។

- បង្កើនការស្តារ កសាង ថែទាំ និងការគ្រប់គ្រងប្រកបដោយចីរភាព និងប្រសិទ្ធភាពនូវហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព អាងស្តុកទឹក ប្រឡាយទឹក សំណង់ទ្វារទឹក លូទឹក ប្រព័ន្ធរំដោះទឹក ប្រឡាយនាំដីល្បាប់ តំបន់ការពារទឹកជំនន់ ការពារទឹកប្រៃ និងស្ថានីយបូមទឹក សំដៅធានាការផ្តល់ទឹកសម្រាប់បង្កបង្កើនផល កាត់បន្ថយឲ្យបានកាន់តែច្រើននូវភាពចំណុះលើធម្មជាតិ ។ រាល់ការកសាងប្រព័ន្ធធារាសាស្ត្រត្រូវមានការចូលរួមពីប្រជាជនមូលដ្ឋាននៅនឹងកន្លែង ដើម្បីធានាថា ប្រព័ន្ធ-ធារាសាស្ត្រទាំងនេះនឹងផ្តល់ផលប្រយោជន៍ច្រើនដល់ប្រជាជនទាំងអស់នៅទីនោះ ។ ជំរុញការធ្វើទំនើបកម្មប្រព័ន្ធធារាសាស្ត្រទាំងខ្នាតតូច មធ្យម និងខ្នាតធំ ដោយបំពាក់មធ្យោបាយឧបករណ៍ប្រកបដោយបច្ចេកវិទ្យាវៃឆ្លាត ថ្លៃប្រឌិត សន្សំសំចៃទឹក និងបង្កើនផលិតភាពខ្ពស់។ ការធ្វើទំនើបកម្មប្រព័ន្ធ

ធារាសាស្ត្រនឹងត្រូវអនុវត្តសម្រាប់គ្រប់តំបន់កសិកម្មសំខាន់ៗ ហើយក្នុងការសាងសង់ប្រព័ន្ធធារាសាស្ត្រថ្មីៗនឹងផ្តល់អាទិភាពនៅតំបន់ដាំដុះមុខដំណាំមានតម្លៃខ្ពស់ដែលមានប្រភពទឹកគ្រប់គ្រាន់។ ព្រមជាមួយនេះ យកចិត្តទុកដាក់បន្តការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍធនធានទឹកនៅក្រោមដី ដើម្បីបង្កើនការប្រើប្រាស់ទឹកដោយចីរភាព ។

- ពង្រឹងកិច្ចសម្របសម្រួល និងសហប្រតិបត្តិការរវាងសមត្ថកិច្ចជំនាញគ្រប់ថ្នាក់នៃក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវាជំនាញសាធារណៈជូនប្រជាជនឱ្យកាន់តែល្អប្រសើរ ឆ្លើយតបបានទាន់ពេលវេលាតាមតម្រូវការជាក់ស្តែង ។ ព្រមជាមួយនោះ ជំរុញការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សឱ្យបានគ្រប់គ្រាន់សម្រាប់ការគ្រប់គ្រង ប្រើប្រាស់ និងអភិវឌ្ឍធនធានទឹកប្រកបដោយចីរភាព ជាពិសេសលើកទឹកចិត្តប្រជាកសិករឱ្យស្ម័គ្រចិត្តចូលរួមបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកនៅតាមគ្រប់ប្រព័ន្ធធារាសាស្ត្រ ដើម្បីលើកកម្ពស់ភាពជាម្ចាស់ក្នុងការចូលរួមទទួលខុសត្រូវលើការគ្រប់គ្រង ប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រនៅក្នុងមូលដ្ឋានរបស់ខ្លួន ។

- បង្កើនទុនវិនិយោគសាធារណៈ បន្តខិតខំទាក់ទាញជំនួយពីដៃគូអភិវឌ្ឍន៍ និងការចូលរួមនៃវិស័យឯកជនក្នុងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រស្រោចស្រពទំនើប ដែលអាចផ្តល់ទឹកស្រោចស្រពផង និងផ្តល់ផលប្រយោជន៍ច្រើនយ៉ាងទៀតផង ដូចជា ថាមពលអគ្គិសនី ការធ្វើវារីវប្បកម្ម ការការពារទឹកជំនន់ និងផ្លូវសម្រាប់ដឹកជញ្ជូន ស្របតាមសក្តានុពលនៃប្រភពធនធានទឹកនៅតាមភូមិសាស្ត្រមូលដ្ឋានជាក់ស្តែង សំដៅបង្កើនលទ្ធភាពស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រនាពេលបច្ចុប្បន្នពី ១.៧៧៨.៤០៤ហិកតា ឱ្យបានដល់ជិត២លានហិកតា នៅត្រឹមឆ្នាំ២០២៣ ពោលគឺបង្កើនលទ្ធភាពស្រោចស្រពបន្ថែមប្រមាណ៣ម៉ឺនហិកតាក្នុង១ឆ្នាំៗ។

- បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានជលសាស្ត្រ ឧតុនិយម ព្យាករណ៍អាកាសធាតុ និងផ្តល់ព័ត៌មានធាតុអាកាសបានមុនហេតុការណ៍ ជាពិសេស ព័ត៌មានស្តីពីបាតុភូតគ្រោះមហន្តរាយធម្មជាតិដែលអាចកើតឡើង ដូចជា គ្រោះទឹកជំនន់ ខ្យល់ព្យុះ រាំងស្ងួត និងរលកកម្តៅ ឱ្យបានដល់ប្រជាជនរួមទាំងប្រជាកសិករនៅក្នុងតំបន់ជនបទដាច់ស្រយាល ដើម្បីត្រៀមលក្ខណៈប្រុងប្រយ័ត្នរៀបចំបញ្ចៀសកាត់បន្ថយ និងឆ្លើយតបសមស្របបានទាន់ពេលវេលាចំពោះគ្រោះថ្នាក់ដែលអាចកើតឡើងជាយថាហេតុ។

### ៤- ការអភិវឌ្ឍទឹកស្អាត

- ពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅទីក្រុង ទីប្រជុំជនឲ្យបាន ៩០% ដល់ឆ្នាំ ២០២៣ និង១០០% ត្រឹមឆ្នាំ ២០២៥ សម្រាប់បម្រើតម្រូវការចាំបាច់របស់ប្រជាជន ក៏ដូចសម្រាប់ផលិតកម្ម និងសេវាកម្មនានា តាមរយៈការអភិវឌ្ឍពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងផ្នែកសាធារណៈ និងផ្នែកឯកជន ដោយឈរលើបុរេលក្ខខណ្ឌបួនយ៉ាងគឺ "ទឹកត្រូវមានគុណភាព សុវត្ថិភាព និរន្តរភាព និងតម្លៃសមរម្យ"។ ការកំណត់ថ្លៃលក់ទឹកស្អាត ត្រូវផ្អែកលើការគិតគូរច្បាស់លាស់អំពីកត្តាថ្លៃដើមផលិត សំដៅធានាបានទាំងផលប្រយោជន៍អ្នកប្រើប្រាស់ ទាំងផលប្រយោជន៍អ្នកផ្តល់សេវា ជាពិសេសជួយសម្រួលដល់ប្រជាជនដែលមានជីវភាពខ្សត់ខ្សោយ។

- បន្តជំរុញការចូលរួមនៃវិស័យឯកជន ក្នុងការបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅឃុំ សង្កាត់ ដែលពុំទាន់មានប្រព័ន្ធទឹកស្អាត ទន្ទឹមនេះយកចិត្តទុកដាក់បង្កើនការផ្គត់ផ្គង់ទឹកស្អាតតាមគ្រប់មធ្យោបាយផ្សេងៗទៀតដូចជា ការកសាងអាងស្តុកទឹកស្អាត ជាត្រពាំង ស្រះ និងអណ្តូងទឹកស្អាតតាមគ្រួសារនៅគ្រប់ភូមិ សំដៅធានាឲ្យប្រជាជនគ្រប់រូបនៅគ្រប់មូលដ្ឋាន រួមទាំងតំបន់ជនបទឆ្ងាយៗបានទទួលទឹកស្អាតប្រើប្រាស់ដោយស្ថិរភាពនៅគ្រប់រដូវកាល ។

**៥- ការអភិវឌ្ឍថាមពលអគ្គិសនី**

- បន្តពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឱ្យដល់ភូមិទាំងអស់នៅឆ្នាំ ២០២០ ហើយរហូតដល់ឆ្នាំ ២០២៣ ប្រមាណ ៧៥% នៃគ្រួសារទាំងអស់ទូទាំងប្រទេសនឹងមានអគ្គិសនីប្រើប្រាស់ដែលមានគុណភាពដូចអគ្គិសនីពីបណ្តាញជាតិ ។

- អនុវត្តគម្រោងកសាងស្ថានីយផលិតអគ្គិសនីនានាឱ្យទាន់ពេលវេលា ដើម្បីបំពេញកង្វះខាតថាមពលអគ្គិសនី រួមទាំងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងគុណភាពនៃការបញ្ជូនថាមពលព្រមជាមួយនឹងការខិតខំកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់លើបរិស្ថានធម្មជាតិ និងសង្គមក្នុងដំណើរការផលិតថាមពល។

- ពិនិត្យឡើងវិញនូវការប៉ាន់ស្មានពីតម្រូវការអគ្គិសនីរយៈពេលវែង និងរៀបចំផែនការអភិវឌ្ឍន៍វិស័យថាមពលឱ្យស្របតាមចក្ខុវិស័យ និងនិន្នាការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងឧស្សាហកម្មព្រមទាំងផ្តល់នូវជម្រើសសមស្របក្នុងការផ្គត់ផ្គង់ថាមពលដែលមានស្ថិរភាព ការជឿទុកចិត្ត និងមានតម្លៃសមរម្យ និងប្រហាក់ប្រហែលគ្នាទូទាំងប្រទេស សម្រាប់ផ្គត់ផ្គង់តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម និងតំបន់ឧស្សាហកម្ម តាមរយៈការបន្តអភិវឌ្ឍបណ្តាញបញ្ជូន អនុស្ថានីយ បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយអគ្គិសនីឱ្យឆាប់បានគ្របដណ្តប់ទូទាំប្រទេស ។

- លើកទឹកចិត្ត និងជំរុញការធ្វើពិពិធកម្មថាមពល ក្នុងនោះរួមមានការបង្កើតប្រភពថាមពលស្អាត និងថាមពលកកើតឡើងវិញ ការសាងសង់វារីអគ្គិសនី និងរោងចក្រអគ្គិសនីប្រើធ្យូងថ្ម ព្រមទាំងប្រភពផ្សេងទៀតដែលមានសមត្ថភាពផលិតធំ និងថ្លៃដើមផលិតទាប។ បន្តអនុវត្តតួនាទីនាំមុខរបស់រដ្ឋក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ព្រមជាមួយនេះ គាំទ្រ និងលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនក្នុងការវិនិយោគ និងធ្វើអាជីវកម្មផ្តល់សេវាអគ្គិសនី ស្របតាមច្បាប់ នីតិវិធី និងស្តង់ដារជាធរមាន ជាពិសេសការអនុវត្តថ្លៃលក់អគ្គិសនីឱ្យបានត្រឹមត្រូវ ដើម្បីការពារផលប្រយោជន៍ និងភាពយុត្តិធម៌សម្រាប់អ្នកផលិត អ្នកបញ្ជូន អ្នកចែកចាយ និងអ្នកប្រើប្រាស់ ។

- រៀបចំ និងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម រួមទាំងការពង្រឹងភាពជឿទុកចិត្ត និងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី។ តម្រង់ការផ្គត់ផ្គង់ថាមពលទៅកាន់តំបន់ផលិតកម្មសំខាន់ៗ ដោយធានាឱ្យបានការផ្គត់ផ្គង់ចរន្តអគ្គិសនី ស្រប

តាមតម្រូវការ និងមានស្ថិរភាពបំផុត ដែលអនុញ្ញាតឱ្យរោងចក្រអាចគ្រោងផលិតកម្មខ្លួនប្រកបដោយប្រសិទ្ធភាព ។

### ៦- ការអភិវឌ្ឍធនធានរ៉ែ ប្រេងកាត និងឧស្ម័ន

- ជំរុញការអភិវឌ្ឍធនធានរ៉ែ ប្រេងកាត និងឧស្ម័ន ដើម្បីប្រែក្លាយធនធាននេះឱ្យទៅជាប្រភពថ្មី និងសំខាន់មួយទៀតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ពិសេសការបន្ថែមសន្ទុះថ្មីសម្រាប់ធានាកំណើនសេដ្ឋកិច្ចខ្ពស់ជាប់ៗគ្នា។ លើកទឹកចិត្តវិស័យឯកជនធ្វើការសិក្សាស្រាវជ្រាវ ស្វែងរុករក និងវិនិយោគលើវិស័យនេះ ដោយបន្តធ្វើការតាមដានត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ ព្រមទាំងយកចិត្តទុកដាក់ខ្ពស់ទៅលើសុវត្ថិភាព សុខុមាលភាព ការការពារបរិស្ថាន និងសង្គម ។

- ជំរុញការផលិត និងផ្គត់ផ្គង់រ៉ែសំណង់ ស៊ីម៉ង់ត៍ និងប្រភេទរ៉ែសំខាន់ៗផ្សេងៗទៀត ដើម្បីបំពេញសេចក្តីត្រូវការក្នុងស្រុកស្របតាមការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ទូទាំងប្រទេស ព្រមជាមួយនេះ បន្តទប់ស្កាត់ និងលុបបំបាត់សកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យ ។

- ជំរុញការអភិវឌ្ឍអណ្តូងប្រេងកាត ឱ្យដំណើរការផលិតប្រេងដំបូងឱ្យបានឆាប់ ទន្ទឹមនេះពង្រឹងការគ្រប់គ្រងចំណូលដែលបានមកពីធនធានទាំងនេះប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយផ្សារភ្ជាប់ជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ពង្រឹងការអនុវត្តបទដ្ឋានបច្ចេកទេសនៅតាមស្ថានីយប្រេង និងឧស្ម័នឥន្ធនៈ ដើម្បីធានាសុវត្ថិភាពប្រជាជន។

### ៧- ការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស មានការវិវត្តន៍ប្រែប្រួលលឿន និងកំពុងដើរតួនាទីយ៉ាងសំខាន់រួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា ។ គណបក្សចាត់ទុកវិស័យនេះ ជាវិស័យថ្មីមួយសម្រាប់ជំរុញជវភាពកំណើនសេដ្ឋកិច្ចផង និងការរីកចម្រើននៃសង្គមកម្ពុជាផង។

- ក្នុងបរិការណ៍នេះ ត្រូវបន្តអភិវឌ្ឍវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឱ្យកាន់តែទំនើបប្រកបដោយគុណភាពខ្ពស់ ស្របតាមស្តង់ដារអន្តរជាតិ មានតម្លៃប្រកួតប្រជែង និងមានសេវាគ្របដណ្តប់ទូទាំងប្រទេសដែលប្រជាជនទូទៅអាចប្រើប្រាស់បាន និងទទួលបានផលប្រយោជន៍ពីសេវានេះគ្រប់ៗគ្នា ពង្រីកការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងពង្រីកហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងឱ្យដល់ទីជនបទដាច់ស្រយាល និងតំបន់មានសក្តានុពលខាងសេដ្ឋកិច្ច និងទេសចរណ៍។

- បង្កើនលទ្ធភាព និងជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំងការតភ្ជាប់អ៊ីនធឺណិតល្បឿនលឿន ដែលងាយស្រួលប្រើប្រាស់ មានតម្លៃសមរម្យដល់ប្រជាជនទូទៅ ពិសេសនៅតាមតំបន់ឧស្សាហកម្ម ទេសចរណ៍ និងតាមគ្រឹះស្ថានសិក្សា ប្រកបដោយសីលធម៌ និងក្នុងក្របខ័ណ្ឌច្បាប់ តាមរយៈការពង្រីកហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ដើម្បីបម្រើដល់គោលដៅកសាងធនធានមនុស្ស អប់រំ បណ្តុះបណ្តាល និងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ ទន្ទឹមនេះ ត្រូវពង្រឹង

សមត្ថភាពនៃប្រព័ន្ធតាមដានត្រួតពិនិត្យ និងការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឱ្យកាន់តែរឹងមាំ និងកាត់បន្ថយហានិភ័យចំពោះសង្គម ។

- រៀបចំក្របខណ្ឌ និងអភិវឌ្ឍប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិកទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាព សន្សំសំចៃពេលវេលា និងថវិកា ដោយបន្តពង្រឹងតួនាទីស្ថាប័នបណ្តុះបណ្តាលធនធានមនុស្ស និងកសាងក្របខណ្ឌគតិយុត្តិ ។

- ជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការបង្កើនអត្រាមន្ត្រីរាជការចេះប្រើប្រាស់ប្រព័ន្ធសុសវែរ (Software) និងកម្មវិធីមូលដ្ឋាន បង្កើនអត្រាសិស្សានុសិស្សដែលបញ្ចប់ការសិក្សាថ្នាក់ទុតិយភូមិមានបំណិនវិជ្ជាជីវៈបច្ចេកវិទ្យាគមនាគមន៍ និងពត៌មាន និងបង្កើនអត្រាធនធានមនុស្សមានជំនាញវិជ្ជាជីវៈនេះឱ្យកាន់តែច្រើនឡើង ។ បង្កើនសមត្ថភាព និងជំរុញការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅតាមសកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវនានា ដោយផ្តោតលើមុខវិជ្ជាអាទិភាពពិសេសជំនាញថ្មីៗដែលកើតចេញពីតម្រូវការការងារ ក្នុងបរិបទ និងនិន្នាការបច្ចេកវិទ្យាពិភពលោក និងសេដ្ឋកិច្ចឌីជីថល ។

- បន្តរៀបចំប្រព័ន្ធប្រៃសណីយ៍ឱ្យមានលក្ខណៈទំនើប ទាន់សម័យ ប្រកបដោយគុណភាពខ្ពស់ មានស្តង់ដារអន្តរជាតិ បង្កលក្ខណៈងាយស្រួល និងផ្តល់ភាពជឿទុកចិត្តលើការប្រើប្រាស់សេវាព្រមជាមួយនឹងការពង្រីកសេវាប្រៃសណីយ៍ឱ្យដល់គ្រប់មូលដ្ឋានភូមិ ឃុំ។ លើកកម្ពស់ការធ្វើប្រតិបត្តិការបណ្តាញប្រៃសណីយ៍អន្តរជាតិ និងបន្តបង្កើតសេវាថ្មីៗបន្ថែមទៀតតាមតម្រូវការទីផ្សារបច្ចុប្បន្ន និងតាមបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានប្រកបដោយគុណភាព។

- បន្តអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិ និងលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយឯកជនក្នុងការពង្រីកវិសាលភាពនៃការផ្សាយឱ្យបានទូលំទូលាយក្នុងប្រទេស ក្នុងតំបន់ និងទ្វីបនានា ដើម្បីផ្តល់ព័ត៌មាន ការអប់រំ និងការកំសាន្តប្រកបដោយគុណភាព និងសមធម៌ ។ លើកកម្ពស់គុណភាពនៃកម្មវិធីផ្សាយព័ត៌មាន ដែលឆ្លុះបញ្ចាំងពីគ្រប់ទិដ្ឋភាពនៃជីវភាពសង្គមកម្ពុជា ជាព័ត៌មានពិត និងត្រឹមត្រូវ ដោយឈរលើស្មារតីទទួលខុសត្រូវ និងការគោរពសីលធម៌វិជ្ជាជីវៈ ។ ព្រមជាមួយនេះ បន្តអប់រំ ទប់ស្កាត់ និងលុបបំបាត់សកម្មភាពផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន រូបភាព ឯកសារ និងសំណេរ ។ល។ ដែលមានចរិតញុះញង់ បំបែកបំបាក់ បំភ្លៃការពិត បំប៉ោងសភាពការណ៍ បង្កអសន្តិសុខ អសណ្តាប់ធ្នាប់ និងអសីលធម៌ ប្រាសចាកវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ខ្មែរតាមគ្រប់រូបភាព សំដៅធានាសន្តិភាព សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងភាពថ្លៃថ្នូរនៃសង្គមជាតិ។

### ខ.៦.៦- ការអភិវឌ្ឍទេសចរណ៍ វប្បធម៌ និងសាសនា

### ១- ការអភិវឌ្ឍទេសចរណ៍

- កម្ពុជាមានសម្បត្តិវប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិតាំងពីបរមបុរាណ ដែលបានបង្ហាញតាមរយៈប្រាសាទបុរាណ ទីសក្ការៈបូជា វប្បធម៌ ទំនៀមទម្លាប់ សិល្បៈ របាំចម្រៀង ទឹកដី ព្រៃភ្នំ បឹងបួ ទន្លេ សមុទ្រ និងរមណីយដ្ឋាននានាជាច្រើន។ គណបក្សចាត់ទុកវិស័យទេសចរណ៍ជា "មាសបៃតង"

និងជាកម្លាំងចលករមួយដ៏សំខាន់ក្នុងការជំរុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ដោយកំណត់យកឆ្នាំ ២០២៣ ជាឆ្នាំគោលដៅសម្រេចការអភិវឌ្ឍទេសចរណ៍ដែលមានភ្ញៀវទេសចរអន្តរជាតិមកកម្ពុជានឹងកើនឡើងដល់ប្រមាណ៩លាននាក់ និងទេសចរក្នុងស្រុកកើនឡើងដល់ប្រមាណ១៥លាននាក់ ស័ក្តិសមនឹងទិសស្លោក " កម្ពុជា ព្រះរាជាណាចក្រអច្ឆរិយៈផ្តល់ភាពកក់ក្តៅ " ។

- បន្តអភិវឌ្ឍផលិតផលទេសចរណ៍ទាំងផ្នែករឹង (រមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ និងកែច្នៃ) និងទាំងផ្នែកទន់ (វប្បធម៌ ទំនៀមទម្លាប់ សិល្បៈ...) ជាមួយនឹងការលើកកម្ពស់ស្តង់ដាររបស់សណ្ឋាគារ ភោជនីយដ្ឋាន តំបន់ទេសចរណ៍ សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ព្រមទាំងគ្រប់គ្រងអនាម័យ បរិស្ថានឲ្យបានល្អប្រសើរ។

- ខិតខំរក្សាទីផ្សារទេសចរណ៍ដែលមានស្រាប់ និងពង្រីកទីផ្សារថ្មីៗបន្ថែមទៀត ដោយបង្កើនវិសាលភាពនៃការផ្សព្វផ្សាយទេសចរណ៍ឱ្យបានកាន់តែទូលាយ ទាំងនៅក្នុងស្រុក និងក្រៅស្រុក ជាមួយនឹងការសិក្សាស្រាវជ្រាវបន្ថែម ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយរវាងស្ថាប័នពាក់ព័ន្ធទាំងអស់។ ពង្រឹង និងពង្រីកផលិតផលទេសចរណ៍ សម្រាប់ផ្គត់ផ្គង់តម្រូវការទីផ្សារទេសចរណ៍ ដោយផ្តោតលើការធ្វើពិពិធកម្ម និងលើកកម្ពស់គុណភាពផលិតផលដែលមានស្រាប់ ព្រមទាំងបង្កើតផលិតផលថ្មី ស្របតាមតម្រូវការទីផ្សារជាក់ស្តែង ។ លើសពីនេះ ត្រូវបន្តពង្រឹងការអនុវត្តយុទ្ធសាស្ត្រទីផ្សារទេសចរណ៍កម្ពុជា និងសៀវភៅសទាក់ទាញទីផ្សារចិន សំដៅទាក់ទាញភ្ញៀវទេសចរអន្តរជាតិដែលមានសក្តានុពលខ្លាំង ។

- ជំរុញឧត្តមភាពប្រកួតប្រជែង និងលើកកម្ពស់កិត្យានុភាពកម្ពុជាលើឆាកអន្តរជាតិ តាមរយៈសម្បត្តិវប្បធម៌ សំដៅប្រែក្លាយកម្ពុជាទៅជាគោលដៅទេសចរណ៍កម្រិតតំបន់ និងពិភពលោកប្រកបដោយភាពទាក់ទាញ (សុខសន្តិភាព សុវត្ថិភាព ផាសុកភាព គុណភាព ភាពជឿជាក់ និងស្មោះត្រង់)។ ជាមួយគ្នានេះ លើកកម្ពស់ចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" និងចលនាប្រឡងប្រណាំងធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ។

- ពង្រឹងគុណភាពបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ (មគ្គុទ្ទេសក៍ទេសចរណ៍ និងជំនាញវិជ្ជាជីវៈ) លើកកម្ពស់គុណភាព សមត្ថភាព ក្រមសីលធម៌ និងបច្ចេកទេសតាមរយៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈច្បាស់លាស់ ភាសាបរទេស និងការផ្តល់សេវាកម្មជូនភ្ញៀវ ដើម្បីធានាស្ថិរភាពទីផ្សារការងារ និងការផ្គត់ផ្គង់កម្លាំងពលកម្មនៅក្នុងវិស័យនេះ។ ព្រមជាមួយនេះ ជំរុញការផ្តល់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈពង្រឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងវិស័យទេសចរណ៍ ។

## ២- ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌

- ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ខ្មែរដោយចីរភាពជាកិច្ចការដ៏មានសារៈសំខាន់ចាំបាច់ ដើម្បីធានាអត្ថិភាពដ៏រឹងមាំនៃអត្តសញ្ញាណជាតិ ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម លើកកម្ពស់សីលធម៌ និង

ពង្រឹងភាពសុខដុមនៃសង្គមជាតិ ។ គណបក្សបន្តពង្រឹងកិច្ចការពារ ថែរក្សា និងអភិវឌ្ឍរាល់បេតិកភណ្ឌវប្បធម៌ជាតិទាំងរូបី និងអរូបី ឲ្យស្ថិតស្ថេរគង់វង្សជានិរន្តរ៍ ។ ប្រើប្រាស់សក្តានុពលវប្បធម៌ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនស្របតាមអត្ថន័យ "វប្បធម៌ជាសេដ្ឋកិច្ច" ។ ផ្សព្វផ្សាយអប់រំបង្កើនការយល់ដឹងរបស់ប្រជាជន ជាពិសេសស្រទាប់យុវវ័យអំពីតម្លៃដ៏វិសេសវិសាលនៃវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទម្លាប់ខ្មែរ និងភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ហើយចូលរួមថែរក្សាលើកស្ទួយប្រកបដោយមនសិការ ព្រមទាំងទប់ស្កាត់ និងលុបបំបាត់វប្បធម៌អវិជ្ជមានទាំងឡាយដែលមានផលប៉ះពាល់ដល់វប្បធម៌ជាតិ ។

- បន្តថែរក្សាជួសជុល ទល់ទ្រប្រាសាទបុរាណ ស្ថានបុរាណ និងបុរាណស្ថាននានាដែលមាននៅពាសពេញប្រទេសឲ្យមាននិរន្តរភាព ជាមួយនឹងការពង្រឹងយន្តការ និងបទដ្ឋានគតិយុត្តិនានា ដើម្បីធានាដល់ការអភិរក្ស និងការអភិវឌ្ឍវប្បធម៌ ព្រមទាំងរាំងស្កាត់មិនឲ្យមានការរំលោភ និងបំផ្លាញបេតិកភណ្ឌវប្បធម៌។ បន្តរៀបចំព្រឹត្តិការណ៍សិល្បៈ វប្បធម៌ និងការផ្សព្វផ្សាយឲ្យបានច្រើន ទាំងក្នុងប្រទេស និងនៅក្រៅប្រទេស ដើម្បីលើកកម្ពស់ការយល់ដឹង ការស្រឡាញ់ ការចូលរួមថែរក្សា ការពារសម្បត្តិវប្បធម៌ជាតិ និងទាក់ទាញភ្ញៀវទេសចរបានកាន់តែច្រើនមកទស្សនាកម្ពុជាដែលជា "ព្រះរាជាណាចក្រមួយនៃវប្បធម៌" ។

- បង្កើនការអប់រំ បណ្តុះបណ្តាលអ្នកតែងនិពន្ធ អ្នកដឹកនាំរឿង ដឹកនាំការសម្តែង សិល្បករសិល្បការិនីលើរាល់ទម្រង់សិល្បៈដើម្បីរក្សាគ្រប់ទម្រង់សិល្បៈឲ្យបានគង់វង្ស ជាពិសេសទម្រង់សិល្បៈមួយចំនួនដែលប្រឈមនឹងការបាត់បង់ និងយកចិត្តទុកដាក់លើកស្ទួយកិត្តិយសរបស់សិល្បករឆ្នើមៗដែលជាមរតកមនុស្សរស់ដ៏មានតម្លៃនៅក្នុងវិស័យវប្បធម៌។ បញ្ចូលមុខវិជ្ជាវប្បធម៌ សិល្បៈ ទៅក្នុងកម្មវិធីសិក្សា ដោយឈរលើគោលការណ៍ "ការអប់រំដើម្បីវប្បធម៌ វប្បធម៌ដើម្បីការអប់រំ"។ ទន្ទឹមនេះខិតខំដកស្រង់ ច្នៃប្រឌិត និងប្រើប្រាស់ចំណេះដឹងថ្មីៗនៃវប្បធម៌សកល សំដៅជំរុញការអភិវឌ្ឍវប្បធម៌ជាតិឲ្យកាន់តែមានភាពសម្បូរបែប ដោយឈរលើការរក្សាអត្តសញ្ញាណជាតិ។

- ជំរុញការអភិវឌ្ឍសហគមន៍វប្បធម៌ ដោយធ្វើឱ្យអ្នកពាក់ព័ន្ធទទួលបានផលប្រយោជន៍ពីវប្បធម៌ប្រកបដោយសមធម៌ ។ យកចិត្តទុកដាក់បង្កើនផលិតផលវប្បធម៌ និងទីផ្សារវប្បធម៌ឱ្យកាន់តែទូលាយទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស។ ពង្រឹងការផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង ចំណេះធ្វើ បទពិសោធន៍ បច្ចេកទេស និងបង្កើនការវិនិយោគលើវិស័យវប្បធម៌។

- លើកកម្ពស់សហប្រតិបត្តិការអន្តរជាតិក្នុងការអភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ជាតិ បន្តជំរុញការចុះបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក បញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ និងក្នុងបញ្ជីស្មារតីចងចាំនៃពិភពលោករបស់អង្គការយូណេស្កូ ព្រមជាមួយនេះបន្តខិតខំប្រមូលវត្ថុបុរាណនានាដែលស្ថិតនៅរាយប៉ាយក្នុងប្រទេស និងទាមទារយកមកវិញនូវវត្ថុបុរាណខ្មែរដែលត្រូវគេលួចយកចេញពីកម្ពុជាទៅបរទេសមកថែរក្សាឲ្យបានគង់មង់ ។

### ៣- ការអភិវឌ្ឍវិស័យសាសនា

- គោរពសេរីភាពខាងជំនឿ និងសាសនា លើកស្ទួយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ និងគាំទ្រការគោរពប្រតិបត្តិសាសនាផ្សេងៗទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ខិតខំធ្វើឱ្យវត្តអារាម និងវិហារសាសនាឯទៀតៗ ក្លាយជាមជ្ឈមណ្ឌលមួយនៃជីវភាពខាងស្មារតី ដែលចូលរួមសកម្មក្នុងការអភិវឌ្ឍសង្គមជាតិខាងផ្នែកវប្បធម៌ អប់រំ សុខាភិបាល សង្គមកិច្ច និងសីលធម៌សង្គម។

- ពង្រឹងសុខដុមនីយកម្មរវាងគ្រប់សាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជា រាំងស្កាត់ការធ្វើអាជីវកម្មលើសាសនា ប្រឆាំងការរើសអើង បែងចែកក្នុងចំណោមប្រជាជនដែលបណ្តាលមកពីភាពខុសគ្នាខាងជំនឿ និងសាសនា សំដៅប្រែក្លាយសក្តានុពលរបស់សាសនាទាំងអស់ ទៅជាកម្លាំងសាមគ្គីដ៏ខ្លាំងក្លាក្នុងការការពារសន្តិភាព ឯកភាពជាតិ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ។

- បន្តពង្រឹងពង្រីកការអប់រំពុទ្ធិកសិក្សាពីកម្រិតបឋមសិក្សាដល់ឧត្តមសិក្សា ។ ថែរក្សាមរតកប្រពៃណី និងទំនៀមទម្លាប់ក្នុងវិស័យពុទ្ធចក្រ បណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យសាសនា បណ្តុះបណ្តាលធនធានព្រះសង្ឃប្រកបដោយចំណេះដឹង គុណធម៌ ប្រកាន់ក្រឹត្យវិន័យបានខ្ជាប់ខ្ជួនតាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត។ បន្តជំរុញការស្រាវជ្រាវ និងបកប្រែគម្ពីរភាសាបាលី ក្បួនច្បាប់ព្រះពុទ្ធសាសនាជាភាសាបរទេសមកជាភាសាខ្មែរ បន្តបោះពុម្ពគម្ពីរដីកា ព្រឹត្តិបត្រមហាសង្ក្រាន្តប្រវត្តិនៃវត្តទូទាំងប្រទេស សៀវភៅតួនាទី ភារកិច្ច ក្រមសីលធម៌របស់ព្រះមេគណ អនុគណ ចៅអធិការ អាចារ្យ សៀវភៅប្រជុំបុណ្យទំនៀមទម្លាប់ខ្មែរ ។ល។ ទន្ទឹមនោះបន្តជំរុញការបណ្តុះបណ្តាលធនធានមនុស្សនៃសាសនាផ្សេងៗទៀត។

## ខ.៦.៧- ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស

### ១-ការអភិវឌ្ឍវិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកទេស និងបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ

- ជំរុញការអភិវឌ្ឍធនធានមនុស្សលើគ្រប់វិស័យប្រកបដោយគុណភាព ដែលមានភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការស្នេហាជាតិ និងមនុស្សជាតិ ជាពិសេសស្របតាមតម្រូវការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា ឧស្សាហកម្ម សំដៅប្រែក្លាយកម្ពុជាទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។ ក្នុងទិសដៅនេះ គណបក្សបន្តលើកកម្ពស់គុណភាពនៃការអប់រំប្រកបដោយសមធម៌ និងបរិយាប័ន្នព្រមទាំងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ជំរុញការសិក្សាអប់រំលើជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ពីកម្រិតបឋមសិក្សារហូតដល់ក្រោយមធ្យមសិក្សា។

- បន្តការកែទម្រង់វិស័យអប់រំ ដោយបង្គលក្ខណៈកាន់តែច្រើនក្នុងការពង្រីកសេវាអប់រំកុមារតូចតាមគ្រប់រូបភាព សម្រាប់កុមារអាយុពីសូន្យឆ្នាំទៅក្រោម ៦ ឆ្នាំ បង្កើនការចូលរៀន និងពង្រឹងការរៀនមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រនៅកម្រិតអប់រំចំណេះទូទៅ បង្កើនអត្រាអក្ខរកម្មមនុស្សពេញវ័យ ផ្តល់ការអប់រំពហុភាសាដល់កុមារជនជាតិដើមភាគតិច ផ្តល់សេវាអប់រំពិសេសដល់កុមារពិការ

និងការអប់រំបំណិនជីវិតនៅតាមសាលាមធ្យមសិក្សា ។ ជំរុញការបង្កើតថ្នាក់មត្តេយ្យសិក្សាគ្រប់រូបភាព កសាងសាលាបឋមសិក្សាឱ្យបានដល់ភូមិ អនុវិទ្យាល័យឱ្យបានគ្រប់ឃុំ និងវិទ្យាល័យឱ្យបានគ្រប់ស្រុក ពង្រីកចំនួនសាលារៀនជំនាន់ថ្មីនៅគ្រប់កម្រិត សាងសង់អគារសិក្សាថ្មី និងជួសជុលអគារសិក្សាទ្រុឌទ្រោម សាងសង់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បណ្ណាល័យ និងបន្ទប់កុំព្យូទ័រ រៀបចំទឹកស្អាត និងបង្គន់អនាម័យ ។ បំផុសចលនាជាតិ និងបង្កើនការចូលរួមនៃផ្នែកឯកជន ព្រមទាំងដៃគូអភិវឌ្ឍនានា ដើម្បីអភិវឌ្ឍវិស័យអប់រំ ។ កាត់បន្ថយចំណាយរបស់មាតាបិតាសិស្ស បង្កើនថវិកាសម្រាប់គ្រឹះស្ថានសិក្សា ពង្រាយគ្រូបង្រៀនឱ្យដល់គ្រប់ទីកន្លែង ពង្រីកអន្តេវាសិកដ្ឋាននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រឹះស្ថានឧត្តមសិក្សា ។

- បង្កើនគុណភាពអប់រំនិងភាពឆ្លើយតបទៅនឹងទីផ្សារការងារ តាមរយៈការយកចិត្តទុកដាក់លើគុណភាពនៃការអប់រំចំណេះទូទៅ ការអប់រំបច្ចេកទេស និងឧត្តមសិក្សាទាំងក្នុងគ្រឹះស្ថានសិក្សារដ្ឋទាំងគ្រឹះស្ថានសិក្សាឯកជន ដូចជាការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន អភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន អភិវឌ្ឍន៍កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល ការពង្រឹងវិធីសាស្ត្របង្រៀន និងរៀនតាមបែបថ្មី ការលើកកម្ពស់ការគ្រប់គ្រងនៅតាមសាលារៀន ពង្រឹងទំនាក់ទំនងជិតស្និទ្ធរវាងសាលា និងមាតា បិតា សិស្ស ប្រារព្ធទិវាជាតិអំណាន ធ្វើអធិការកិច្ច ពង្រឹងការប្រឡងគ្រប់ប្រភេទ អនុវត្តតេស្តវាយតម្លៃលទ្ធផលសិក្សាសិស្ស បង្កើតកម្មវិធីស្រាវជ្រាវផ្តោតលើការបណ្តុះបណ្តាលគ្រូ វិធីសាស្ត្របង្រៀន និងនិន្នាការថ្មីៗក្នុងវិស័យអប់រំ ព្រមទាំងការបង្កើនការស្រាវជ្រាវ និងនវានុវត្តន៍នៅឧត្តមសិក្សា។

- លើកកម្ពស់តម្លៃវិជ្ជាជីវៈ និងកិត្តិយសគ្រូបង្រៀន តាមរយៈការប្រារព្ធទិវាគ្រូបង្រៀនជារៀងរាល់ឆ្នាំនៅថ្ងៃ ៥ តុលា ដែលជាទិវារំឭកគុណគ្រូសម្រាប់ជាការចងចាំនៃយុវជនគ្រប់ជំនាន់ ការបង្កើនប្រាក់បៀវត្សជូនគ្រូបង្រៀនដើម្បីកែលម្អលក្ខខណ្ឌការងារ និងការរស់នៅ ការអនុវត្តគន្លងអាជីពគ្រូបង្រៀន។

- បន្តអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយគុណភាព និងជំនាញច្បាស់លាស់ ស្របតាមតម្រូវការទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស។ បន្តផ្តល់អាហារូបករណ៍ និងបង្កលក្ខណៈងាយស្រួលដល់យុវជន យុវនារី ឲ្យទទួលបានការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមគ្រប់រូបភាព ទាំងរដ្ឋ និងឯកជន និងបន្តជំរុញកម្មវិធីលើកកម្ពស់ផលិតភាពជាតិ ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងរបស់ជាតិនៅក្នុងតំបន់ ជាពិសេសក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។

### ២- ការលើកកម្ពស់សុខភាពប្រជាជន

- បន្តអភិវឌ្ឍវិស័យសុខាភិបាល សំដៅធានាឲ្យប្រជាជនគ្រប់រូបទទួលបានសេវាថែទាំសុខភាព ដែលមានគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាព ប្រកបដោយសមធម៌ ដោយផ្តោតលើគោលដៅធំ ២ គឺ:

**១.** បង្កើនលទ្ធភាពរបស់ប្រជាជនឲ្យទទួលបាន និងប្រើប្រាស់សេវាអប់រំសុខភាព លើកកម្ពស់សុខុមាលភាព សេវាបង្ការ ព្យាបាល ថែទាំ ស្តារនីតិសម្បទា ក្នុងតម្លៃចំណាយមួយដែលអាចរ៉ាប់រងបានដើម្បីសម្រេចគោលបំណងក្នុងការ : • លើកកម្ពស់សុខភាពបន្តពូជ បន្ថយការស្លាប់ មាតា ទារក និងកុមារ និងកែលម្អកង្វះអាហារូបត្ថម្ភ ក្នុងចំណោមស្ត្រី និងកុមារ • បន្ថយការឈឺ និងស្លាប់ ដោយជំងឺឆ្លងជាពិសេសមេរោគអេដស៍/ ជំងឺអេដស៍ របេង គ្រុនចាញ់ និងជំងឺឆ្លងដែលលេចឡើង និងលេចឡើង

សាជាថ្មី •បន្ថយការឈឺ និងស្លាប់ដោយជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ មានជាអាទិ៍ ទឹកនោមផ្អែម ឡើងសម្ពាធឈាម ជំងឺមហារីក ជំងឺផ្លូវដង្ហើម ជំងឺផ្លូវចិត្ត និងការបំពានគ្រឿងញៀន បង្ការ និងគ្រប់គ្រងការចុះខ្សោយចក្ខុវិញ្ញាណ ការចុះខ្សោយសោតវិញ្ញាណ ពិការភាព និងជំងឺចាស់ជរា ។

២.បន្ថយចំណាយរបស់ប្រជាជននៅពេលមកទទួល និងប្រើប្រាស់សេវា សុខភាព ពិសេសប្រជាជនក្រីក្រ ជនងាយរងគ្រោះ ស្ត្រី និងកុមារ ដោយបង្កើនចំណាយថវិកាជាតិលើការថែទាំសុខភាពប្រជាជន និងបង្កើនការគ្របដណ្តប់នៃប្រព័ន្ធគាំពារសុខភាពសង្គម ឲ្យឈានទៅគ្របដណ្តប់សេវាសុខភាពជាសាកល ។

- ប្រជាជនក្រីក្រ ជនពិការ និងមនុស្សចាស់ជរាគ្មានទីពឹង ទទួលបានការប្រើប្រាស់សេវាថែទាំសុខភាពដោយឥតបង់ថ្លៃ នៅប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព និងមន្ទីរពេទ្យសាធារណៈទូទាំងប្រទេស តាមរយៈការពង្រីកមូលនិធិសមធម៌សុខាភិបាល។

- បង្កើនការគ្របដណ្តប់ និងលទ្ធភាពទទួលបានសេវានានារួមមាន : សេវាសុខភាពបន្តពូជមានគុណភាព ជាពិសេសសម្រាប់ស្ត្រី និងយុវវ័យ សេវាថែទាំគភ៌មុនសម្រាល សម្រាលមានសុវត្ថិភាព ថែទាំក្រោយសម្រាល សេវាសម្ភព សង្គ្រោះបន្ទាន់ និងថែទាំទារក ព្រមទាំងសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន វ៉ាក់សាំងបង្ការជំងឺ សេវាពិនិត្យព្យាបាលជំងឺកុមារ និងសេវាអាហារូបត្ថម្ភដើម្បីបន្ថយកង្វះថាមពលជាតិសាច់ និងមីក្រូសារជាតិក្នុងចំណោម ស្ត្រី និងកុមារតូច។

- លុបបំបាត់ករណីថ្មីនៃការចម្លងមេរោគអេដស៍ និងបន្តកាត់បន្ថយការស្លាប់ដែលទាក់ទងនឹងមេរោគអេដស៍ / ជំងឺអេដស៍។ ខិតខំលុបបំបាត់ជំងឺគ្រុនចាញ់នៅត្រឹមឆ្នាំ២០២៥។ បង្កើនការស្រាវជ្រាវរកករណីរបេង និងរក្សាកម្រិតខ្ពស់នៃការព្យាបាលជាសះស្បើយនៃជំងឺរបេងគ្រប់សណ្ឋាន ។ បង្កើនការគ្របដណ្តប់ និងលទ្ធភាពទទួលសេវាគ្រប់គ្រងជំងឺឆ្លងដទៃទៀត ដូចជាជំងឺដង្កូវព្រូន ដែលបណ្តាលមកពីជំងឺតំបន់ត្រូពិក ជំងឺឆ្លងលេចឡើងថ្មី និងលេចឡើងម្តងទៀត និងជំងឺឆ្លងពីសត្វមកមនុស្ស ។ ពង្រឹងការអនុវត្តច្បាប់សុខភាពអន្តរជាតិ ព្រមទាំងពង្រឹងប្រព័ន្ធជាតិអង្កេតតាមដាន និងឆ្លើយតបទៅនឹងជំងឺ។

- បន្ថយការប្រឈមរបស់ប្រជាជននឹងកត្តាហានិភ័យនៃជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ មានជាអាទិ៍ជំងឺមហារីក ទឹកនោមផ្អែម និងជំងឺបេះដូង សរសៃឈាម លើកកម្ពស់ការស្រាវជ្រាវជំងឺមិនឆ្លង និងបង្ការនៅដំណាក់កាលបឋមឲ្យបានទាន់ពេលវេលា។

- បង្កើនការទទួលបាន និងការគ្របដណ្តប់នៃសេវាបឋម និងគ្រប់ជ្រុងជ្រោយនៃសុខភាពផ្លូវចិត្ត និងសេវាព្យាបាលបន្សាបការញៀន ព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីហានិភ័យនៃជំងឺផ្លូវចិត្ត និងគ្រឿងញៀន។ ជំរុញការបន្ថយការប្រើប្រាស់បំពានថ្នាំញៀន គ្រឿងញៀនស្រវឹង និងថ្នាំជក់ក្នុងចំណោមប្រជាជនទូទៅ។

- បង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឧបករណ៍ និងបច្ចេកវិទ្យាវេជ្ជសាស្ត្រ សម្រាប់មូលដ្ឋានសុខាភិបាល និងការវិនិយោគលើបច្ចេកវិទ្យាព័ត៌មានបម្រើវិស័យសុខាភិបាល។ បន្តជំរុញការកសាងមណ្ឌលសុខភាពឲ្យបាននៅគ្រប់ឃុំដែលពុំទាន់មាននៅឡើយ។ ពង្រឹងប្រព័ន្ធបណ្តុះបណ្តាលដែលផ្តោតទៅលើសមត្ថភាព ជំនាញឯកទេស និងអភិវឌ្ឍប្រព័ន្ធទទួលស្គាល់គុណភាពបណ្តុះបណ្តាល និងទទួលស្គាល់គ្រឹះស្ថានបណ្តុះបណ្តាល ។ យកចិត្តទុកដាក់ពង្រីកធនធានមនុស្សឲ្យឆ្លើយតបនឹង

សំណួមពរនៃការលើកកម្ពស់សុខភាពរបស់ប្រជាជន ជាពិសេសនៅមូលដ្ឋាន។ បន្តពង្រាយបុគ្គលិកសុខាភិបាលមានសមត្ថភាព និងពហុជំនាញដោយសមធម៌ និងពង្រឹងយន្តការលើកទឹកចិត្តដ៏សមរម្យ ។

- ពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងនីតិក្រមសុខាភិបាល សម្រាប់អ្នកមានវិជ្ជាជីវៈសុខាភិបាល អ្នកផ្តល់សេវាសុខាភិបាលទាំងផ្នែកសាធារណៈ និងឯកជន ព្រមទាំងពង្រឹងការត្រួតពិនិត្យគុណភាពផលិតផលឱសថ។

- ជំរុញការផ្លាស់ប្តូរឥរិយាបថ និងការប្រាស្រ័យទាក់ទងរបស់អ្នកផ្តល់សេវា និងអ្នកប្រើប្រាស់សេវាប្រកបដោយសីលធម៌ និងមានការទទួលខុសត្រូវទាំងអស់គ្នា លើកកម្ពស់ការប្រតិបត្តិ «សិទ្ធិអតិថិជន និងសិទ្ធិអ្នកផ្តល់សេវា» ការប្រតិបត្តិរបៀបរបបរស់នៅមានសុខភាព និងឥរិយាបថល្អក្នុងការស្វែងរកការថែទាំសុខភាព។

- ពង្រឹងកិច្ចសហប្រតិបត្តិការពហុវិស័យទាំងជាតិ និងអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាសុខភាព និងបញ្ហាពាក់ព័ន្ធសុខភាព ដោយរួមទាំងភាពជាដៃគូរវាងផ្នែកសុខាភិបាលសាធារណៈ និងផ្នែកឯកជន។

## ខ.៦.៨- ការអភិវឌ្ឍការងារ និងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម

### ១- ការអភិវឌ្ឍការងារ និងមុខរបរ

- រក្សាការងារ និងបង្កើនការងារជូនប្រជាជន ដោយបន្តអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ដើម្បីបង្កើនភាពសុខដុមរមនាក្នុងសង្គម បង្កើនឱកាសការងារសមរម្យនិងមានផលិតភាពខ្ពស់ លើកកម្ពស់ការអភិវឌ្ឍជំនាញ និងធនធានមនុស្ស ។

- បន្តដំឡើងប្រាក់ឈ្នួលអប្បបរមាជារៀងរាល់ឆ្នាំ សម្រាប់ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ព្រមទាំងអនុវត្តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមាដែលនឹងគ្របដណ្តប់វិស័យផ្សេងទៀត ជាពិសេសវិស័យកម្មន្តសាល សំណង់ និងសណ្ឋាគារ។

- បន្តជួយសម្រាលបន្ទុកចំណាយរបស់កម្មករ និយោជិត តាមរយៈការពង្រីកការតបណ្តាញអគ្គិសនី និងទឹកស្អាតដោយតម្លៃសមរម្យជូនកម្មករនិយោជិត សិស្ស និស្សិត នៅតាមផ្ទះជួល និងជំរុញការអនុវត្តច្បាប់ស្តីពីភតិសន្យាពិសេស (ច្បាប់ជួលបន្ទប់) ព្រមទាំងបន្តលើកលែងពន្ធចំពោះប្រាក់អត្ថប្រយោជន៍បន្ថែម ក៏ដូចជាបន្តកែសម្រួលកម្រិតប្រាក់បៀវត្សរ៍អប្បបរមាត្រូវជាប់ពន្ធ។

- បង្កើនអនាម័យ និងសុវត្ថិភាពនៅកន្លែងធ្វើការងារ និងជំរុញការរៀបចំកន្លែងស្នាក់នៅ និងមធ្យោបាយធ្វើដំណើរសម្រាប់កម្មករ និយោជិតដោយសុវត្ថិភាព។

- ធានាសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ដើម្បីការពារសិទ្ធិសេរីភាព និងផលប្រយោជន៍របស់កម្មករ និយោជិត និងនិយោជកស្របតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព និងអនុសញ្ញាអន្តរជាតិខាងការងារ និងដើម្បីធានានូវភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ។

- បន្តពង្រឹងអភិបាលកិច្ចទីផ្សារការងារ និងពង្រីកសេវារកការងារធ្វើសម្រាប់ប្រជាជន ព្រមទាំងបង្ការ និងទប់ស្កាត់រាល់អំពើជួញដូរពលកម្ម។

- បន្តអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារ ដោយបន្តពង្រីកកិច្ចសហប្រតិបត្តិ-ការជាមួយប្រទេសនានា ដើម្បីបើកទូលាយទីផ្សារការងារនៅក្រៅប្រទេសសម្រាប់ប្រជាជន ព្រមទាំងផ្តល់

ការគាំពារសិទ្ធិ ផលប្រយោជន៍ សេចក្តីថ្លៃថ្នូររបស់ពលករ ជួយសម្របសម្រួលទំនាក់ទំនងគ្រួសារពលករចំណាកស្រុក និងជំរុញការបង្កើតឱកាសការងារក្នុងប្រទេសសម្រាប់សមាហរណកម្មពលករដែលត្រឡប់មកមាតុភូមិវិញ។

- ពង្រឹងប្រព័ន្ធអធិការកិច្ចការងារ និងយន្តការដោះស្រាយវិវាទការងារឲ្យកាន់តែមានប្រសិទ្ធភាព។

- បន្តអភិវឌ្ឍមុខរបរជូនប្រជាពលរដ្ឋ ដោយភ្ជាប់សកម្មភាពសេដ្ឋកិច្ចក្នុងសហគមន៍ទៅនឹងសកម្មភាពសេដ្ឋកិច្ចជាតិ បញ្ជ្រាបនូវបច្ចេកទេសកែច្នៃកសិផល ឬសេវាកម្មជូនប្រជាជនតាមសហគមន៍ និងរៀបចំយន្តការទទួលស្គាល់ជំនាញរបស់កម្មករ និយោជិត ក៏ដូចជាបញ្ជ្រាបនូវគំនិតសហគ្រិនភាព និងបង្កលក្ខណៈងាយស្រួល ដល់ប្រជាជនតាមសហគមន៍ និងកម្មករ និយោជិត ក្នុងការបង្កើតមុខរបរដោយខ្លួនឯង។

## ២- ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម

បន្តអភិវឌ្ឍ និងពង្រឹងប្រព័ន្ធគាំពារសង្គមដោយផ្តោតលើសសរស្តម្ភ២ គឺ ៖ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម ។

### ● ប្រព័ន្ធជំនួយសង្គម

- បង្កើនអន្តរាគមន៍សង្គមកិច្ច ដើម្បីជួយដល់ប្រជាជនក្រីក្រងាយរងគ្រោះ និងជនរងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ ។ ពង្រឹងកម្មវិធីសង្គ្រោះបន្ទាន់សម្រាប់ប្រជាជនក្រីក្រងាយរងគ្រោះ ទប់ស្កាត់ទុរគតភាព និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។ ពង្រឹងកម្មវិធីដោះស្រាយបញ្ហាជនអនាថា និងជនវិបល្លាសស្មារតី។ ជំរុញការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ យកចិត្តទុកដាក់ធ្វើការអភិវឌ្ឍសហគមន៍ប្រជាជនក្រីក្រ ជំរុញការកសាងលំនៅឋានសម្រាប់ប្រជាជនក្រីក្រឲ្យរស់នៅបានសមរម្យ។

- បន្តជួយប្រជាជនក្រីក្រងាយរងគ្រោះតាមរយៈការបន្តពង្រឹងមូលនិធិសមធម៌ កម្មវិធីអាហាររូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារ កម្មវិធីផ្តល់អាហារនៅតាមសាលារៀន កម្មវិធីអាហាររូបករណ៍ថ្នាក់បឋមសិក្សា មធ្យមសិក្សា និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ។

- ជំរុញកិច្ចការពារ និងលើកកម្ពស់សុខុមាលភាព និងសិទ្ធិជនពិការតាមរយៈការបង្កើនគុណភាពសេវាស្តារលទ្ធភាពពលកម្ម ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការរកការងារធ្វើជូនជនពិការ និងការអនុវត្តគោលនយោបាយឧបត្ថម្ភជនពិការក្រីក្រតាមសហគមន៍ ។ ជំរុញការទទួលយកជនពិការចូលធ្វើការនៅតាមស្ថាប័នរដ្ឋ ឯកជន និងសង្គមស៊ីវិល ស្របតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងសិទ្ធិជនពិការ។

- បន្តអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ដោយយកចិត្តទុកដាក់ជំរុញនូវកម្មវិធីអភិវឌ្ឍមនុស្សចាស់តាមសហគមន៍ និងកម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារឲ្យកាន់តែប្រសើរ។ ពង្រឹងសកម្មភាពនៃសមាគមមនុស្សចាស់នៅតាមឃុំ សង្កាត់ លើកទឹកចិត្តចំពោះការបង្កើតកម្មវិធីមនុស្សធម៌នានាដើម្បីជួយដល់ជនចាស់ជរា។ ជំរុញការរៀបចំ និងដំណើរការសេវាជនចាស់ជរាដើម្បីបណ្តុះ

បណ្ដាលភ្នាក់ងារផ្ដល់សេវាថែទាំជនចាស់ជរា។ ជំរុញដំណើរការនៃមជ្ឈមណ្ឌលគាំពារមនុស្សចាស់ជរាក្រីក្រ គ្មានទីពឹង និងបណ្ដុះបណ្ដាលបុគ្គលិកភ្នាក់ងារផ្ដល់សេវាថែទាំជនចាស់ជរា។

- លើកកម្ពស់ការអនុវត្តការងារយុវនីតិសម្បទា និងការអនុវត្តកម្មវិធីយុត្តិធម៌អនីតិជន។ ពង្រឹងការព្យាបាល ស្ដារនីតិសម្បទាសម្រាប់ជួយជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀនតាមមណ្ឌល ព្រមជាមួយនោះលើកទឹកចិត្តការព្យាបាល និងស្ដារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀននៅតាមសហគមន៍ និងនៅតាមគ្រួសារ។

- **ប្រព័ន្ធសន្តិសុខសង្គម**

- អភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមឲ្យកាន់តែរឹងមាំ និងមានវិសាលភាពទូលំទូលាយ ដោយរួមទាំងប្រជាជនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជនពិការ ចាស់ជរា និងជនងាយរងគ្រោះ តាមរយៈការពង្រឹងបេឡាជាតិរបបសន្តិសុខសង្គម បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន មូលនិធិជនពិការ មូលនិធិសមធម៌ និងមូលនិធិគន្ធបុប្ផា។

-បន្តអនុវត្តគោលនយោបាយតម្រូវឲ្យនិយោជកមានកាតព្វកិច្ចបង់ភាគទានជំនួសកម្មករនិយោជិត១០០% សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ព្រមទាំងដាក់ឲ្យអនុវត្តរបបប្រាក់សោធនដល់កម្មករនិយោជិត នៅឆ្នាំ ២០១៩ និងសិក្សាលទ្ធភាពដាក់ឲ្យដំណើរការរបបនិកម្មភាពការងារ។

- បន្តអនុវត្តគោលនយោបាយរដ្ឋបង់ភាគទានជំនួសមន្ត្រីសាធារណៈសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកសោធន និងបង់ជំនួសមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន សម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ។

- ពង្រឹងដំណើរការរបបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ និវត្តជន និងអតីតយុទ្ធជន ព្រមទាំងអ្នកនៅក្នុងបន្ទុក ។

- សិក្សាលទ្ធភាព និងឈានទៅរៀបចំដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ សំដៅសម្រេចគោលដៅនៃការគ្របដណ្ដប់សុខភាពជាសកល។

### ២.៦.៩- ការលើកកម្ពស់ស្ថានភាពស្ត្រី និងកុមារ ការអភិវឌ្ឍយុវជន និងកីឡា

### ១- ការលើកកម្ពស់ស្ថានភាពស្ត្រី និងកុមារ

- គណបក្សយកចិត្តទុកដាក់ការលើកស្ទួយតម្លៃស្ត្រីខ្មែរក្នុងសង្គម ជំរុញការអភិវឌ្ឍស្ត្រីលើគ្រប់ផ្នែក លុបបំបាត់រាល់ទស្សនៈ ឬឥរិយាបថរើសអើងចំពោះស្ត្រី សំដៅបង្កើនការចូលរួមដ៏សកម្មរបស់ស្ត្រីក្នុងការអភិវឌ្ឍប្រទេសជាតិ តាមរយៈការបន្តលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិរបស់ស្ត្រី។

- បង្កើនតួនាទីរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការពង្រីកកម្មវិធីបណ្ដុះបណ្ដាលបំពាក់បំប៉នជំនាញបច្ចេកទេស ការផ្ដល់ឱកាសការងារ ការកសាងសហគ្រិនភាព និងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី បង្កើនឱកាសរៀនសូត្ររបស់ស្ត្រី និងក្មេងស្រី ពិសេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។

- បង្កើនសមាមាត្រនៃស្ត្រីក្នុងស្ថាប័នសាធារណៈ ដើម្បីឲ្យស្ត្រីបានចូលរួមកាន់តែច្រើនឡើងក្នុងការដឹកនាំ និងការធ្វើសេចក្ដីសម្រេចនៃអភិបាលកិច្ចទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- ពង្រឹងការអនុវត្តច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ និងផែនការជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដើម្បីលុបបំបាត់នូវឥរិយាបថប្រើហិង្សាលើស្ត្រី ពង្រីកវប្បធម៌អហិង្សា លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ព្រមទាំងការកសាងគ្រួសារប្រកបដោយសុភមង្គល។

- បន្តជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍន៍គ្រប់វិស័យ និងគ្រប់កម្រិត ។

- លើកកម្ពស់ប្រព័ន្ធសុវត្ថិភាពដើម្បីសុខុមាលភាព និងសិទ្ធិរបស់កុមារ ជាពិសេសកុមារដែលបាត់បង់ឪពុកម្ដាយ ឬអាណាព្យាបាលធ្វើទេសន្តរប្រវេសន៍រយៈពេលយូរ ដោយជំរុញឲ្យទទួលបានការអប់រំ និងអនុវត្តយ៉ាងម៉ត់ចត់នូវអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមារ សំដៅធានានូវសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺ "សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍ សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួមរបស់កុមារ"។ យកចិត្តទុកដាក់ថែទាំ អប់រំ កុមារឲ្យក្លាយជា "កូនល្អ សិស្សល្អ និងមិត្តល្អ" ដែលជាអនាគតពលរដ្ឋល្អ ។

- ពង្រឹងការអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ ការថែទាំកុមារតាមគ្រួសារ និងសហគមន៍ ការបង្កើនការគ្រប់គ្រង និងគុណភាពនៃការថែទាំកុមារនៅតាមមណ្ឌលរដ្ឋ និងមណ្ឌលនៃអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអនុវត្តម៉ឺងម៉ាត់នូវអនុសញ្ញាអន្តរជាតិ និងច្បាប់ជាធរមាន ដើម្បីរកគ្រួសារល្អនៅក្នុង និងក្រៅប្រទេសសម្រាប់កុមារ រាំងស្កាត់ការធ្វើអាជីវកម្មកុមារតាមគ្រប់រូបភាព។

## ២- ការអភិវឌ្ឍយុវជន និងកីឡា

- យុវជនជាសសរទ្រូងរបស់ប្រទេសជាតិ ជាកម្លាំងបន្តវេនប្រកបដោយសក្ដានុពលក្នុងការកសាង និងការពារមាតុភូមិ ដែលតម្រូវឱ្យយុវជនត្រូវមានបុគ្គលិកលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា ស្មារតី សីលធម៌ តម្លៃ និងបំណិន។ គណបក្សបន្តជំរុញការអភិវឌ្ឍយុវជនប្រកបដោយគុណភាព និងបណ្ដុះបណ្ដាលយុវជនឲ្យមានសមត្ថភាពឈានចូលទៅក្នុងទីផ្សារការងារ ឬបង្កើតមុខរបរ ដោយផ្ដល់ឱកាសពង្រីកសក្ដានុពលរបស់ខ្លួននៅក្នុងការអប់រំ ការងារ សុខភាព ការចូលរួមធ្វើសេចក្ដីសម្រេចចិត្ត និងការរួមចំណែកអភិវឌ្ឍគ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

- បន្តពង្រីកកម្មវិធីអប់រំ និងផ្ដល់ជំនាញវិជ្ជាជីវៈបច្ចេកទេសទាំងជំនាញរឹង និងជំនាញទន់ដល់យុវជន ដែលរួមទាំងយុវជនពុំសូវមានលទ្ធភាព យុវជនងាយរងគ្រោះ និងយុវជនពិការ។ ជំរុញការបោះជំហានវិទ្យាសាស្ត្រ បច្ចេកវិទ្យា ។ លើកកម្ពស់ការអនុវត្តកម្មវិធីអប់រំសហគ្រិនភាព ចលនាយុវជនស្ម័គ្រចិត្តនៅក្នុងសាលា និងនៅតាមសហគមន៍ ។ ពង្រឹងការផ្ដល់កម្មវិធីប្រឹក្សាអាជីព មុខរបរ ការតម្រង់ទិសការសិក្សាដល់យុវជន និងការផ្ដល់សេវាព័ត៌មានទីផ្សារការងារដល់យុវជនក្នុងសាលា និងយុវជននៅតាមសហគមន៍សំដៅលើកកម្ពស់តួនាទីរបស់យុវជនក្នុងវិស័យសេដ្ឋកិច្ច ។

- បង្កើនក្របខណ្ឌឲ្យយុវជនចូលរួមក្នុងការដឹកនាំ និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងការពារ រាល់សមិទ្ធផលសង្គមតាមរយៈការបន្តអនុវត្តជាជំហានៗនូវទិសដៅយុវភាវូបនីយកម្មក្នុងការផ្តល់ការ ទទួលខុសត្រូវនៅគ្រប់លំដាប់ថ្នាក់ ។ បង្កលក្ខណៈឱ្យយុវជនបានចូលរួមពេញលេញក្នុងកិច្ចការសហ-គមន៍នៃមូលដ្ឋាន និងស្ថាប័ននានា។ ជំរុញឱ្យមានតំណាងយុវជនក្នុងគណៈកម្មការ ឬក្រុមប្រឹក្សានៅ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់សិទ្ធិក្នុងការចូលរួម ការសម្តែងមតិ និងការសម្រេចចិត្ត របស់យុវជន ដោយផ្អែកលើការទទួលបានព័ត៌មានត្រឹមត្រូវ ។ ជំរុញការបញ្ជ្រាបសេចក្តីត្រូវការរបស់ យុវជននៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍន៍គ្រប់វិស័យ និងគ្រប់កម្រិត។

- ជំរុញចលនាកាយរិទ្ធ ក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន យុវជនកាកបាទក្រហម ចូលរួម សកម្មក្នុងការអភិវឌ្ឍសង្គម ពង្រីកស្មារតីមនុស្សធម៌ និងការទទួលខុសត្រូវចំពោះខ្លួនឯង គ្រួសារ និង សង្គម។

- លើកកម្ពស់វិស័យកីឡា ជាវិស័យអាទិភាពមួយរបស់ជាតិ ដែលត្រូវខិតខំជំរុញខ្លាំង ជាពិសេស នៅពេលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាស៊ីហ្គេមលើកទី ៣២ នៅឆ្នាំ ២០២៣ ខាងមុខ។ ក្នុងទិសដៅនេះ ត្រូវបន្តជំរុញការអនុវត្តការកែទម្រង់វិស័យកីឡា និងពង្រឹងយន្តការដែលមានស្រាប់ ដើម្បីអភិវឌ្ឍវិស័យកីឡា តាមរយៈការពង្រឹងសហព័ន្ធកីឡា ការបណ្តុះបណ្តាលកីឡាករ គ្រូបង្វឹក អាជ្ញា កណ្តាល និងចៅក្រម ។ រៀបចំទីលានកីឡាតាមស្តង់ដារក្នុងគ្រឹះស្ថានសិក្សា ដោយចាប់ផ្តើមពី **១ វិទ្យាល័យក្នុង ១ រាជធានី ខេត្ត** ពង្រឹង និងពង្រីកសកម្មភាពអប់រំកាយក្នុងម៉ោងសិក្សា និងការងារកីឡា ក្រៅម៉ោងសិក្សា និងរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា។ ជំរុញលើកទឹកចិត្តមហាជន ហាត់ប្រាណជាប្រចាំដើម្បីសុខភាព ព្រមទាំងផ្សារភ្ជាប់សកម្មភាពអប់រំកាយ និងកីឡាទៅនឹងកិច្ចការ សង្គម វប្បធម៌ និងលុបបំបាត់បាតុភាពអសកម្មផ្សេងៗក្នុងសង្គម។ បង្កើនការអភិវឌ្ឍសមត្ថភាព គ្រូបង្វឹក អនុរក្ស កីឡាករ កីឡាការិនីជម្រើសជាតិ រួមទាំងកីឡាករ កីឡាការិនីថ្នាល និងរៀបចំ ព្រឹត្តិការណ៍កីឡាជាតិរៀងរាល់ ២ ឆ្នាំម្តង ឆ្ពោះទៅកាន់ការប្រកួតកីឡាស៊ីហ្គេមនាឆ្នាំ ២០២៣។

### ខ.៧- ការការពារជាតិ ការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម

#### ១- ការការពារជាតិ

- ការពារជាតិ ការពារបូរណភាពទឹកដី គឺជាកាតព្វកិច្ចរបស់ពលរដ្ឋកម្ពុជាគ្រប់រូប ដោយមាន កងយោធពលខេមរភូមិន្ទធ្វើជាស្នូល។ នៅក្នុងដំណាក់កាលដែលប្រទេសមានសន្តិភាព ទន្ទឹមនឹង កិច្ចការពារអធិបតេយ្យ បូរណភាពទឹកដី កងយោធពលខេមរភូមិន្ទមានតួនាទីសំខាន់ក្រៃលែងក្នុងការ ចូលរួមការពារសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ ការអភិវឌ្ឍ ព្រមទាំងរួមចំណែកក្នុងបុព្វហេតុ សន្តិភាព និងមនុស្សធម៌លើពិភពលោក ។

- បន្តជំរុញការកែទម្រង់កងយោធពលខេមរភូមិន្ទឲ្យស្របនឹងការវិវត្តន៍រីកចម្រើនរបស់ប្រទេស ជាតិ ជាកងកម្លាំងដែលមានឧត្តមគតិស្មោះត្រង់ដាច់ខាតចំពោះជាតិ មាតុភូមិ គោរពស្រឡាញ់ប្រជាជន មានឆន្ទៈប្រយុទ្ធប្តូរផ្តាច់ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការការពារជាតិ ការពាររាល់សមិទ្ធផលនៃ សង្គម ការពាររាជរដ្ឋាភិបាលស្របច្បាប់ដែលប្រសូត្រចេញពីប្រជាជន។

- ពង្រឹងកិច្ចការពារយ៉ាងរឹងមាំនូវអធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាលើដែនដីគោក ដែនអាកាស ដែនទឹក កោះ ឆ្នេរ ដែនសមុទ្រ តំបន់ឥតភ្ជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងខ្ពង់រាបបាតសមុទ្រ ដោយយកចិត្តទុកដាក់កសាងផែនការយុទ្ធសាស្រ្តការពារជាតិយូរអង្វែង កសាងប្រៀបការពារជាតិ ពង្រឹងប្រព័ន្ធដឹកនាំបញ្ជា ប្រព័ន្ធគាំទ្រ ផ្លូវគមនាគមន៍ជាយុទ្ធសាស្រ្ត ជាពិសេសផ្លូវយុទ្ធសាស្រ្តតាមបណ្តោយព្រំដែន លើកកម្ពស់សមត្ថភាពរបស់កងទ័ពគ្រប់ប្រភេទក្នុងការបំពេញប្រតិបត្តិការរបស់ខ្លួន កសាងភូមិ ឃុំ នៅតាមព្រំដែនជាប់ជាមួយប្រទេសជិតខាង ដែលជាមូលដ្ឋានមួយដ៏រឹងមាំសម្រាប់កិច្ចការពារបូរណភាពទឹកដី។

- បន្តធ្វើទំនើបកម្មកងយោធពលខេមរភូមិន្ទ និងបង្កើនការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យការពារជាតិ តាមរយៈការលើកកម្ពស់ការបណ្តុះបណ្តាល និងហ្វឹកហ្វឺនយោធិន ទាំងនាយ និងពលទាហាន ពង្រឹងការបំពាក់ និងគ្រប់គ្រងអាវុធយុទ្ធភណ្ឌ ការធានាភ័ស្តុភារហិរញ្ញវត្ថុ និងជីវភាពរបស់យោធិន ព្រមទាំងជំរុញការអប់រំចិត្តសាស្រ្ត និងការងារគោលនយោបាយនានាចំពោះយោធិន និងអតីតយុទ្ធជន ដើម្បីធានាឲ្យកងយោធពលខេមរភូមិន្ទបំពេញបានល្អនូវតួនាទី និងភារកិច្ចរបស់ខ្លួន ។

- ពង្រឹងការចងសម្ព័ន្ធមេត្រីរវាងក្រសួង ស្ថាប័ន ក្រុមហ៊ុន សង្គមស៊ីវិល និងប្រជាជនជាមួយកងទ័ពដែលកំពុងឈរជើងនៅតាមបន្ទាត់ព្រំដែន ទាំងស្មារតី និងសម្ភារៈ។ បង្កើនការអប់រំប្រជាជនជាពិសេសស្រទាប់យុវវ័យអំពីស្មារតីស្នេហាជាតិ ស្រឡាញ់មាតុភូមិ និងចងចាំគុណូបការៈដ៏ថ្លៃថ្លារបស់បុព្វបុរស យុទ្ធជន យុទ្ធនារី ដែលបានធ្វើពលិកម្មយ៉ាងអង់អាចដើម្បីជាតិ ដែលជាកត្តាដ៏សំខាន់ចាំបាច់ដើម្បីពង្រឹងខឿនការពារជាតិរបស់ប្រជាជនឲ្យបានរឹងមាំយូរអង្វែង ។

- ពង្រឹង និងពង្រីកទំនាក់ទំនងជិតស្និទ្ធរវាងកងយោធពលខេមរភូមិន្ទ និងកងទ័ពនៃប្រទេសជិតខាងភូមិផងរបងជាមួយ ជាពិសេសរវាងអាជ្ញាធរខេត្ត ស្រុក និងអង្គភាពឈរជើងតាមព្រំដែន ដើម្បីពង្រឹងចំណងមិត្តភាព ស្ថិរភាព សន្តិសុខ តាមព្រំដែន បង្កើនសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងការប្រាស្រ័យទាក់ទងគ្នាដោយសុខដុមរមនារវាងប្រជាជននៅសងខាងព្រំដែន ។

- បង្កើនកិច្ចសហប្រតិបត្តិការរវាងកងយោធពលខេមរភូមិន្ទជាមួយកងយោធានៃបណ្តាប្រទេសជាមិត្ត ដោយឈរលើស្មារតីគោរពផលប្រយោជន៍គ្នាទៅវិញទៅមក និងបន្តចូលរួមចំណែកយ៉ាងសកម្មក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅបណ្តាប្រទេស តាមការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាល ។

## ២- ការការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម

- ខឿនសន្តិសុខជាតិ គឺជាកត្តាជាមូលដ្ឋានមួយមិនអាចខ្វះបាន ដើរទន្ទឹមនឹងខឿនការពារជាតិ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ពង្រឹងឲ្យបានរឹងមាំជាប្រចាំ សំដៅធានាថា សន្តិសុខនៃកម្ពុជាបានបំពេញតួនាទីជាបុព្វបទល្អប្រសើរ សម្រាប់ការអភិវឌ្ឍប្រទេសលើគ្រប់វិស័យប្រកបដោយចីរភាព និងភាពសុខដុមរមនានៃសង្គមជាតិ ។ ក្នុងស្មារតីនេះ ខិតខំកសាងឲ្យបាននូវ**ចលនាសន្តិសុខមាតុភូមិ** ប្រកបដោយឋាមពល ក្រោមពាក្យស្លោក "**មាតុភូមិខ្ញុំ សុវត្ថិភាពខ្ញុំ**" តាមរយៈការបន្តអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការបំផុសការចូលរួមដ៏ក្លៀវក្លារបស់ប្រជាជនគ្រប់រូប និងគ្រប់

មជ្ឈដ្ឋានក្នុងសង្គម ដោយមានកងនគរបាលជាតិធ្វើជាស្នូល ដើម្បីធានាការការពារស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ។

- បន្តជំរុញអនុវត្តគោលនយោបាយសុខដុមនីយកម្មសង្គមឲ្យកាន់តែមានប្រសិទ្ធភាព ដើម្បីធានាថែរក្សារឹងមាំនូវឆ្លងសាមគ្គីភាព ឯកភាពផ្ទៃក្នុងជាតិ មិនទុកឲ្យមានចន្លោះប្រហោងដែលត្រូវបានប្រើប្រាស់សម្រាប់ការបង្កើតឡើងនូវកម្លាំងប្រឆាំង ឬកម្លាំងប្រដាប់អាវុធខុសច្បាប់ណាមួយមកបំផ្លាញសមិទ្ធផលនានា និងភាពសុខសាន្តនៃសង្គមជាតិ ។

- រក្សាសន្តិសុខផ្ទៃក្នុងឲ្យបានរឹងមាំ ធានាការពារប្រក្រតីភាពនៃដំណើរការ និងការប្រព្រឹត្តទៅរបស់គ្រប់ស្ថាប័នជាតិ ប្រឆាំងដាច់ខាតសកម្មភាពបដិវត្តន៍ពណ៌ ដែលប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ប្រឆាំងរាល់សកម្មភាពកុប្បកម្ម ការធ្វើវិទ្ធង្សនា និងវិច្ឆេទកម្មគ្រប់រូបភាព និងការយកទឹកដីកម្ពុជាដើម្បីធ្វើសកម្មភាពប្រឆាំងនឹងប្រទេសជិតខាងដែលនឹងនាំប្រទេសជាតិឲ្យធ្លាក់ទៅក្នុងគ្រោះមហន្តរាយ និងសង្គ្រាមជាថ្មី។

- បើកទូលាយកិច្ចសហប្រតិបត្តិការជាមួយភ្នាក់ងារប្រតិបត្តិច្បាប់ នៃបណ្តាប្រទេសជាមិត្តក្នុងតំបន់ និងក្រៅតំបន់ ដើម្បីទប់ស្កាត់មិនឲ្យកើតមានអំពើភេរវកម្ម បង្ការ ទប់ស្កាត់ និងបង្ក្រាបដោយប្រសិទ្ធភាពនូវបទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាអាទិ៍ បទល្មើសគ្រឿងញៀន បទល្មើសបច្ចេកវិទ្យាព័ត៌មាន បទល្មើសជួញដូរមនុស្ស ។ល។

- លើកកម្ពស់សន្តិសុខ សុវត្ថិភាព សង្គម ធ្វើឲ្យជនគ្រប់រូបនៅក្នុងព្រះរាជាណាចក្រកម្ពុជាទទួលបានសេចក្តីសុខទាំងផ្លូវកាយ និងផ្លូវចិត្ត បទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទមានការថយចុះ ជាពិសេសបទល្មើសឧក្រិដ្ឋ បទល្មើសគ្រឿងញៀន និងបទល្មើសជួញដូរមនុស្ស។ រក្សាបរិយាកាសសង្គមកម្ពុជាដែលគ្មានក្រុមសង្គមងងឹត ក្រុមជនពាល និងជនទំនើង ហើយគ្រប់សហគមន៍ប្រជាជននៅភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ។

- រៀបចំសណ្តាប់ធ្នាប់សាធារណៈ និងសណ្តាប់ធ្នាប់ចរាចរណ៍ឲ្យមានរបៀបរៀបរយល្អ ជាពិសេសនៅតាមរាជធានី ខេត្តធំៗ ទីប្រជុំជន និងតំបន់ទេសចរណ៍សំខាន់ៗ តាមរយៈការលើកកម្ពស់ការយល់ដឹង និងការគោរពប្រតិបត្តិច្បាប់ឲ្យបានគ្រប់ៗគ្នា ក្នុងនោះយកចិត្តទុកដាក់ធ្វើឲ្យគ្រោះថ្នាក់ចរាចរណ៍កាន់តែបានកាត់បន្ថយ ការកកស្ទះចរាចរណ៍ត្រូវបានដោះស្រាយ គ្រោះថ្នាក់អគ្គិភ័យមានការថយចុះ ព្រមជាមួយនឹងការលើកកម្ពស់របៀបរស់នៅប្រកបដោយភាពជឿនលឿន និងថ្លៃថ្នូរ ។

- ធានាការផ្តល់សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ អត្តសញ្ញាណបណ្ណ ឯកសារអត្រានុកូលដ្ឋានឲ្យបានលឿន រហ័សដោយមិនយកថ្លៃអាករ និងធានាការផ្តល់ឯកសារឆ្លងដែននានាឲ្យបានទាន់ពេលវេលា ។ ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីអត្តសញ្ញាណកម្មនៅកម្ពុជាសម្រាប់ឆ្នាំ ២០១៧-២០២៦ ឲ្យបានសម្រេច រៀបចំច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងការចុះបញ្ជីស្ថិតិអត្រានុកូលដ្ឋាន ព្រមទាំងធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងការងារអត្តសញ្ញាណកម្មតាមបែបបច្ចេកវិទ្យាព័ត៌មានឲ្យឆ្លើយតបតាមការវិវត្តន៍នៃសភាពការណ៍ ។

- ពង្រឹងការអនុវត្តច្បាប់ស្ដីពីអន្តោប្រវេសន៍យ៉ាងម៉ឺងម៉ាត់។ ទប់ស្កាត់ការជ្រៀតចូលមករស់នៅ ឬធ្វើសកម្មភាព ដោយខុសច្បាប់របស់ជនបរទេស តាមរយៈការបង្កើនសមត្ថភាពត្រួតពិនិត្យតាមច្រកទ្វារព្រំដែន ការពង្រឹងកំណត់ត្រាទិន្នន័យ និងកិច្ចសហការផ្លាស់ប្ដូរព័ត៌មានជាមួយបណ្ដាភ្នាក់ងារអន្តោប្រវេសន៍នៃបណ្ដាប្រទេសជាមិត្ត។ បង្កើនសកម្មភាពគ្រប់គ្រង ត្រួតពិនិត្យការស្នាក់នៅ និងការប្រកបមុខរបរវិជ្ជាជីវៈរបស់ជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមច្បាប់ ព្រមទាំងជំរុញការដោះស្រាយបញ្ហាជនបរទេសបែបអន្តោប្រវេសន៍ឲ្យបានសម្រេច។

- លើកកម្ពស់សមត្ថភាពកងកម្លាំងនគរបាលគ្រប់ជំនាញ គ្រប់ថ្នាក់ ឲ្យមានការរីកចម្រើនឆ្លើយតបតាមសំណូមពរនៃកិច្ចការពារ សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនាដំណាក់កាលថ្មី ដោយយកចិត្តទុកដាក់បន្តអនុវត្តកំណែទម្រង់ឲ្យបានស៊ីជម្រៅ ទាំងការងារបណ្ដុះបណ្ដាលបំពាក់បំប៉នជំនាញឯកទេសចាំបាច់ ការធ្វើវិភាគមុខងារ ការពិនិត្យកែសម្រួលរចនាសម្ព័ន្ធ ការត្រៀមកម្លាំងបន្តវេន ការងារគ្រប់គ្រងកម្លាំង និងជាពិសេសខិតខំអប់រំលើកកម្ពស់ការគោរពវិន័យ សីលធម៌ ធ្វើឲ្យនគរបាលជាតិក្លាយជាកងជួររៀបរយ និងបម្រើប្រជាជនដោយឆន្ទៈស្មោះស្ម័គ្រ។

### ខ.៨- ការពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេស ជំរុញសមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក

បច្ចុប្បន្ន និងក្នុងរយៈពេលមួយតទៅមុខទៀត យើងអាចប្រមើលមើល និងប៉ាន់ស្មានបានថា ពិភពលោកនឹងបន្តវិវត្តន៍ប្រែប្រួលតាមនិន្នាការពហុប៉ូល ដោយបណ្ដាប្រទេសមហាអំណាចបន្តប្រកួតប្រជែងគ្នាដើម្បីឧត្តមភាព និងឥទ្ធិពលលើវណ្ណសិរ្សនានា ទាំងនយោបាយ សេដ្ឋកិច្ច យោធា បច្ចេកវិទ្យា វិទ្យាសាស្ត្រ វប្បធម៌ ។ល។ ទន្ទឹមនេះ ជម្លោះតាមតំបន់ ការគំរាមកំហែង នឹងការប្រឈមជាសាកលនានា ដែលបណ្ដាលមកពីគ្រោះថ្នាក់នៃអាវុធនុយក្លេអ៊ែរ ការរីករាលដាលនៃចលនាភេរវកម្ម លំហូរនៃជនភៀសខ្លួន គ្រោះមហន្តរាយ ការប្រែប្រួលធាតុអាកាស ជម្ងឺឆ្លង។ល។ បានបំបែកផង និងបង្រួបបង្រួមប្រទេសនានាផង ក្នុងដំណើរការស្វែងរកដំណោះស្រាយចំពោះបញ្ហាទាំងនោះ។

សម្រាប់កម្ពុជា ការចូលរួម និងផ្ដល់វិភាគទានរបស់ខ្លួនក្នុងចលនានានានៃពិភពលោក ដោយរាប់ពីសមាហរណកម្មតំបន់ ដល់ការចូលរួមវិភាគទានចំពោះសន្តិភាព ស្ថិរភាព និងវិបុលភាពពិភពលោក **នឹងផ្អែកសំខាន់លើមូលដ្ឋានការពារផលប្រយោជន៍គោលរបស់ប្រទេសជាតិ** ។

អាស្រ័យហេតុនេះ នយោបាយការបរទេសរបស់គណបក្សប្រជាជនកម្ពុជាសម្រាប់ឆ្នាំ ២០១៨-២០២៣ នឹងផ្ដោតទៅលើការការពារឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី អព្យាក្រឹតភាព និងគោលការណ៍សន្តិសហវិជ្ជមាន ព្រមទាំងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដោយឈរលើមូលដ្ឋានស្មើភាព ស្មើសិទ្ធិ និងការគោរពគ្នាទៅវិញទៅមក។ សកម្មភាពសំខាន់ៗនៃកិច្ចការការបរទេសសម្រាប់បណ្ដាឆ្នាំទៅមុខនឹងផ្ដោតលើ ៖

- ពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ តាមរយៈយន្តការទ្វេភាគី និងពហុភាគីក្នុងតំបន់ និងពិភពលោក ជាមួយបណ្ដាប្រទេសទាំងអស់ និងអង្គការអន្តរជាតិ តាមគោលការណ៍គោរពគ្នាទៅវិញទៅមក មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងផងគ្នា ស្មើភាព និងស្មើសិទ្ធិ រួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ។

- បន្តចូលរួមយ៉ាងសកម្មជាមួយប្រទេសទាំងអស់ក្នុងតំបន់ និងពិភពលោក ក្នុងការរិះរកដំណោះស្រាយបញ្ហាប្រឈមដែលពិភពលោកកំពុងជួបប្រទះ ជាពិសេសការប្រែប្រួលអាកាសធាតុ ភេរវកម្ម ការកាត់បន្ថយសព្វាវុធ សន្តិសុខស្បៀង អាហារូបត្ថម្ភ និងថាមពល គ្រោះមហន្តរាយ ទប់ស្កាត់ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស ឧក្រិដ្ឋកម្មឆ្លងដែន ជម្ងឺឆ្លង អន្តោប្រវេសន៍ខុសច្បាប់ ។ល។

- នៅក្នុងតំបន់ យើងនឹងបន្តសហការយ៉ាងសកម្មជាមួយប្រទេសសមាជិកអាស៊ានទាំងអស់ ដើម្បីសម្រេចឲ្យបាននូវគោលដៅរបស់អាស៊ានជាសហគមន៍មួយដែលផ្អែកលើវិធានច្បាប់ យកចិត្តទុកដាក់ដល់ប្រជាជន និងយកប្រជាជនជាស្នូល ស្របតាម «ទស្សនវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ» ។

- ពង្រឹងកិច្ចសហការជាមួយប្រទេសជិតខាងដើម្បីពន្លឿនការកំណត់ខណ្ឌសីមា និងការបោះបង្គោលព្រំដែនឲ្យបានចប់សព្វគ្រប់ និងប្រែក្លាយតំបន់ព្រំដែនជាមួយប្រទេសជិតខាងទាំងអស់ឲ្យទៅជាតំបន់សន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍ ។

- បន្តប្រកាន់ជំហរអព្យាក្រឹតចំពោះរាល់បញ្ហាក្នុងតំបន់ និងអន្តរជាតិ និងផ្តល់សារៈសំខាន់ខ្ពស់ក្នុងការដោះស្រាយជម្លោះនានាដោយសន្តិវិធី តាមរយៈការចរចា ពិគ្រោះយោបល់ និងផ្អែកលើគោលការណ៍នៃច្បាប់អន្តរជាតិ។

- បន្តប្រកាន់ខ្ជាប់ "នយោបាយចិនមួយ" និងចាត់ទុកការងើបឡើងរីកចម្រើនខ្លាំងក្លារបស់ប្រទេសចិន ជាការរួមចំណែកដល់ការរីកចម្រើនលូតលាស់នៃសេដ្ឋកិច្ច ក៏ដូចជាការពង្រឹងនូវគ្រឹះសន្តិភាព និងស្ថិរភាពសម្រាប់តំបន់ និងពិភពលោកទាំងមូល ។

- បន្តបញ្ជូនកងកម្លាំងរក្សាសន្តិភាពកម្ពុជាចូលរួមយ៉ាងសកម្មក្នុងការការពារ និងថែរក្សាសន្តិភាពនៅក្នុងបណ្តាប្រទេស នៅក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការរក្សាសន្តិភាពរបស់ អ.ស.ប. រួមចំណែកដល់បុព្វហេតុសន្តិភាព និងមនុស្សធម៌ក្នុងពិភពលោក ។

- បន្តធ្វើការកែទម្រង់នយោបាយការទូតប្រពៃណី មកជានយោបាយការទូតដែលផ្តល់សារៈសំខាន់ដល់សកម្មភាព សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ ទេសចរណ៍ ទាក់ទាញការវិនិយោគពីបរទេស និងពង្រីកទីផ្សារនាំចេញផលិតផលកម្ពុជា។

- បង្កើនការប្រុងប្រយ័ត្នខ្ពស់ចំពោះការប៉ុនប៉ងអនុវត្តបដិវត្តន៍ពណ៌របស់មជ្ឈដ្ឋានខាងក្រៅ សំដៅផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ប្រឆាំងការជ្រៀតជ្រែករបស់បរទេសចូលកិច្ចការផ្ទៃក្នុងកម្ពុជា និងធ្វើការវាយបកល្បិចកលដ៏ខ្មៅងងឹតរបស់ពួកទាំងនោះ ព្រមទាំងបំភ្លឺ បង្ហាញការពិតអំពីសភាពការណ៍ជាក់ស្តែងនៅកម្ពុជា ការពារកេរ្តិ៍ឈ្មោះ កិត្តិយសរបស់ជាតិ និងសុឆន្ទៈរបស់គណបក្សប្រជាជនកម្ពុជា ក្នុងការរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍ ។

កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជាសម្រាប់ការកសាង និងការពារមាតុភូមិ ឆ្នាំ ២០១៨ - ២០២៣ ត្រូវបានកសាងឡើងដោយផ្អែកលើមូលដ្ឋានសមិទ្ធផលដ៏ថ្លៃថ្លានៃសង្គមជាតិរយៈពេល ៣៩ឆ្នាំកន្លងមក និងបំណងប្រាថ្នាដ៏ឧត្តុង្គឧត្តមរបស់ប្រជាជនកម្ពុជា ព្រមទាំងការវិវត្តន៍នៃសភាព

ការណ៍ជាតិ និងសភាពការណ៍អន្តរជាតិនៅដំណាក់កាលបច្ចុប្បន្ន ហើយត្រូវបានមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសអនុម័តនៅថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១៨។

**គណបក្សប្រជាជនកម្ពុជា** សូមអំពាវនាវដល់ជនរួមជាតិនៅគ្រប់ទិសទី និងមជ្ឈដ្ឋានចម្រើនជឿនលឿនទាំងអស់នៅក្នុងសង្គម សូមផ្តល់ការគាំទ្រ និងចូលរួមអនុវត្តកម្មវិធីនយោបាយនេះប្រកបដោយភាពជឿជាក់ ដើម្បីរួមគ្នាបង្កើតឡើងសមិទ្ធផលថ្មីៗទៀតលើគ្រប់វិស័យ កាន់តែធំធេងឡើងក្នុងបុព្វហេតុកសាង និងការពារមាតុភូមិយើងឆ្ពោះទៅរកអនាគតដ៏ត្រចះត្រចង់ ។